# របាយការណ៍

# សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ

របាយការណ៍ឆ្នាំទី២ នីតិកាលទី ៥ (វិច្ឆិកា ២០១៤ - តុលា ២០១៥)





**តំណាងរាស្ត្រប្រឈមការគំរាមកំហែង**
**ករណីហិង្សា ការបំពានលើអភ័យឯកសិទ្ធិ**
**និងការដកតំណែង**





## សកម្មភាពគណៈកម្មការជំនាញនៃរដ្ឋសភាកើនឡើងគួរឲ្យកត់សម្គាល់

ផលិតដោយ: **ខុមហ្វ្រែល** COMFREL

ខែ កុម្ភៈ ឆ្នាំ ២០១៦

# របាយការណ៍

# សមាគមរដ្ឋសភា និងតំណាងរាស្ត្រ

**មតិក្នុងរបាយការណ៍នេះមិនឆ្លុះបញ្ចាំងពីជំហររបស់ម្ចាស់ជំនួយ និងដៃគូរឡើង។**

រូបថតក្របមុខៈ *យកចេញពីទំព័រ Facebook របស់រដ្ឋសភាជាតិ និងពី Internet។*

# មាតិកា


- ➢ **សេចក្តីប្រកាសព័ត៌មានស្តីពី ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២ នៃនីតិកាលទី៥ (ភាសាខ្មែរ)**
- ➢ **សេចក្តីប្រកាសព័ត៌មានស្តីពី ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២ នៃនីតិកាលទី៥ (ភាសាអង់គ្លេស)**
- ➢ **របាយការណ៍ស្តីពីលទ្ធផលនៃការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ**

I. សង្ខេបការរកឃើញ ........ ០១

II. ដំណើរការប្រជុំរបស់រដ្ឋសភា ........ ០៤

២.១ ការប្រជុំពេញអង្គរបស់រដ្ឋសភា ........ ០៤

២.១.១ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភា ........ ០៥

២.១.២ ការបញ្ចេញមតិជាបរិមាណរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា........ ០៦

២.១.៣ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុប ........ ០៧

២.១.៤ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស .. ០៧

២.១.៥ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រតាមគណបក្សទៅលើតួអង្គស្ថាប័ន និងចំណុចផ្សេងៗ ........ ០៨

២.១.៦តារាងសេចក្តីព្រាង/សេចក្តីស្នើច្បាប់សំខាន់ៗ ដែលរដ្ឋសភាបានអនុម័ត ហើយបន្សល់នូវភាពចម្រូងចម្រាស ........ ០៩

២.២ការប្រជុំរបស់គណៈកម្មការជំនាញ/ប្រជុំដេញដោល ឬការឆ្លើយបំភ្លឺ........ ១០

III. ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ........ ១៣

៣.១ ចំនួនដង និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន ........ ១៤

៣.២ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ........ ១៦

៣.៣ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សនីមួយៗ ........ ១៧

៣.៤ មណ្ឌលរាជធានី ខេត្តដែលអ្នកតំណាងរាស្ត្របានចុះ ........ ១៩

៣.៥ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលរាជធានី ខេត្ត........ ១៩

IV. កិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា ........ ២០

៤.១ កិច្ចអន្តរាគមន៍របស់រដ្ឋសភា........ ២០

៤.២ លទ្ធផល និងលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រ ........ ២១

V. សំឡេង ឬការផ្តល់ពិន្ទុរបស់ម្ចាស់ឆ្នោតចំពោះអ្នកតំណាងរាស្ត្រ ........ ២៤

VI. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ ........ ២៥

៦.១ រដ្ឋសភាកែសម្រួលអ្នកនាំពាក្យ ........ ២៥

៦.២ ករណីលាលែងពីតំណាងរាស្ត្ររបស់ឯកឧត្តម វ៉ាន សំអឿន ........ ២៦

៦.៣ ការគំរាមអ្នកតំណាងរាស្ត្រដែលបានធ្វើការចោទសួរទាក់ទងថវិការដ្ឋសភា ........ ២៦

៦.៤ ក្រុមការងារ ឬគណៈកម្មការចម្រុះគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ........ ២៦

៦.៥ តំណាងរាស្ត្រ និងបញ្ហាព្រំដែន ........ ២៧

៦.៦ ការខ្វែងគំនិតគ្នាក្នុងការកោះហៅមន្ត្រីអាជ្ញាធរស្ថាប័នរដ្ឋឲ្យចូលបំភ្លឺក្នុងរដ្ឋសភា ........ ៣០

៦.៧ វប្បធម៌សន្ទនា គឺជាការបិទមាត់ភាគីសន្ទនា? ........ ៣១

៦.៨ អ្នកតំណាងរាស្ត្រមានអំណាចរដ្ឋបាលលើអ្នកតំណាងរាស្ត្រ? ........ ៣២

៦.៩ ភាពចម្រូងចម្រាសក្នុងការអនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ........ ៣៣

៦.១០ ការដាក់ទណ្ឌកម្មខាងវិន័យលើអ្នកតំណាងរាស្ត្រ អ៊ុំ សំអាន ........ ៣៥

៦.១១ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងរងអំពើហិង្សាយ៉ាងធ្ងន់ធ្ងរនៅមុខរដ្ឋសភា ........ ៣៦

៦.១២ អនុប្រធានទី១ នៃរដ្ឋសភាទទួលរងការគំរាមកំហែងជាបន្តបន្ទាប់មុនការសម្រេចដកតំណែងដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ........ ៣៨

៦.១៣ សិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភារបស់ឯកឧត្តម សម រង្ស៊ី ត្រូវបាត់បង់ ........ ៣៩

VII. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗទាក់ទងរដ្ឋសភា និងតំណាងរាស្ត្រ ........ ៤០

➤ **ឧបសម្ព័ន្ធ**

# សេចក្តីប្រកាសព័ត៌មានស្តីពី ការសង្កេត
# រដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២
# នៃនីតិកាលទី៥(ភាសាខ្មែរ)

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២ នៃនីតិកាលទី៥

របាយការណ៍សង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២ នៃរដ្ឋសភានីកាលទី៥ ក្នុងឆ្នាំ២០១៥ បានបង្ហាញថា បញ្ញត្តិខ្លះនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ត្រូវបានកែលម្អ។ សកម្មភាពរបស់គណៈកម្មការជំនាញរដ្ឋសភា និងចំនួននៃការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំពេញអង្គមានការកើនឡើង ប៉ុន្តែសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រមានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងរបាយការណ៍ឆ្នាំទី១ ឆ្នាំ ២០១៤។ ក្នុងឆ្នាំទី២ នេះអ្នកតំណាងរាស្ត្រពីគណបក្សប្រឆាំងកំពុងប្រឈមការគំរាមកំហែង ករណីហិង្សា និងការបំពានលើអភ័យឯកសិទ្ធិ និងការដកតំណែង ដែលមិនស្របនឹងរដ្ឋធម្មនុញ្ញ។

លោក **គល់ បញ្ញា** នាយកប្រតិបត្តិរបស់ខុមហ្វ្រែល បានលើកឡើងថា «អាណត្តិនេះ តាមពិតត្រូវមានឱកាសច្រើនដោយការគោរពរដ្ឋធម្មនុញ្ញ និងកិច្ចព្រមព្រៀងរបស់គណបក្សកាន់អំណាច និងគណបក្សមិនកាន់អំណាចរដ្ឋាភិបាល ដែលអ្នកតំណាងរាស្ត្រ និងរដ្ឋសភាអាចបំពេញ និងប្រតិបត្តិសិទ្ធិអំណាច និងតួនាទីដើម្បីគណនេយ្យភាពប្រជាធិបតេយ្យ បានប្រសិទ្ធផលច្រើនជាងការរកឃើញនៅក្នុងរបាយការណ៍នេះ។ ឱកាសនេះ ត្រូវបានកាត់បន្ថយ ដោយអ្នកកាន់អំណាចរដ្ឋាភិបាល និងមិនទាន់ត្រូវបានប្រើប្រាស់ពេញលេញ និងប្រសិទ្ធភាព ដោយអ្នកតំណាងរាស្ត្រ។»

**ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រៈ** ក្នុងរយៈពេលពីខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែតុលា ឆ្នាំ២០១៥ មានតំណាងរាស្ត្រចំនួន**៩១រូប** មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួន **១០០៤លើក**។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងរបាយការណ៍ឆ្នាំទី១ នៃនីតិកាលទី៥នេះ ការសង្កេតឃើញថា ចំនួនសកម្មភាពមានការថយចុះ ហើយចំនួនតំណាងរាស្ត្រចុះធ្វើសកម្មភាពក៏មានការថយចុះតិចតួចដែរ ដែលក្នុងរយៈពេលនោះមានតំណាងរាស្ត្រចំនួន**៩៦រូប** ចុះធ្វើសកម្មភាពបានចំនួន**១២៧៤លើក**។ ការថយចុះចំនួនសកម្មភាពរបស់តំណាងរាស្ត្រ ជាពិសេសតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាក្នុងរយៈពេលនេះ ការសង្កេតឃើញថា មានមូលហេតុមួយចំនួនដូចជា ទី១.តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាខ្វះកិច្ចសហការក្នុងការផ្តល់ព័ត៌មានអំពីសកម្មភាពចុះមូលដ្ឋានរបស់ខ្លួន និងសកម្មនៅរដ្ឋសភា, ទី២.តំណាងរាស្ត្រមួយចំនួនមិនសូវចុះធ្វើសកម្មភាពនៅមូលដ្ឋាន និងមានការយល់ឃើញថា ក្រុមការងារចុះពង្រឹងមូលដ្ឋានរបស់គណបក្សនេះរួមមានមន្ត្រីអាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាល បានធ្វើសកម្មភាពច្រើនហើយ និងទី៣.ការិយាល័យតំណាងរាស្ត្របំពេញការងាររបស់ខ្លួនមិនបានពេញលេញ។ ដោយឡែកសកម្មភាពតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមានការកើនឡើងក៏ព្រោះតែមិនសូវមានសកម្មភាពការងារចំពោះកិច្ចនៅរដ្ឋសភា មានបញ្ហាអំពីការដកតំណែង ដកអភ័យឯកសិទ្ធិអ្នកដឹកនាំនៃតំណាងរាស្ត្ររបស់ខ្លួន និងបានធ្វើពហិការមិនចូលកិច្ចប្រជុំមួយចំនួន ដែលធ្វើឲ្យតំណាងរាស្ត្រទាំងនោះមានពេលវេលាចុះទៅមូលដ្ឋានបានច្រើន។

ក្នុងរយៈពេលពីខែវិច្ឆិកា ២០១៤ ដល់ខែតុលា ២០១៥ ខុមហ្វ្រែលទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ច្រើនជាងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។ តំណាងរាស្ត្រពីគណ

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office** : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

បក្សសង្គ្រោះជាតិចំនួន **៤២រូប** បានចុះមូលដ្ឋានចំនួន**៧៧៤លើក** (គិតជាមធ្យមតំណាងរាស្ត្រម្នាក់ធ្វើសកម្មភាព ១៨ លើក) ហើយតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន **៤៩រូប**ចុះមូលដ្ឋានបានចំនួន **២៣០លើក** (គិតជាមធ្យម តំណាងរាស្ត្រម្នាក់ធ្វើសកម្មភាព ៤លើក)។

**ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភា:** រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញ២លើក និងបានបើកកិច្ចប្រជុំជាវិសាមញ្ញ ២លើក ដែលមាន ២៣កិច្ចប្រជុំ ក្នុងនោះភាគច្រើនចំណាយពេល១ព្រឹកក្នុងមួយកិច្ចប្រជុំ។ របៀបវារៈចំនួន ២៥[1] ត្រូវលើកមកពិភាក្សា និងអនុម័ត ដែលរួមមានៈ សេចក្តីស្នើច្បាប់ចំនួន ០៧ សេចក្តីព្រាងច្បាប់ចំនួន ១០ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន ០៧លើក និងការបោះឆ្នោតទម្លាក់តំណែងចំនួន ១លើក។

ក្នុងចំណោមកិច្ចប្រជុំទាំងនោះ មានអ្នកតំណាងរាស្ត្រចំនួន **៤៣រូប** បានឡើងមកបញ្ចេញមតិ ដោយប្រើប្រាស់ថេរវេលាសរុប **១១៩៩នាទី**។ បើធ្វើការប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី១ ចំនួនអ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិមានការកើនឡើង ដែលពេលនោះមានតំណាងរាស្ត្រចំនួន **២៣រូប** បានឡើងបញ្ចេញមតិ ប្រើប្រាស់ថេរវេលាសរុប **៦៩៣នាទី** ។

អ្នកតំណាងរាស្ត្រទាំង **៤៣រូប** ដែលបានឡើងមកបញ្ចេញមតិមាន **២១រូប** ពីគណបក្សប្រជាជនកម្ពុជា និង **២២រូប** ពីគណបក្សសង្គ្រោះជាតិ។ ការសង្កេតឃើញថា ចំនួនតំណាងរាស្ត្រឡើងបញ្ចេញមតិពីគណបក្សសង្គ្រោះជាតិមានការកើនឡើងច្រើនបើធៀបក្នុងឆ្នាំទី១ ដែលមានចំនួនតែ **៤រូប**។ មូលហេតុនៃការកើនឡើងគឺដោយសារតំណាងរាស្ត្រពីគណបក្សនេះ បានសម្រេចចូលរដ្ឋសភាចាប់ពីខែសីហា ឆ្នាំ២០១៤។

បើទោះជាមានការកើនឡើងអំពីចំនួននៃការបញ្ចេញមតិ ប៉ុន្តែការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ជាច្រើន គឺខ្វះតម្លាភាព មិនសូវមានគុណភាព និងធ្វើឡើងដោយប្រញាប់ប្រញាល់។ ជាក់ស្តែងដូចជាការអនុម័តសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ធ្វើឡើងដោយមិនមានការពិភាក្សាលើខ្លឹមសារច្បាប់។ សេចក្តីព្រាងច្បាប់ចំនួនប្រាំ (០៥) ត្រូវបានអនុម័តមានសំឡេងតែមួយគណបក្ស គឺគណបក្សប្រជាជនកម្ពុជា។ ដោយឡែកការពិភាក្សាលើសេចក្តីព្រាងច្បាប់ដ៏ចម្រូងចម្រាសស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ អ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិបានដើរតួនាទីដូចអ្នកការពារច្បាប់ គឺធ្វើការពន្យល់នូវចំណុចវិជ្ជមាននៃសេចក្តីព្រាងច្បាប់ នៅស្របពេលដែលមជ្ឈដ្ឋានជាតិ និងអន្តរជាតិធ្វើការរិះគន់ថា ច្បាប់នេះបានរឹតត្បឹតសិទ្ធិ សេរីភាពរបស់អង្គការ សមាគមមិនមែនរដ្ឋាភិបាល និងខ្វះតម្លាភាពក្នុងការតាក់តែងសេចក្តីព្រាងច្បាប់នេះ។

**សកម្មភាពរបស់គណៈកម្មការជំនាញរបស់រដ្ឋសភា:** សកម្មភាពរបស់គណៈកម្មការជំនាញមានការកើនឡើងច្រើនគួរឲ្យកត់សម្គាល់ ទាំងគណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលក្នុងរយៈពេលនេះមានសកម្មភាពរហូតដល់ **១០៥លើក។** បន្ទាប់ពីមានការបែងចែកអំណាច ដោយគណៈកម្មការជំនាញពាក់កណ្តាល (៥គណៈកម្មការជំនាញ) ដឹកនាំដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ចាប់ពីអំឡុងខែសីហា ឆ្នាំ២០១៤ ការសង្កេតឃើញថា សកម្មភាពរបស់គណៈកម្មការជំនាញមានការកើនឡើងជាលំដាប់។ ក្នុងចំណោមសកម្មភាពរបស់គណៈកម្មការជំនាញទាំងអស់ គណៈកម្មការជំនាញដឹកនាំដោយគណបក្សសង្គ្រោះជាតិមានសកម្មភាពច្រើនជាង ដែលចំនួន **៦៦លើក** រីឯគណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជាមានសកម្ម

[1] មិនរួមបញ្ចូលទាំងព្រះរាជសាររបស់ព្រះមហាក្សត្រជូនសម័យប្រជុំរដ្ឋសភាចំនួន ២លើក និងរបាយការណ៍រាយការណ៍ប្រចាំចន្លោះសម័យប្រជុំរដ្ឋសភា ចំនួន ២លើក។

ភាពចំនួន **៣៩លើក**។ សកម្មភាពរួមមាន ការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ និងជួបពិភាក្សានៅសាមីក្រសួងពាក់ព័ន្ធ សកម្មភាពទទួលពាក្យបណ្ដឹងពីប្រជាពលរដ្ឋ និងការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ច ឬ/និងប្រជាពលរដ្ឋ ឬតំណាងអង្គការសង្គមស៊ីវិល និងព្រមទាំងសកម្មភាពចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ (ពិសេសទំនាស់ដីធ្លី)។ រដ្ឋមន្ត្រីចំនួន ០៨រូប ត្រូវបានហៅមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញរដ្ឋសភា និងនៅក្នុងក្រសួងសាមី។

**លទ្ធផល និងលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រ:** រាជរដ្ឋាភិបាលសម្រេចលុបចោលកិច្ចព្រមព្រៀងទទួលសិទ្ធិលក់សំបុត្រចូលទស្សនាតំបន់អង្គរក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០១៥ និងបានសម្រេចស្ដីពីការលុបចោលនូវកិច្ចព្រមព្រៀងសម្បទានរវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុន AZ លើការយកកម្រៃសេវាថែទាំ និងជួសជុលផ្លូវជាតិលេខ៤ ក្នុងខែមករា ឆ្នាំ២០១៦។ ការសម្រេចលុបកិច្ចព្រមព្រៀងទាំងពីរនេះ មានការមើលឃើញថា ជាការខិតខំរបស់អ្នកតំណាងរាស្ត្រ។

ពាក់ព័ន្ធការលក់សំបុត្រចូលទស្សនាតំបន់អង្គរវត្ត អ្នកតំណាងរាស្ត្រពីគណបក្សប្រឆាំង តែងតែធ្វើការទាមទារអំពីតម្លាភាព និងការបង្កើនចំណូល និងបានស្នើជាបន្តបន្ទាប់ឲ្យរដ្ឋាភិបាលលុបចោលកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនឯកជននេះ។ ចំពោះការយកកម្រៃសេវាថែទាំ និងជួសជុលផ្លូវជាតិលេខ៤ អ្នកតំណាងរាស្ត្រពីគណបក្សប្រឆាំងក៏បានទាមទារឲ្យមានលុបចោលផងដែរ ដោយធ្វើការចោទប្រកាន់ថា កិច្ចព្រមព្រៀងនោះមិនមានតម្លាភាព និងមិនមានការដេញថ្លៃ ហើយចំណូលពីការប្រមូលថវិកា មិនសមាមាត្រនឹងទំហំនៃការថែទាំ និងជួសជុលផ្លូវជាតិមួយនេះទេ។

ក្នុងរយៈពេលនេះ ការសង្កេតឃើញថា អ្នកតំណាងរាស្ត្របានចេញលិខិតចំនួន ៣៦ច្បាប់ ថ្វាយ/ជូនព្រះមហាក្សត្រ រាជរដ្ឋាភិបាល រដ្ឋសភា និងស្ថាប័នសារព័ត៌មាន ក្នុងគោលបំណងភាគច្រើនស្នើ ឬអំពាវនាវវិធានការពីស្ថាប័ននីតិប្រតិបត្តិ ដើម្បីអន្តរាគមន៍រកដំណោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។ លិខិតស្ទើរទាំងអស់ធ្វើឡើងដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ។ ក្នុងចំណោមលិខិតទាំងនោះ មានលិខិតចំនួន ៩ច្បាប់ ទទួលការឆ្លើយតបពីរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។ ជាមួយគ្នានេះមានលិខិតចំនួន ៤ច្បាប់ ត្រូវបានបដិសេធមិនធ្វើការបញ្ជូនដោយប្រធានរដ្ឋសភាផងដែរ ដែលករណីនេះត្រូវបានពិនិត្យឃើញថា ជាការប្រើសិទ្ធិអំណាចជាប្រធានរដ្ឋសភាហួសព្រំដែន។

**ការពង្រឹងការងារនៃការិយាល័យតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង:** យ៉ាងហោចណាស់មានការិយាល័យតំណាងរាស្ត្រមួយនៅក្នុងខេត្តព្រៃវែង ត្រូវបានពង្រឹងដោយអ្នកតំណាងរាស្ត្រ (អ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ) ដែលបានឯកភាពគ្នាកំណត់ឲ្យមានអ្នកតំណាងរាស្ត្រប្រចាំការ ក្នុងគោលបំណងទទួលជួបផ្ទាល់ជាមួយម្ចាស់ឆ្នោត និងទទួលពាក្យបណ្ដឹង ដើម្បីឈានទៅរកដោះស្រាយបញ្ហាជូនម្ចាស់ឆ្នោតតាមយន្តការការិយាល័យតំណាងរាស្ត្រ និងរដ្ឋសភា។

ជាការកត់សម្គាល់ ការរៀបចំនេះបានទទួលការចាប់អារម្មណ៍ពីម្ចាស់ឆ្នោត ហើយបញ្ហាមួយចំនួនត្រូវបានបញ្ជូនទៅរដ្ឋសភា ហើយរដ្ឋសភាបានស្នើវិធានការបន្តពីអាជ្ញាធរមានសមត្ថកិច្ច។ បើទោះជាសកម្មភាពនេះមិនទាន់បានបង្ហាញអំពីលទ្ធផលជាដុំកំភួន និងឆ្លើយតបទៅនឹងបញ្ហាម្ចាស់ឆ្នោតក្នុងខេត្តព្រៃវែង ប៉ុន្តែវាគឺជាការខិតខំល្អមួយដើម្បីប្រសិទ្ធភាពការងាររបស់ការិយាល័យតំណាងរាស្ត្រផង និងដើម្បីផលប្រយោជន៍ម្ចាស់ឆ្នោតផង។

**តំណាងរាស្ត្រ១០រូប ដែលសកម្មជាងគេ:** ចំពោះការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ខុមហ្វ្រែលទទួលព័ត៌មានថា មានតំណាងរាស្ត្រ **១០រូប** ពីគណបក្សសង្គ្រោះជាតិ បានធ្វើសកម្មភាពច្រើនជាងគេ។ ដោយឡែកចំពោះការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភាវិញ តំណាងរាស្ត្រដែលសកម្មភាពជាងគេរួមមាន **៧រូប** ពីគណបក្សប្រជាជនកម្ពុជា និង**៣រូប** ពីគណបក្សសង្គ្រោះជាតិ។ ចំពោះការផ្ដល់ពិន្ទុដោយម្ចាស់ឆ្នោតដល់អ្នកតំណាង

រាស្ត្រអំពីការបំពេញសកម្មភាព និងភារកិច្ចវិញ ជាលទ្ធផលឃើញថា តំណាងរាស្ត្រ **៥រូប** ពីគណបក្សប្រជាជនកម្ពុជា និង **៥រូប** ពីគណបក្សសង្គ្រោះជាតិ មានម្ចាស់ឆ្នោតបានផ្តល់ពិន្ទុច្រើនជាងគេ។

**តំណាងរាស្ត្រមានភាពងាយរងគ្រោះ:** តំណាងរាស្ត្រ ដែលការពារដោយអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពិសេសមួយចំនួន ដែលចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ប៉ុន្តែប្រឈមភាពងាយរងគ្រោះ មិនខុសពីប្រជាពលរដ្ឋធម្មតានោះទេ។ ការសង្កេតឃើញថា មានតំណាងរាស្ត្រ ៥រូប រួមទាំងសមាជិកព្រឹទ្ធសភាម្នាក់ មកពីគណបក្សប្រឆាំង (គណបក្សសម  រង្ស៊ី និងគណបក្សសង្គ្រោះជាតិ) បានទទួលរងគ្រោះលើបញ្ហាមួយចំនួនដូចជា ការរំលោភបំពានលើការដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រពីរដ្ឋសភា និងពីតុលាការ ការដកតំណែង និងបញ្ហាសន្តិសុខសុវត្ថិភាព ព្រោះថា តំណាងរាស្ត្របានទទួលរងនូវអំពើហិង្សា និងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរនៅមុខរដ្ឋសភា នៅពេលខ្លួនចុះបំពេញការងារ (ចុះពិនិត្យតំបន់ដែលមានទំនាស់នៅតាមបន្ទាត់ព្រំដែន) និងនៅគេហដ្ឋាន។ ភាពងាយរងគ្រោះមួយទៀត អង្គភាពប្រឆាំងអំពើពុករលួយបានដាក់លិខិតសួរនាំតំណាងរាស្ត្រម្នាក់ អំពីកិច្ចការចាយវាយ រៃអង្គាសថវិកាបុគ្គលឯកជនសម្រាប់ការងារបេសកកម្មរបស់ខ្លួន វាមិនត្រឹមជាការគំរាមកំហែង តែវាជាការរំលោភសិទ្ធិ។ តំណាងរាស្ត្រជារួមក៏ទទួលរងគំនាបពីគណបក្សនយោបាយសាមី ព្រោះថា ច្បាប់បោះឆ្នោតបានចែងថា «សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្ស...។»[2]

**ការសន្ទនារបស់គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ:** សហគមន៍ជាតិ និងអន្តរជាតិបានសាទរចំពោះការបង្កើតឲ្យមានការសន្ទនារវាងគណបក្សទាំងពីរ ព្រោះថា បញ្ហាជាតិ និងការខ្វែងគំនិតគ្នារវាងគណបក្សដឹកនាំរដ្ឋាភិបាល និងគណបក្សនៅក្រៅរដ្ឋាភិបាល ដែលមានអាសនៈក្នុងរដ្ឋសភានឹងត្រូវបានដោះស្រាយ។ មួយវិញទៀត ក្របខ័ណ្ឌច្បាប់ (បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា) និងក្រមសីលធម៌សម្រាប់គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ ត្រូវបានបង្កើត ដើម្បីជំរុញការសន្ទនានេះ។ មិនយូរប៉ុន្មានវប្បធម៌សន្ទនានេះ ជួបភាពរង្គោះរង្គើ ព្រោះភាគីសន្ទនានៃគណបក្សប្រជាជនកម្ពុជាយល់ឃើញថា ភាគីសន្ទនារបស់ខ្លួនមិនអាចធ្វើការតិះតៀនខ្លួនបានទេ។ រីឯភាគីនៃគណបក្សសង្គ្រោះជាតិយល់ឃើញថា ខ្លួនត្រូវធ្វើការងារពីរទន្ទឹមគ្នា គឺកិច្ចការសន្ទនាជាមួយភាគីគណបក្សកាន់អំណាចលើការទម្រង់បញ្ហាជាតិមួយចំនួន និងនៅធ្វើការតិះតៀនរដ្ឋាភិបាល និងគណបក្សកាន់អំណាចក្នុងនាមខ្លួនជាគណបក្សប្រឆាំង។

### សម្រាប់ព័ត៌មានបន្ថែមៈ

| **ឈ្មោះ** | **លេខទូរស័ព្ទ** |
|---|---|
| • លោក គឹម ឈន | ០១២ ៩៤២ ០១៩ |
| • លោក កន សាវង្ស | ០១១ ៨៨៤ ៨៤០ |
| • លោក ស៊ិន ទិត្យសីហា | ០១២ ២៥២ ៦៦១ |

[2] មាត្រា ១៣៩ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

# សេចក្តីប្រកាសព័ត៌មានស្តីពី ការសង្កេត
# រដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២
# នៃនីតិកាលទី៥ ( ភាសាអង់គ្លេស )

Phnom Penh, Date Feb 18, 2016

**Press Release Statement**

**On**

**National Assembly and Parliamentarian Watch for 2nd Year of the 5th Mandate**

The report on Parliamentary Watch in year II of the 5th mandate, 2015 revealed that some provisions of the Internal Regulation of the National Assembly were amended and improved. The working activities of the expert commissions and numbers of parliamentarians who had expressed their opinion in plenary sessions of the National Assembly increased comparing to the previous year, 2014. However, the number of visits to constituencies by NA's members actually decreased.

In this second year of the fifth mandate, opposition party's members were subjected to threats, harassment, violence and abuse of parliamentarian immunity and the depriving of membership parliamentarian of the opposition party.

Mr. **Koul Panha**, executive director of COMFREL stated that "in fact, this year of the mandate, there were great opportunities for both parties' parliamentarians to following or exercising provisions of the constitution. Also the expression of the political agreement of the two parties which was made last year in which the parliamentarians might function well their duties, roles and powers to ensure effective democratic accountability of the NA."

The numbers of constituencies visits made by MPs from both parties from November 2014 to October 2015, was 91 amounted to 1004 times. The rate decreased compared to 2014-report when there were 1274 visits by 96 members of both parties' It is reported that the decreasing of numbers of constituencies visits of MPs, particularly those who belong to CPP, due to some of the following reasons; (1) Lacking of cooperation of reporting the cases from MPs of the CPP on their field visits and activities at the national assembly, (2) Some CPP's MPs did not really focus on their constituencies visits because they thought that jobs have been done by their executive officials such as local authorities, working groups, Government officials, and (3) the Offices of MPs have not worked well.. Partly, it was discovered that the numbers of field visits of MPs from CNRP increased because there were little work and tasks to be done at the National Assembly, after the removal form the NA of the CNRP top leadership. This led to boycotting of some several meeting sessions of the National Assembly and therefore, freeing up more time for them to make filed visits.

Between November 2014 and October 2015 COMFREL reported about field visits of MPs from CNRP were more than CPP's. Forty two CNRP's MPs made field visits, 774 times (18 times

on average for each parliamentarian) and 49 CPP's MPs amounting to 230 visits ( 4 times on average for each MP).

The National Assembly's Plenary Sessions Processes: The National Assembly opened its ordinary sessions twice and the other two extraordinary sessions were called for meeting. The two meeting sessions (ordinary and extraordinary summed up together accounted for 23 times of debate sessions and majority of the sessions were a full of a single morning session. There were twenty five session's agendas picked out debate and approval including; seven proposed drafted laws, 10 submitted draft laws from the Cabinets, 7 times voted to giving confidence on proposed candidates for offices and 1 time voted to dismissal of first Vice-president of the National Assembly post.

Amongstts all those meeting sessions, forty three (43) MPs had expressed their opinion of the issues and it took (one thousand one hundred and ninety nine (1199) minutes in total. It's found increase if comparing to the 2014-report (first year report of the 5th mandate) which had only twenty three (23) parliamentarians expressed their opinion on the matters and times consuming acounted for six hundreds and ninety three (693) minutes in total.

Amongst the forty three (43) PMs who had been named for expression of opinion, twenty one (21) parliamentarians were CPP and twenty two (22) were CNRP. It was s reported that the numbers of CNRP's MPs who were named to express opinion increased when compared with the previous year' which showed that only four (4) MPs had been named to express their opinion. The reason for the increase is attributed to the fact that in August 2014, all fifty five (55) CNRP's MPs took their seats in the National Assembly.

In spite of the fact that the numbers of parliamentarians from the CNRP who had expressed their opinion had increased, on many occasions during the the debate and approval of the proposed draft laws and drafted laws were reported as less transparent. , questions of quality of the passed bills and were pushed to be passed immediately , especailly the following things: the proposed draft law on the Organization and Functioning of the National Election Commnittee, the proposed draft law on Election of Members of the National Assembly, LEMNA, and the proposed draft law on Election of Commune/Sangkat Council. The three aforementioned laws were passed over without any debate on its legal essence. There were 5 drafted laws passed with a single party's voices, CPP. Apart from this, the debates on the very controversial drafted laws of LANGO and Financial Budget Management bill of 2016, speakers from CPP played role as draft law defending groups who are generally in charge as the executive..

Parliamentarian's activities of the Expert Commissions: Parliamentarian's activities of the expert commissions were reported on, notably an increase both the Commissions led by CNRP and Committees led by CPP. The numbers of activities recorded were up to 105 times in totaly. After the division of each five lead-Expert Commissions, from October 2014 to early end of 2015, the five expert commissions leading by CNRP were reported increase gradually. Amongst all reported

activities, 66 times were belonged to CNRP's lead-Expert commissions and CPP's lead-Expert commissions amounted for 39 times. Those expert commissions' activities included the invitation/summons of the ministers in-charge of ministries and Royal Govt. officials to answer questions on the appealed petitions, meeting with ministers in charge to discuss on the relevant matters, receiving petitions from appealed petitioners and the field visits with executive authorities or citizens or representatives of Civil Society Organizations and went to the disputed areas, epsecially the land crisis areas. It's reported that eight (8) ministers of the ministry were summonsed to answer questions before the relevant expert commissions.

Results and appealed letters of Parliamentarians: The Royal Govt. of Cambodia decided to invalidate the agreement on the collection of Angkor Wat revenue between Royal Govt. of Cambodia and Sokimex in November 2015 and revoke the license of the 35-year concession agreement granted to AZ Distribution Company to maintain and service National Road number 4 in early January 2016. The decision of the Royal Govt. of Cambodia to revoke licenses of the two concession agreements is seen the effort of the opposition party's MP.

Regarding the matter of the collection revenue of Angkor Wat by Sokimex company, parliamentarians from opposition party have always demanded transparency and an increase in revenue collecting capacity They have consistently requested that the Royal Govt. of Cambodia revoke the license for the concession agreement with Sokimex. The collection of the service toll fee for national road number 4, has also been questioned by opposition party f parliamentarians. They have frequently the revoking of the concession license, claiming that the concession agreement was not transparent and it was made without a public bidding process. In addition, the revenue collected was not proportionate to the actual maintenance and reparation of the road.

During this period, it was observed that MPs sent a total of 36 letters, to the King, the Royal Government of Cambodia, NA and department of information calling for an immediate action from the executive body to intervene. Almost of letters were written by CNRP. Only 9 letters were responded to by the government and relevant stakeholders. Four were rejected by NA president in what is considered an abuse of his power.

Strengthening the responsibilities of MP's office in Prey Veng: at least the Prey Veng provincial MP's office is regularly stationed a CNRP's MP to collect complaints, directly communicate with voters and solving the problems of voters' concerns. The instant stationing a PM for office was agreed within CNRP's MP.

It was noted that voters were interested in this solution. Some complaints were submitted to the NA requested for intervention by local authorities. Although, this mechanism has yet to show the any results, however, it is seen as a positive moving forward in encouraging MPs to take their responsibilities seriously in the interests of voters.

Ten (10) MPs were found active: It is observed that there were ten (10) CNRP's MPs actively conducted field visits. Apart from this, MPs who had named to express their opinion in the National Assembly sessions, seven (7) CPP's MPs and three CNRP's PMs, were recorded very active. Regarding the matter of Scoring Card on PM's performance and function their duties, it was discovered that five (5) CPP's MPs and five (5) CNRP's MPs were given high scores.

MPs in vulnerability: MPs are granted privilege and immunity by constitution and the existing law but they were facing challenges the same as ordinary citizens who are not granted immunity. The report revealed that there were five (5) MPs included one senator from the opposition party were harassed and abused on depriving their constitutional immunity, dismissal of office and security by the CPP's dominated MPs and the Courts. The opposition party's MPs were severely under threatening and harassing of mental and physical violence in their field work performance (the case like the visiting to the controversial border dispute) and even at their residence. Further, another vulnerability of MPs was that an opposition party's MP was summonsed to question by the ACU in the case of a dubious allegation of corruption involving raising fund activities. This was not only the threat but abusing their rights. All MPs are under pressure from their political parties because the provisions of LEMNA provided that "MP shall lose his/her membership in case he/she is deprived of party's membership".[1] They may even face removal from the party.

The political dialogue between CPP and CNRP: The national and international community welcomed the political dialogue between the CPP and CNRP and expected that the so-called '*culture of dialogue*' would make to solve the national controversial issues between the Royal Govt. of Cambodia and the opposition party peacefully. In addition, the legal framework (Internal regulation of NA) and code of conduct for both elected political parties were established to strengthen this culture of political dialogue. Unfortunately, this culture of political dialogue did not go smoothly and it seems would not last long. CPP used culture of political dialogue to threaten opposition party in their freedom of expression. The CNRP found itself in the difficult position where it performed its duty as the opposition questioning government performance on national issues, while attempting to avoid criticism of the CPP.

**For further information, please contact**

| | |
|---|---|
| Mr. Kim Chhorn | 012 942 019 |
| Mr. Korn Savang | 011 884 840 |
| Mr. Sin Titseiha | 012 252 661 |

[1] Article 2, Law on Election of Members of National Assembly, LEMNA, 2015.

# របាយការណ៍ស្តីពីលទ្ធផលនៃការសង្កេត
# រដ្ឋសភា និងតំណាងរាស្ត្រ

# របាយការណ៍ស្តីពីលទ្ធផលនៃការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ

## I. សង្ខេបការរកឃើញ

ការសង្កេតរដ្ឋសភា និងតំណាងរាស្ត្រ ឆ្នាំទី២ នៃរដ្ឋសភានីកាលទី៥ ក្នុងឆ្នាំ២០១៥ រកឃើញថា សកម្មភាពរបស់គណៈកម្មការជំនាញរដ្ឋសភា និងចំនួននៃការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំពេញអង្គមានការកើនឡើង ប៉ុន្តែសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រមានការថយចុះ បើធៀបនឹងរយៈពេលដូចគ្នាក្នុងរបាយការណ៍ឆ្នាំទី១ ឆ្នាំ២០១៤។ ក្នុងឆ្នាំទី២នេះ អ្នកតំណាងរាស្ត្រពីគណបក្សប្រឆាំងកំពុងប្រឈមការគំរាមកំហែង ករណីហិង្សា និងការបំពានលើអភ័យឯកសិទ្ធិ និងការដកតំណែង ដែលមិនស្របនឹងរដ្ឋធម្មនុញ្ញ។

នៅក្នុងរបាយការណ៍ឃ្លាំមើលរដ្ឋសភា និងតំណាងរាស្ត្រនេះ មានលើកមកបង្ហាញពីការសង្កេតនូវសកម្មភាពដូចជាៈ ដំណើរការប្រជុំរបស់រដ្ឋសភា សកម្មភាពសំខាន់ៗរបស់គណៈកម្មការជំនាញរដ្ឋសភា សកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ កិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា កម្មវិធីសំឡេងម្ចាស់ឆ្នោត និងព្រឹត្តិការណ៍សំខាន់ៗទាក់ទងរដ្ឋសភា និងតំណាងរាស្ត្រ។

**ដំណើរការប្រជុំពេញអង្គរបស់រដ្ឋសភាៈ** រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញ២លើក និងបានបើកកិច្ចប្រជុំជាវិសាមញ្ញ២លើក ដែលមាន២៣កិច្ចប្រជុំ ក្នុងនោះភាគច្រើនចំណាយពេល១ព្រឹកក្នុងមួយកិច្ចប្រជុំ។ របៀបវារៈចំនួន២៥[1] ត្រូវលើកមកពិភាក្សា និងអនុម័ត ដែលរួមមានៈ សេចក្តីស្នើច្បាប់ចំនួន០៧ សេចក្តីព្រាងច្បាប់ចំនួន១០ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន០៧លើក និងការបោះឆ្នោតទម្លាក់តំណែងចំនួន១លើក។

ក្នុងចំណោមកិច្ចប្រជុំទាំងនោះ មានអ្នកតំណាងរាស្ត្រចំនួន៤៣រូប ក្នុងនោះ ២១រូប មកពីគណបក្សប្រជាជនកម្ពុជា និង ២២រូប មកពីគណបក្សសង្គ្រោះជាតិ បានឡើងបញ្ចេញមតិ ដោយប្រើប្រាស់ថេរវេលាសរុប១១៩៩នាទី។ បើធ្វើការប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី១ ចំនួនអ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិមានការកើនឡើង ដែលពេលនោះមានតំណាងរាស្ត្រចំនួន២៣រូប បានឡើងបញ្ចេញមតិ ដោយប្រើប្រាស់ថេរវេលាសរុប៦៩៣នាទី។ តាមការសង្កេតឃើញថា ចំនួនតំណាងរាស្ត្រឡើងបញ្ចេញមតិពីគណបក្សសង្គ្រោះជាតិមានការកើនឡើងច្រើនបើធៀបជាមួយឆ្នាំទី១ ឆ្នាំ២០១៤ ដែលមានចំនួនតែ៤រូប។ មូលហេតុនៃការកើនឡើងគឺដោយសារតំណាងរាស្ត្រពីគណបក្សនេះ បានសម្រេចចូលរដ្ឋសភាចាប់ពីខែសីហា ឆ្នាំ២០១៤។

បើទោះជាមានការកើនឡើងអំពីចំនួននៃការបញ្ចេញមតិ ប៉ុន្តែការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ជាច្រើន គឺខ្វះតម្លាភាព មិនសូវមានគុណភាព និងធ្វើឡើងដោយប្រញាប់ប្រញាល។ ជាក់ស្តែងដូចជាការអនុម័តសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើឡើងដោយមិនមានការពិភាក្សាលើខ្លឹមសារច្បាប់។ សេចក្តីព្រាងច្បាប់ចំនួនប្រាំ (០៥) ត្រូវបានអនុម័តមានសំឡេងតែមួយគណបក្សគឺគណបក្សប្រជាជនកម្ពុជា។ ដោយឡែកការពិភាក្សាលើសេចក្តីព្រាងច្បាប់ដ៏ចម្រូងចម្រាស ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ អ្នកតំណាងរាស្ត្រឡើងបញ្ចេញមតិបានដើរតួនាទីដូចអ្នកការពារច្បាប់

[1] មិនរួមបញ្ចូលទាំងព្រះរាជសាររបស់ព្រះមហាក្សត្រជូនសម័យប្រជុំរដ្ឋសភាចំនួន ២លើក និងរបាយការណ៍រាយការណ៍ប្រចាំចន្លោះសម័យប្រជុំរដ្ឋសភាចំនួន ២លើក។

គឺធ្វើការពន្យល់នូវចំណុចវិជ្ជមាននៃសេចក្តីព្រាងច្បាប់ នៅស្របពេលដែលមជ្ឈដ្ឋានជាតិ និងអន្តរជាតិធ្វើការរិះគន់ថា ច្បាប់នេះបានរឹតត្បិតសិទ្ធិ សេរីភាពរបស់អង្គការ សមាគមមិនមែនរដ្ឋាភិបាល និងខ្វះតម្លាភាពក្នុងការតាក់តែងសេចក្តីព្រាងច្បាប់នេះ។

**សកម្មភាពរបស់គណៈកម្មការជំនាញរបស់រដ្ឋសភាៈ** សកម្មភាពរបស់គណៈកម្មការជំនាញមានការកើនឡើងច្រើនគួរឲ្យកត់សម្គាល់ ទាំងគណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលក្នុងរយៈពេលនេះមានសកម្មភាពរហូតដល់១០៥លើក។ បន្ទាប់ពីមានការបែងចែកអំណាច ដោយគណៈកម្មការជំនាញពាក់កណ្តាល (៥គណៈកម្មការជំនាញ) ដឹកនាំដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ចាប់ពីអំឡុងខែសីហា ឆ្នាំ២០១៤ ការសង្កេតឃើញថា សកម្មភាពរបស់គណៈកម្មការជំនាញមានការកើនឡើងជាលំដាប់។ ក្នុងចំណោមសកម្មភាពរបស់គណៈកម្មការជំនាញទាំងអស់ គណៈកម្មការជំនាញដឹកនាំដោយគណបក្សសង្គ្រោះជាតិមានសកម្មភាពច្រើនជាង ដែលចំនួន ៦៦លើក រីឯគណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រជាជនកម្ពុជា មានសកម្មភាពចំនួន៣៩លើក។ សកម្មភាពទាំងនោះរួមមាន ការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញ និងជួបពិភាក្សានៅសាមីក្រសួងពាក់ព័ន្ធ សកម្មភាពទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ច ឬ/និងប្រជាពលរដ្ឋ ឬតំណាងអង្គការសង្គមស៊ីវិល និងព្រមទាំងសកម្មភាពចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ។ រដ្ឋមន្ត្រីចំនួន០៨រូប ត្រូវបានហៅមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញរដ្ឋសភា និងនៅក្នុងក្រសួងសាមី។

**ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រៈ** ក្នុងរយៈពេលពីខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែតុលា ឆ្នាំ២០១៥ មានតំណាងរាស្ត្រចំនួន៩១រូប មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានចំនួន១០០៤លើក។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងរបាយការណ៍ឆ្នាំទី១ នៃនីតិកាលទី៥នេះបានបង្ហាញថា ចំនួនសកម្មភាពមានការថយចុះ ហើយចំនួនតំណាងរាស្ត្រចុះធ្វើសកម្មភាពក៏មានការថយចុះតិចតួចដែរ។ ក្នុងរយៈពេលនោះមានតំណាងរាស្ត្រចំនួន៩៦រូប ចុះធ្វើសកម្មភាពបានចំនួន១២៧៤លើក។ ការថយចុះចំនួនសកម្មភាពរបស់តំណាងរាស្ត្រ ជាពិសេសតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា ក្នុងរយៈពេលនេះការសង្កេតឃើញថា មានមូលហេតុមួយចំនួនដូចជា ទី១.តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាខ្វះកិច្ចសហការក្នុងការផ្តល់ព័ត៌មានអំពីសកម្មភាពចុះមូលដ្ឋានរបស់ខ្លួន និងសកម្មនៅរដ្ឋសភា, ទី២.តំណាងរាស្ត្រមួយចំនួនមិនសូវចុះធ្វើសកម្មភាពនៅមូលដ្ឋាន និងយល់ឃើញថា ក្រុមការងារចុះពង្រឹងមូលដ្ឋានរបស់គណបក្សនេះរួមមាន មន្ត្រីអាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាលបានធ្វើសកម្មភាពច្រើនហើយ និងទី៣.ការិយាល័យតំណាងរាស្ត្រមួយចំនួនបំពេញការងាររបស់ខ្លួនមិនបានពេញលេញ។ ដោយឡែកសកម្មភាពតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមានការកើនឡើងក៏ព្រោះតែមិនសូវមានសកម្មភាពការងារចំពោះកិច្ចនៅរដ្ឋសភា មានបញ្ហាអំពីការដកតំណែង ដកអភ័យឯកសិទ្ធិអ្នកដឹកនាំនៃតំណាងរាស្ត្ររបស់ខ្លួន និងបានធ្វើពហិការមិនចូលរួមកិច្ចប្រជុំមួយចំនួន ដែលធ្វើឲ្យតំណាងរាស្ត្រទាំងនោះមានពេលវេលាចុះទៅមូលដ្ឋានបានច្រើន។

ក្នុងរយៈពេលពីខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែតុលា ឆ្នាំ២០១៥ ខុមហ្វ្រែលទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ច្រើនជាងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។ តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំនួន៤២រូប បានចុះមូលដ្ឋានចំនួន៧៧៤លើក (គិតជាមធ្យមតំណាងរាស្ត្រម្នាក់ធ្វើសកម្មភាព១៨លើក) ហើយតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន៤៩រូប ចុះមូលដ្ឋានបានចំនួន២៣០លើក (គិតជាមធ្យមតំណាងរាស្ត្រម្នាក់ធ្វើសកម្មភាព៤លើក)។

**លទ្ធផល និងលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រៈ** រាជរដ្ឋាភិបាលបានសម្រេចលុបចោលកិច្ចព្រមព្រៀងទទួលសិទ្ធិលក់សំបុត្រចូលទស្សនាតំបន់អង្គរក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០១៥ និងបានសម្រេចស្តីពីការលុបចោលនូវកិច្ចព្រមព្រៀងសម្បទានរវាង

រាជរដ្ឋាភិបាល និងក្រុមហ៊ុនAZ លើការយកកម្រៃសេវាថែទាំ និងជួសជុលផ្លូវជាតិលេខ៤ ក្នុងខែមករា ឆ្នាំ២០១៦។ ការសម្រេចលុបកិច្ចព្រមព្រៀងទាំងពីរនេះ មានការមើលឃើញថា ជាការខិតខំរបស់អ្នកតំណាងរាស្ត្រ។

ពាក់ព័ន្ធការលក់សំបុត្រចូលទស្សនាតំបន់អង្គរវត្ត អ្នកតំណាងរាស្ត្រពីគណបក្សប្រឆាំង តែងតែធ្វើការទាមទារអំពីតម្លាភាព និងការបង្កើនចំណូល និងបានស្នើជាបន្តបន្ទាប់ឲ្យរដ្ឋាភិបាលលុបចោលកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនឯកជននេះ។ ចំពោះការយកកម្រៃសេវាថែទាំ និងជួសជុលផ្លូវជាតិលេខ៤ អ្នកតំណាងរាស្ត្រពីគណបក្សប្រឆាំងក៏បានទាមទារឲ្យមានលុបចោលផងដែរ ដោយធ្វើការចោទប្រកាន់ថា កិច្ចព្រមព្រៀងនោះមិនមានតម្លាភាព និងមិនមានការដេញថ្លៃ ហើយចំណូលពីការប្រមូលថវិកា មិនសមាមាត្រនឹងទំហំនៃការថែទាំ និងជួសជុលផ្លូវជាតិមួយនេះទេ។

ក្នុងរយៈពេលនេះ ការសង្កេតឃើញថា អ្នកតំណាងរាស្ត្របានចេញលិខិតចំនួន ៣៦ច្បាប់ ថ្វាយ/ជូនព្រះមហាក្សត្រ រាជរដ្ឋាភិបាល រដ្ឋសភា និងស្ថាប័នសារព័ត៌មាន ក្នុងគោលបំណងភាគច្រើនស្នើ ឬអំពាវនាវវិធានការពីស្ថាប័ននីតិប្រតិបត្តិ ដើម្បីអន្តរាគមន៍រកដំណោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។ លិខិតស្ទើរទាំងអស់ធ្វើឡើងដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ។ ក្នុងចំណោមលិខិតទាំងនោះ មានលិខិតចំនួន៩ច្បាប់ ទទួលការឆ្លើយតបពីរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។ ជាមួយគ្នានេះមានលិខិតចំនួន៤ច្បាប់ ត្រូវបានបដិសេធមិនធ្វើការបញ្ជូនដោយប្រធានរដ្ឋសភាផងដែរ ដែលករណីនេះត្រូវបានពិនិត្យឃើញថា ជាការប្រើសិទ្ធិអំណាចជាប្រធានរដ្ឋសភាហួសព្រំដែន។

**ការពង្រឹងការងារនៃការិយាល័យតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង:** យ៉ាងហោចណាស់មានការិយាល័យតំណាងរាស្ត្រមួយនៅក្នុងខេត្តព្រៃវែង ត្រូវបានពង្រឹងដោយអ្នកតំណាងរាស្ត្រ (អ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ) ដែលបានឯកភាពគ្នាកំណត់ឲ្យមានអ្នកតំណាងរាស្ត្រប្រចាំការ ក្នុងគោលបំណងទទួលជួបផ្ទាល់ជាមួយម្ចាស់ឆ្នោត និងទទួលពាក្យបណ្ដឹង ដើម្បីឈានទៅរកដំណោះស្រាយបញ្ហាជូនម្ចាស់ឆ្នោតតាមយន្តការការិយាល័យតំណាងរាស្ត្រ និងរដ្ឋសភា។

ជាការកត់សម្គាល់ ការរៀបចំនេះបានទទួលការចាប់អារម្មណ៍ពីម្ចាស់ឆ្នោត ហើយបញ្ហាមួយចំនួនត្រូវបានបញ្ជូនទៅរដ្ឋសភា ហើយរដ្ឋសភាបានស្នើវិធានការបន្តពីអាជ្ញាធរមានសមត្ថកិច្ច។ បើទោះជាសកម្មភាពនេះមិនទាន់បានបង្ហាញអំពីលទ្ធផលជាដុំកំភួន និងឆ្លើយតបទៅនឹងបញ្ហាម្ចាស់ឆ្នោតក្នុងខេត្តព្រៃវែង ប៉ុន្តែវាគឺជាការខិតខំល្អមួយ ដើម្បីប្រសិទ្ធភាពការងាររបស់ការិយាល័យតំណាងរាស្ត្រផង និងដើម្បីផលប្រយោជន៍ម្ចាស់ឆ្នោតផង។

**តំណាងរាស្ត្រ១០រូប ដែលសកម្មជាងគេ:** ចំពោះការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ តាមរយៈរបាយការណ៍ខុមហ្វ្រែលទទួលបានរកឃើញថា មានតំណាងរាស្ត្រ១០រូប ពីគណបក្សសង្គ្រោះជាតិ បានធ្វើសកម្មភាពច្រើនជាងគេ។ ដោយឡែកចំពោះការឡើងបញ្ចេញមតិរបស់តំណាងរាស្ត្រក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភាវិញ តំណាងរាស្ត្រដែលសកម្មភាពជាងគេរួមមាន ៧រូប ពីគណបក្សប្រជាជនកម្ពុជា និង៣រូប ពីគណបក្សសង្គ្រោះជាតិ។ ចំពោះការផ្ដល់ពិន្ទុដោយផ្ទាល់ពីម្ចាស់ឆ្នោតដល់អ្នកតំណាងរាស្ត្រអំពីការបំពេញសកម្មភាព និងភារកិច្ចវិញ ជាលទ្ធផលឃើញថា តំណាងរាស្ត្រ៥រូប ពីគណបក្សប្រជាជនកម្ពុជា និង៥រូប ពីគណបក្សសង្គ្រោះជាតិ មានម្ចាស់ឆ្នោតបានផ្ដល់ពិន្ទុច្រើនជាងគេ។

**តំណាងរាស្ត្រមានភាពងាយរងគ្រោះ ដោយការគំរាមកំហែង ការបំពារបំពាន និងអំពើហិង្សា:** តំណាងរាស្ត្រដែលការពារដោយអភ័យ និងបុព្វសិទ្ធិពិសេសមួយចំនួនដែលចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ប៉ុន្តែប្រឈមភាពងាយរងគ្រោះ មិនខុសពីប្រជាពលរដ្ឋធម្មតានោះទេ។ ការសង្កេតឃើញថា មានតំណាងរាស្ត្រ៥រូប រួមទាំងសមាជិកព្រឹទ្ធសភាម្នាក់មកពីគណបក្សប្រឆាំង (គណបក្សសម រង្ស៊ី និងគណបក្សសង្គ្រោះជាតិ) បានទទួលរងគ្រោះលើបញ្ហាមួយចំនួនដូចជា ការរំលោភបំពានលើការដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រពីរដ្ឋសភា និងពីតុលាការ ការដកតំណែង និងបញ្ហាសន្តិសុខសុវត្ថិភាព ព្រោះថា តំណាងរាស្ត្របានទទួលរងនូវអំពើហិង្សា និងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរនៅមុខរដ្ឋសភា នៅពេលខ្លួនចុះ

បំពេញការងារ (ចុះពិនិត្យតំបន់ដែលមានទំនាស់នៅតាមបន្ទាត់ព្រំដែន) និងនៅគេហដ្ឋាន។ ភាពងាយរងគ្រោះមួយទៀតគឺ អង្គភាពប្រឆាំងអំពើពុករលួយបានដាក់លិខិតសួរនាំទៅតំណាងរាស្ត្រម្នាក់ អំពីកិច្ចការចំណាយថវិកា ដែលរ៉ៃអង្គាសពីបុគ្គល ឯកជន សម្រាប់ការងារបេសកកម្មរបស់ខ្លួន វាមិនត្រឹមជាការគំរាមកំហែង តែវាជាការរំលោភសិទ្ធិ។ ជាទូទៅតំណាងរាស្ត្រក៏ ទទួលរងនូវគំនាបពីគណបក្សនយោបាយសាមីផងដែរ ព្រោះថា ច្បាប់បោះឆ្នោតបានចែងថា «សមាជិករដ្ឋសភាត្រូវបាត់បង់ សមាជិកភាពរបស់ខ្លួន ក្នុងករណីសាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្ស...។»[2]

**មាតិកាសំខាន់ៗ**


| | |
|---|---|
| I. សង្ខេបការរកឃើញ | ទំព័រទី ០១ |
| II. ដំណើរការប្រជុំរបស់រដ្ឋសភា | ទំព័រទី ០៤ |
| III. ការចុះមូលដ្ឋាន និងឬការិយាល័យតំណាងរាស្ត្រ | ទំព័រទី ១៣ |
| IV. កិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា | ទំព័រទី ២០ |
| V. សំឡេងម្ចាស់ឆ្នោតចំពោះអ្នកតំណាងរាស្ត្រ | ទំព័រទី ២៤ |
| VI. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ | ទំព័រទី ២៥ |
| VII. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗទាក់ទង រដ្ឋសភា និងតំណាងរាស្ត្រ | ទំព័រទី ៤០ |


**រូបសញ្ញាគណបក្សប្រើក្នុងរបាយការណ៍នេះ៖**

គណបក្ស ប្រជាជនកម្ពុជា

គណបក្ស សង្គ្រោះជាតិ

## II. ដំណើរការប្រជុំរបស់រដ្ឋសភា

### ២.១ ការប្រជុំពេញអង្គរបស់រដ្ឋសភា

របាយការណ៍សង្កេតរដ្ឋសភា និងតំណាងរាស្ត្រឆ្នាំទី២ នៃនីតិកាលទី៥ ចន្លោះពេលពីខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែ តុលា ឆ្នាំ២០១៥។ ការសង្កេតឃើញថា រដ្ឋសភាបានបើកសម័យប្រជុំពេញអង្គសាមញ្ញ២លើក (លើកទី១ ចន្លោះពេលពីខែ តុលា ២០១៤ ដល់ខែធ្នូ ២០១៤ និងលើកទី២ ក្នុងចន្លោះពីខែមេសា ២០១៥ ដល់ដើមខែកក្កដា ២០១៥) និងបានបើកកិច្ច ប្រជុំជាវិសាមញ្ញ ២លើក (លើកទី១ ក្នុងខែមីនា ២០១៥ និងលើកទី២ ក្នុងខែកក្កដា ២០១៥)។

រយៈពេលនេះរដ្ឋសភា មានរបៀបវារៈចំនួន២៩ ដែលរួមបញ្ចូលទាំងព្រះរាជសាររបស់ព្រះមហាក្សត្រជូនសម័យប្រជុំ ចំនួន២លើក និងរបាយការណ៍រាយការណ៍ប្រចាំចន្លោះសម័យប្រជុំចំនួន២លើក។ ក្នុងរបៀបវារៈទាំងអស់ របៀបវារៈចំនួន២៥ ត្រូវបានលើកមកពិភាក្សា និងអនុម័ត និងរួមទាំងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត និងការបោះឆ្នោតទម្លាក់ផង។ ក្នុងរបៀបវា រៈទាំង២៥នេះ រួមមានសេចក្តីស្នើច្បាប់ចំនួន០៧ សេចក្តីព្រាងច្បាប់ចំនួន១០ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន០៧លើក និងការបោះឆ្នោតទម្លាក់តំណែងចំនួន១លើក។

សេចក្តីស្នើច្បាប់ទាំង០៧ ដែលរដ្ឋសភាលើកមកពិភាក្សា និងអនុម័តរួមមាន៖ ១.សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ២.សេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ,

[2] មាត្រា ១៣៩ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

៣.សេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៣ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ, ៤.សេចក្តីស្នើច្បាប់ស្តីពីភតិកិច្ចសន្យាពិសេស, ៥.សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មមាត្រា២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា, ៦.សេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង៧.សេចក្តីស្នើវិសោធនកម្មប្រការ៣ថ្មី,៧ថ្មី,៨,១០ថ្មី(ពីរ),១៤ថ្មី,១៨,២០,២១,២២ថ្មី,៣១ថ្មី(ពីរ),៣៣ថ្មី,៣៤,៣៦ថ្មី,៣៨ថ្មី,៤០ថ្មី និងប្រការ៤៧ថ្មី(បី)នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

សេចក្តីព្រាងច្បាប់ទាំង១០ ដែលលើកមកពិភាក្សា និងអនុម័តរួមមានៈ ១.សេចក្តីព្រាងច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក, ២.សេចក្តីព្រាងច្បាប់ស្តីពី ការត្រួតពិនិត្យផលិតផលថ្នាំជក់, ៣.សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ, ៤.សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣, ៥.សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល, ៦.សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ២០១៥, ៧.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជណាកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ីស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ, ៨.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុសស្តីពីការជំរុញ និងការការពារទៅវិញទៅមក នៃវិនិយោគ, ៩.សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋបេឡារុស, ១០.សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣,៤,៥,២៦,២៧,២៨,៤២,៧៤ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា។

ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត និងជ្រើសតាំងមានចំនួន០៧លើក ដែលរួមមានៈ ការបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន១លើក, ការបោះឆ្នោតជ្រើសតាំងសមាភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន១លើក, ការបោះឆ្នោតទុកចិត្តលើតែងតាំង ឯកឧត្តម អ៊ុក សារាវុធ ជាអគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិចំនួន១លើក, ការបោះឆ្នោតជ្រើសតាំងសមាជិកសមាជិកានៃគណៈកម្មការជំនាញនៃរដ្ឋសភាចំនួន៣លើក និងការបោះឆ្នោតដកតំណែងជាអនុប្រធានទី១ នៃរដ្ឋសភាពីឯកឧត្តម កឹម សុខា ចំនួន១លើក។

ក្នុងរយៈពេលនេះ ការសង្កេតឃើញថា រដ្ឋសភាមិនមានជួបវិបត្តិខ្វះកូរ៉ុមសម្រាប់កិច្ចប្រជុំពេញអង្គរបស់ខ្លួននោះទេ បើទោះជាកិច្ចប្រជុំពេញអង្គមួយចំនួនត្រូវបានធ្វើពហិការមិនចូលរួមពីតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិក៏ដោយ។

### ២.១.១ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំរដ្ឋសភា

មិនខុសប្លែកពីរបាយការណ៍កន្លងមក ការសង្កេតជារួមឃើញថា ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រម្នាក់ៗ ធ្វើឡើងស្របទៅនឹងបន្ទាត់នយោបាយរបស់គណបក្សខ្លួន។ បើទោះជាមានការកត់សម្គាល់ថា ការបញ្ចេញមតិរបស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាក្នុងដើមនីតិកាលទី៥នេះ មានភាពខុសប្លែកពីរយៈពេលកន្លងមក ដោយតំណាងរាស្ត្រដែលបានឡើងបញ្ចេញមតិពេលនោះ បានជជែក និងសួរដេញដោលទៅលើតំណាងរាជរដ្ឋាភិបាល ដែលជាអ្នកការពារសេចក្តីព្រាងច្បាប់ ប៉ុន្តែក្នុងរយៈពេលនេះ ការបញ្ចេញមតិភាគច្រើនបានត្រឡប់មកដូចដើមវិញ ពោលគឺតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា បានចេញមុខការពារសេចក្តីព្រាងច្បាប់ជំនួសឱ្យតំណាងរាជរដ្ឋាភិបាល និងធ្វើការលើកសរសើរអំពីសេចក្តីព្រាងច្បាប់ក្នុងកំឡុងពេលពិភាក្សា និងអនុម័ត។

ការសង្កេតជាទូទៅឃើញថា មានតំណាងរាស្ត្រភាគច្រើននៅតែមិនបានឡើងបញ្ចេញមតិពិភាក្សាលើច្បាប់ ដោយស្ថិតនៅក្នុងស្ថានភាពស្ងប់ស្ងាត់ និងមិនសូវមានការបញ្ចេញមតិយោបល់ក្នុងការពិភាក្សានោះទេ។ តារាងខាងក្រោមនេះ បង្ហាញពីចំនួនតំណាងរាស្ត្រដែលឡើងបញ្ចេញមតិច្រើនជាងគេទាំង១០រូប ក្នុងកិច្ចប្រជុំកិច្ចប្រជុំពេញអង្គក្នុងរយៈពេលមួយឆ្នាំនេះ។

*តារាងទី១ តារាងអ្នកតំណាងរាស្ត្របានបញ្ចេញមតិច្រើនជាងគេ ១០រូប*

| ល.រ | ឈ្មោះតំណាងរាស្ត្រ | គណបក្ស | ចំនួនដង | ចំនួននាទី | | | |
|---|---|---|---|---|---|---|---|
| | | | | អញ្ជើញ | វិជ្ជមាន | អវិជ្ជមាន | សរុប |
| ១ | សុន ឆ័យ | | ២១ | ១៨៧ | ០ | ៧ | ១៩៤ |
| ២ | ឈាង វុន | | ១៥ | ៥៩ | ៤៧ | ៤ | ១១០ |
| ៣ | សម រង្ស៊ី | | ៨ | ៦៦ | ៧ | ០ | ៧៣ |
| ៤ | ហែម ខន | | ៥ | ៤៧ | ១០ | ០ | ៥៧ |
| ៥ | ជាម យៀប | | ៥ | ៣០ | ១៣ | ២ | ៤៥ |
| ៦ | ឡោក ខេង | | ៤ | ៣១ | ១៣ | ០ | ៤៤ |
| ៧ | យឹម សុវណ្ណ | | ៤ | ៥១ | ០ | ២ | ៥៣ |
| ៨ | ប៉ែន បញ្ញា | | ៤ | ១១ | ១៦ | ០ | ២៧ |
| ៩ | ហ៊ុន សែន | | ៣ | ៣៣ | ០ | ០ | ៣៣ |
| ១០ | ស ខេង | | ៣ | ១៨ | ០ | ០ | ១៨ |

### ២.១.២ ការបញ្ចេញមតិជាបរិមាណរបស់អ្នកតំណាងរាស្ត្រក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា

រយៈពេល១ឆ្នាំនេះ មានអ្នកតំណាងរាស្ត្រសរុបចំនួន ៤៣រូប មកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានឡើងបញ្ចេញមតិក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា ដោយប្រើប្រាស់រយៈពេលសរុប ១១៩៩នាទី (ស្មើនឹង ១៩ម៉ោង ៥៩នាទី)។ បើជាមធ្យមក្នុងតំណាងរាស្ត្រ១រូប បានបញ្ចេញមតិបានប្រមាណ ២៨នាទី។

តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន ២១រូប នៃតំណាងរាស្ត្រសរុបនៃគណបក្សនេះ ៦៨រូប បានឡើងបញ្ចេញមតិ ដោយប្រើរយៈពេលសរុបចំនួន ៥១០នាទី (ស្មើនឹង៨ម៉ោង៣០នាទី)។ រីឯតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំនួន ២២រូប នៃតំណាងរាស្ត្រសរុបនៃគណបក្សនេះ ៥៥រូប បានឡើងបញ្ចេញមតិសរុបចំនួនថ ៦៨៩នាទី (ស្មើនឹង ១១ម៉ោង ២៩នាទី)។

*ក្រាហ្វិកទី១៖ចំនួនតំណាងរាស្ត្រ និងរយៈពេលបញ្ចេញមតិតាមគណបក្ស*




ការបញ្ចេញមតិរបស់តំណាងរាស្ត្រគិតជាបរិមាណ ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាសម្រាប់របាយការណ៍ឆ្នាំទី២ នៃរដ្ឋសភានីតិកាលទី៥នេះ ឃើញថា ការបញ្ចេញមតិមានការប្រជុំប្រសងគ្នា ដោយអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន ២១រូប បានឡើងបញ្ចេញមតិ ហើយអ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះ ចំនួន ២២រូប បានឡើងបញ្ចេញមតិ។

តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាមានចំនួន២១រូប ស្មើនឹង៣១% នៃចំនួនតំណាងរាស្ត្រសរុបរបស់គណបក្សនេះ បានបញ្ចេញមតិសរុបចំនួន៥១០នាទី (ស្មើនឹង៤៣% នៃរយៈពេលសរុប)។ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមានចំនួន២២រូប ស្មើនឹង៤០% នៃចំនួនតំណាងរាស្ត្រសរុបរបស់គណបក្សនេះ បានបញ្ចេញមតិសរុបចំនួន៦៨៩នាទី (ស្មើនឹង ៥៧% នៃរយៈពេលសរុប)។

### ២.១.៣ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុប

ខ្លឹមសារមតិរបស់អ្នកតំណាងរាស្ត្រដែលបានបញ្ចេញនៅក្នុងអំឡុងពេលប្រជុំពេញអង្គ ត្រូវបានវិភាគដោយបែងចែកជាបីសូរ(TONE) គឺ៖ អព្យាក្រឹត្យ វិជ្ជមាន និងអវិជ្ជមាន ចំពោះស្ថាប័ន របៀបវារៈ ឬតួអង្គ/ស្ថាប័នរដ្ឋាភិបាលណាមួយដែលអ្នកតំណាងរាស្ត្រនិយាយសំដៅទៅ។ ខ្លឹមសារអព្យាក្រឹត្យ គឺសំដៅលើមតិធម្មតាទៅលើតួអង្គ ឬស្ថាប័នណាមួយ។ ចំណែកឯវិជ្ជមាន គឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិសេចក្តីព្រាងច្បាប់គោលនយោបាយ ឬតួអង្គ ឬស្ថាប័នណាមួយ។ រីឯអវិជ្ជមានវិញ គឺនិយាយពីគុណវិបត្តិរបស់តួអង្គ ឬស្ថាប័នណាមួយ។

ក្នុងរយៈពេលនេះ មានតំណាងរាស្ត្រចំនួន៤៣រូប បានបញ្ចេញមតិដោយប្រើពេលវេលាសរុបចំនួន១១៩៩នាទី (ស្មើនឹង១៩ម៉ោង៥៩នាទី)។ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាក្នុងរបាយការណ៍ឆ្នាំទី១ឃើញថា រយៈពេលសរុបនៃការបញ្ចេញមតិមានការកើនឡើងច្រើន ដែលក្នុងពេលនោះតំណាងរាស្ត្របានឡើងបញ្ចេញមតិ ដោយប្រើប្រាស់រយៈពេលសរុបចំនួន ៦៩៣នាទី (ស្មើនឹង១១ម៉ោង៣៣នាទី) ប៉ុណ្ណោះ។ ចំណែកឯខ្លឹមសារនៃបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រវិញ ខុមហ្វ្រែលអង្កេតឃើញថា ខ្លឹមសារនៃការបញ្ចេញមតិមិនខុសពីខ្លឹមសារបញ្ចេញមតិឆ្នាំមុននោះទេ ពោលខ្លឹមសារបញ្ចេញមតិគឺ ផ្តោតលើខ្លឹមសារអព្យាក្រឹត្យ និងវិជ្ជមាន។ ក្នុងនោះខ្លឹមសារបែបអព្យាក្រឹត្យមានចំនួន១០១៥នាទី ខ្លឹមសារវិជ្ជមាន១៥៥នាទី ចំណែកឯខ្លឹមសារអវិជ្ជមាន២៩នាទី។

### ២.១.៤ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រធៀបនឹងរយៈពេលសរុបតាមគណបក្ស

ការសង្កេតឃើញថា ខ្លឹមសារនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា គឺផ្តោតទៅលើខ្លឹមសារបែបអព្យាក្រឹត្យ និងបែបវិជ្ជមាន។ ដោយឡែក តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិវិញ ខ្លឹមសារនៃការបញ្ចេញមតិ គឺផ្តោតភាគច្រើនទៅលើខ្លឹមសារបែបអព្យាក្រឹត្យ។

*ក្រាហ្វិកទី២៖ ចំនួននាទីនិងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន របស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា*




ក្រាហ្វិកនេះបង្ហាញថា តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាធ្វើការបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យចំនួន៣៦៣នាទី ស្មើនឹង៧១%នៃ រយៈពេលសរុបរបស់គណបក្សខ្លួន។ ខ្លឹមសារវិជ្ជមានចំនួន១៤១នាទី ស្មើនឹង២៨% នៃរយៈពេលសរុប ហើយខ្លឹមសារអវិជ្ជមានចំនួន០៦នាទី ស្មើនឹង១% នៃរយៈពេលសរុបរបស់គណបក្សខ្លួន។

*ក្រាហ្វិកទី៣៖ ចំនួននាទី និងភាគរយការបញ្ចេញមតិ អព្យាក្រឹត្យ វិជ្ជមាន អវិជ្ជមាន របស់អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ*

ក្រាហ្វិកនេះបង្ហាញថា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិធ្វើការបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យចំនួន៦៥២នាទី ស្មើនឹង៩៥% នៃរយៈពេលសរុបរបស់គណបក្សខ្លួន។ រីឯខ្លឹមសារក្នុងន័យអវិជ្ជមានវិញមានចំនួន២៣នាទី ស្មើនឹង៣% នៃរយៈពេលសរុប ហើយខ្លឹមសារក្នុងន័យវិជ្ជមានចំនួន១៤នាទី ស្មើនឹង២% នៃរយៈពេលសរុបរបស់គណបក្សខ្លួន។




## ២.១.៥ ខ្លឹមសារនៃការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រតាមគណបក្សទៅលើតួអង្គស្ថាប័ន និងចំណុចផ្សេងៗ

តារាងខាងក្រោមនេះ បានបង្ហាញពីខ្លឹមសារការបញ្ចេញមតិរបស់តំណាងរាស្ត្រតាមគណបក្ស ទៅលើតួអង្គ ឬស្ថាប័ននានានៅក្នុងសម័យប្រជុំពេញអង្គទាំង២១កិច្ចប្រជុំ។ អ្នកតំណាងរាស្ត្របានបញ្ចេញមតិក្នុងខ្លឹមសារបែបអព្យាក្រឹត្យ អវិជ្ជមាន និងវិជ្ជមាន។

*តារាងទី២៖ខ្លឹមសារនៃការបញ្ចេញមតិរបស់តំណាងរាស្ត្រតាមគណបក្សនយោបាយទាំងបីចំណុចសំខាន់ៗ (គិតជានាទី)*

| ល.រ | ចំណុចដែលពាក់ព័ន្ធ | គណបក្សប្រជាជនកម្ពុជា | | | គណបក្សសង្គ្រោះជាតិ | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | អព្យាក្រឹត្យ | វិជ្ជមាន | អវិជ្ជមាន | អព្យាក្រឹត្យ | វិជ្ជមាន | អវិជ្ជមាន | |
| ១ | របៀបវារៈកំពុងពិភាក្សា | ២០២ | ១១៥ | ០ | ៣៦០ | ៩ | ៨ | ៦៩៤ |
| ២ | នាយករដ្ឋមន្ត្រី | ៦ | ៥ | ០ | ៧ | ០ | ០ | ១៨ |
| ៣ | រាជរដ្ឋាភិបាល | ៧៥ | ១៩ | ០ | ១៦៦ | ២ | ១៣ | ២៧៥ |
| ៤ | ប្រធានរដ្ឋសភា | ០ | ០ | ០ | ១ | ០ | ០ | ១ |
| ៥ | រដ្ឋសភា | ៧ | ០ | ០ | ១៥ | ០ | ០ | ២២ |
| ៦ | គណៈកម្មការនានារបស់រដ្ឋសភា | ១០ | ០ | ០ | ៥ | ១ | ២ | ១៨ |
| ៧ | ប្រធានព្រឹទ្ធសភា | ០ | ០ | ០ | ១ | ០ | ០ | ១ |
| ៨ | ស្ថាប័នព្រឹទ្ធសភា និងសមាជិក | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៩ | គណបក្សខ្លួនគាត់ | ៣ | ១ | ០ | ០ | ១ | ០ | ៥ |
| ១០ | គណបក្សដទៃទៀត | ៦ | ០ | ២ | ០ | ០ | ០ | ៨ |
| ១១ | តំណាងរាស្ត្រខ្លួនឯង | ១ | ១ | ០ | ០ | ០ | ០ | ២ |
| ១២ | តំណាងរាស្ត្រដទៃទៀត | ១៣ | ០ | ៤ | ០ | ០ | ០ | ១៧ |
| ១៣ | មណ្ឌល(ខេត្ត/រាជធានី)របស់គាត់ | ០ | ០ | ០ | ០ | ០ | ០ | ០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៤ | មណ្ឌល (ខេត្ត/រាជធានី) ផ្សេងទៀត | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ១៥ | តុលាការ | 0 | 0 | 0 | ២ | 0 | 0 | ២ |
| ១៦ | បញ្ហាស្ត្រី | 0 | 0 | 0 | ៥ | 0 | 0 | ៥ |
| ១៧ | អនុសាសន៍លើច្បាប់កំពុងពិភាក្សា | ៥ | 0 | 0 | ៤ | 0 | 0 | ៩ |
| ១៨ | សំណួរ/សុំការបំភ្លឺលើច្បាប់កំពុង | ៣ | 0 | 0 | ២៤ | 0 | 0 | ២៧ |
| ១៩ | យុវជន | 0 | 0 | 0 | ២ | 0 | 0 | ២ |
| ២០ | បញ្ហាផ្សេងៗ | ៣២ | 0 | 0 | ៦០ | ១ | 0 | ៩៣ |
| សរុប | | ៣៦៣ | ១៤១ | ៦ | ៦៥២ | ១៤ | ២៣ | |
| | | **៥១០** | | | **៦៨៩** | | | **១១៩៩** |

ក្នុងរយៈពេលនេះ ការសង្កេតឃើញថា ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយទាំងពីរផ្តោតសំខាន់ទៅលើចំណុចពាក់ព័ន្ធចំនួន៣ ដែលបានចំណាយរយៈពេលច្រើនជាងគេ ក្នុងចំណោមតួអង្គ និងស្ថាប័នទាំង២០។ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្របានផ្តោតខ្លាំងទៅលើ ការផ្តល់ជាអនុសាសន៍លើរបៀបវារៈកំពុងពិភាក្សា និងតួអង្គរាជរដ្ឋាភិបាល ដែលត្រូវបានក្រុមអ្នកតំណាងរាស្ត្រចំណាយរយៈពេលបញ្ចេញមតិសរុប៩៧០នាទី ឬ១៦ម៉ោង១៦នាទី (ស្មើនឹង៨០% នៃរយៈពេលនៃការបញ្ចេញមតិសរុប)។

ការបញ្ចេញមតិរបស់តំណាងរាស្ត្រដោយផ្តោតលើអនុសាសន៍ចំពោះសេចក្តីស្នើ ឬសេចក្តីព្រាងច្បាប់ ដែលកំពុងពិភាក្សា ត្រូវបានអ្នកតំណាងរាស្ត្រចំណាយរយៈពេលអស់៦៩៤នាទី ស្មើនឹង៥៧% នៃចំនួនរយៈពេលបញ្ចេញមតិសរុប។ ការបញ្ចេញមិត ដែលពាក់ព័ន្ធនឹងរាជរដ្ឋាភិបាល គឺសំដៅទៅលើតួអង្គរាជរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាល ត្រូវបានតំណាងរាស្ត្រចំណាយរយៈពេលអស់២៧៥នាទី ស្មើនឹង២៣% នៃរយៈពេលបញ្ចេញមតិសរុប។

ការបញ្ចេញមតិរបស់តំណាងរាស្ត្រ ជុំវិញការបញ្ចេញមតិទៅលើរបៀបវារៈកំពុងពិភាក្សា តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាបានបញ្ចេញមតិ ក្នុងន័យអព្យាក្រឹត្យចំនួន២០២នាទី ហើយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិបានបញ្ចេញមតិចំនួន៣៦០នាទី។ ពាក់ព័ន្ធនឹងស្ថាប័នរាជរដ្ឋាភិបាល ត្រូវបានតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាបញ្ចេញមតិផ្តោតទៅលើខ្លឹមសារអព្យាក្រឹត្យបានចំនួន៧៥នាទី ហើយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិបានបញ្ចេញមតិក្នុងន័យអព្យាក្រឹត្យបានចំនួន១៦៦នាទី។

### ២.១.៦ តារាងសេចក្តីព្រាង/សេចក្តីស្នើច្បាប់សំខាន់ៗ ដែលរដ្ឋសភាបានអនុម័ត ហើយបន្សល់នូវភាពចម្រូងចម្រាស

ក្នុងឆ្នាំ២០១៥នេះ មានសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន១៧ ត្រូវបានអនុម័តដោយរដ្ឋសភា ក្នុងនោះមានសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន៤ ត្រូវបានរដ្ឋសភាធ្វើការអនុម័ត ដែលបន្សល់នូវភាពចម្រូងចម្រាសជាច្រើន ព្រោះថា ច្បាប់ទាំងនោះទទួលរងការរិះគន់ពីភាគីពាក់ព័ន្ធ ដោយខ្លឹមសារនៃមាត្រាមួយចំនួនមិនច្បាស់លាស់ ប៉ះពាល់ដល់សិទ្ធិសេរីភាពភាគីពាក់ព័ន្ធ និងការផ្តន្ទាទោសមិនសមហេតុផលជាដើម។

សេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ទាំង ៤នោះរួមមានៈ ១.សេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ, ២.សេចក្តីស្នើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការជាតិរៀបចំការបោះឆ្នោត, ៣.សេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ និង៤.សេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

*តារាងទី៣៖ តារាងសេចក្តីព្រាង/សេចក្តីស្នើច្បាប់សំខាន់ៗ ដែលរដ្ឋសភាបានអនុម័ត ហើយបន្សល់នូវភាពចម្រូងចម្រាស*

| ល.រ | សេចក្តីព្រាង/សេចក្តីស្នើច្បាប់ | ថ្ងៃខែពិភាក្សា និងអនុម័ត | រយៈពេលពិភាក្សា | សំឡេងអនុម័ត | កំណត់សម្គាល់ |
|---|---|---|---|---|---|
| ១ | សេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ១៩ មិនា ២០១៥ | ១ព្រឹក | ១០៣/១០៣ | - គ្មានការពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភា។<br>- ទទួលរងការរិះគន់ពីសហគមន៍ជាតិ និងអន្តរជាតិថា ការកែប្រែថ្មីក្នុងសេចក្តីស្នើច្បាប់មានភាពអាក្រក់ជាងច្បាប់ចាស់។ |
| ២ | សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | | | ១០៣/១០៣ | |
| ៣ | សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល | ១៣ កក្កដា ២០១៥ | ១ព្រឹក | ៦៨/៦៨ | - តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិពហិការមិនចូលរួមអនុម័ត និងអំពាវនាវឲ្យរដ្ឋសភាជាតិទម្លាក់ចោលការអនុម័ត។<br>- ទទួលរងការរិះគន់ពីសហគមន៍ជាតិ និងអន្តរជាតិ ព្រោះវាបានរឹតត្បិតសិទ្ធិសេរីភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។<br>- មានការទាមទារពីក្រុមអង្គការសង្គមស៊ីវិលទម្លាក់ចោលការអនុម័ត និងស្នើមានការពិគ្រោះយោបល់បន្ថែមទៅលើខ្លឹមសារដែលប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ខ្លួន។ |
| ៤ | សេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ | ៣០ តុលា ២០១៥ | ១ព្រឹក | ៦៧/៦៧ | - មិនមានតំណាងរាស្ត្រណាមួយឡើងបញ្ចេញមតិលើសេចក្តីព្រាងច្បាប់នោះទេ ដោយហេតុថា សេចក្តីព្រាងច្បាប់នេះត្រូវបានស្នើឡើងដោយក្រុមអ្នកតំណាងរាស្ត្រផ្ទាល់។<br>- មិនមានវត្តមានរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សប្រឆាំងនោះទេ។ |

## ២.២ ការប្រជុំរបស់គណៈកម្មការជំនាញ/ប្រជុំដេញដោល ឬការឆ្លើយបំភ្លឺ

ឆ្នាំទី២នៃនីតិកាលទី៥នេះ ខុមហ្វ្រែលសង្កេតឃើញថា គណៈកម្មការជំនាញនៃរដ្ឋសភាមានសកម្មភាពគួរឲ្យកត់សំគាល់ក្នុងការបំពេញការងារតាមជំនាញការងារ/ការទទួលបន្ទុកវិស័យរបស់គណៈកម្មការសាមី។ រយៈពេលពេលនេះ គណៈកម្មការជំនាញនៃរដ្ឋសភាបានធ្វើសកម្មភាពការងារតាមវិស័យទទួលបន្ទុករបស់ខ្លួនមានចំនួន១០៥លើក ដែលក្នុងនោះគណៈកម្មការជំនាញដឹកនាំដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមានសកម្មភាពចំនួន៦៦លើក ហើយគណៈកម្មការជំនាញដឹកនាំដោយតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាមានសកម្មភាពចំនួន៣៩លើក។ ក្នុងចំណោមសកម្មភាពទាំងនោះ គណៈកម្មការទី១មានចំនួន១៥លើក, គណៈកម្មការទី២ចំនួន០៦លើក, គណៈកម្មការទី៣ចំនួន២០លើក, គណៈកម្មការទី៤ចំនួន ០៧លើក, គណៈកម្មការទី៥ចំនួន១៥លើក, គណៈកម្មការទី៦ចំនួន៥លើក, គណៈកម្មការទី៧ចំនួន១៥លើក, គណៈកម្មការទី៨ចំនួន១០លើក, គណៈកម្មការទី០៩ចំនួន០៦លើក និងគណៈកម្មការទី១០ចំនួន៦លើក។

ក្នុងរយៈពេលនេះដែរ ការសង្កេតឃើញថា រដ្ឋមន្ត្រីចំនួន៨រូប រួមមាន រដ្ឋមន្ត្រីក្រសួងបរិស្ថាន, រដ្ឋមន្ត្រីក្រសួងផែនការ, រដ្ឋមន្ត្រីក្រសួងសុខាភិបាល, រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា, រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, រដ្ឋមន្ត្រីក្រសួងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវបានកោះហៅមកបំភ្លឺដោយផ្ទាល់មាត់នៅក្នុងគណៈកម្មការជំនាញនៃរដ្ឋសភា និងនៅសាមីក្រសួងផ្ទាល់។ ជាមួយគ្នានេះ ក៏មានការជួបពិភាក្សាការងារជាមួយក្រុមអង្គការសង្គមមិនមែនរដ្ឋាភិបាលមួយចំនួនផងដែរ។

ក្នុងចំណោមសកម្មភាពទាំង១០៥[3] ដែលគណៈកម្មការជំនាញនៃរដ្ឋសភាបានធ្វើរួមមានៈ ការកោះអញ្ជើញរដ្ឋមន្ត្រីបំភ្លឺក្នុងគណៈកម្មការជំនាញ, ចុះជួបពិភាក្សានៅសាមីក្រសួង/មន្ទីរ និងវិស័យពាក់ព័ន្ធ, សកម្មភាពទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ, និងការចុះជួបពិភាក្សាការងារជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីពិនិត្យ និងស្វែងយល់ពីបញ្ហា និងកង្វល់នានា និងព្រមទាំងចុះទៅដល់កន្លែងដែលមានទំនាស់ផ្សេងៗ ពិសេសបញ្ហាទំនាស់ដីធ្លី។

ការសង្កេតឃើញថា គណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សសង្គ្រោះជាតិបានធ្វើសកម្មភាពការងារច្រើនជាងគណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ពិសេសសកម្មភាពការកោះហៅរដ្ឋមន្ត្រីមកបំភ្លឺនៅក្នុងគណៈកម្មការជំនាញ និងការចេញមកទទួលយកញត្តិពីប្រជាពលរដ្ឋ ការចុះពិនិត្យ និងដោះស្រាយករណីទំនាស់នានា (ទំនាស់ដីធ្លី) របស់ប្រជាពលរដ្ឋ។

ជាក់ស្តែង គណៈកម្មការជំនាញទី១ នៃរដ្ឋសភាដឹកនាំដោយឯកឧត្តម អេង ឆៃអ៊ាង បានធ្វើសកម្មភាពកោះអញ្ជើញរដ្ឋមន្ត្រី២រូប គឺរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តម សាយ សំអាល់ បំភ្លឺជុំវិញករណីទំនាស់ដីធ្លីផ្សេងៗដែលស្ថិតក្រោមបន្ទុកដោះស្រាយរបស់ក្រសួង ពិសេសរឿងទំនាស់ដីធ្លី នៅស្រុកបទុមសាគរ និងស្រុកគិរីសាគរ ខេត្តកោះកុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឯកឧត្តម អ៊ឹម ឈុនលឹម មកបំភ្លឺអំពីលទ្ធផលនៃការដោះស្រាយទំនាស់ដីធ្លី ដែលទាក់ទងនឹង វិស័យទទួលខុសត្រូវក្រសួងនៅវិមានរដ្ឋសភា។ គណៈកម្មការនេះ ក៏បានចុះបេកសកម្មដើម្បីពិនិត្យ អង្កេត ស្រាវជ្រាវពីករណីទំនាស់ដីធ្លីក្នុងខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ រវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនវិនិយោគចំការកៅស៊ូ Co.LTD ក្រុមហ៊ុនយូប៊ីអ៊ីឌីវេឡុបមេន ក្រុមហ៊ុនដាយណាម ក្រុមហ៊ុនកាសូទឹម និងក្រុមហ៊ុនដួងទៀងក្រចេះ វ៉ាប់ប៊េរីឌីវេឡុបមេនលីមីធីត។ លើសពីនេះ គណៈកម្មការចុះអង្កេតលើករណីបញ្ហាជម្លោះដីធ្លីចំនួន១៧ករណី ក្នុងស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងក្រុងព្រះសីហនុ ក្នុងខេត្តព្រះសីហនុ ដោយបានជួបប្រជាពលរដ្ឋនរស់នៅក្នុងតំបន់ទំនាស់ទាំងនោះ និងបានពិនិត្យទីតាំងដីទំនាស់ និងព្រមទាំងជួបពិភាក្សាជាមួយ ឯកឧត្តម ឈិត សុខុន អភិបាលខេត្តព្រះសីហនុ រួមទាំងអាជ្ញាធរថ្នាក់ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ដើម្បីរកដំណោះស្រាយ។ ការសង្កេតឃើញថា មានការឆ្លើយភ្លាមៗពីអាជ្ញាធរខេត្ត ដោយបានដោះស្រាយជូនប្រជាពលរដ្ឋដែលមានទំនាស់នៅស្ពានឆេះអូរត្រេះ តាមរយៈការចាប់ឆ្នោតដីសម្បទានសង្គមកិច្ច។

ដោយឡែក ទំនាស់ដីធ្លីដំរាំរ៉ៃនៅភូមិឡពាង ខេត្តកំពង់ឆ្នាំង គណៈកម្មការទី១ បានបន្តសម្របសម្រួលស្វែងរកដោះស្រាយ ដោយបានចុះផ្ទាល់ទៅទីតាំងទំនាស់ចំនួន៧លើក និងជួបនៅភ្នំពេញចំនួន៥លើក។ គណៈកម្មការក៏បានចុះជួបប្រជាពលរដ្ឋមានទំនាស់ដីធ្លី ក្នុងភូមិកំពង់អូស ស្រុកពញាឮ ខេត្តកណ្តាល ជាមួយក្រុមហ៊ុនឧកញ៉ា អេង ឌីប៉ូ អភិវឌ្ឍន៍ ដើម្បីធ្វើការអង្កេត ប្រមូលព័ត៌មានទាំងសងខាង និងឈានទៅរកដំណោះស្រាយ។

ទន្ទឹមគ្នានេះ គណៈកម្មការជំនាញទី៣នៃរដ្ឋសភា ដឹកនាំដោយ ឯកឧត្តម ប៉ុល ហំម បានអញ្ជើញឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការ មកបំភ្លឺពីកិច្ចដំណើរការការងារ និងបញ្ហាប្រឈមផ្សេងៗរបស់ក្រសួងផែនការ។ ជួបពិភាក្សាការងារ

[3] មិនរាប់បញ្ចូលនូវកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ និងសកម្មភាពក្រៅប្រទេស

ជាមួយឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ឯកឧត្តម សាយ សំអាល់រដ្ឋមន្ត្រីក្រសួងបរិស្ថានដើម្បីស្វែងយល់លទ្ធផលការងាររបស់ក្រសួងសាមីក្នុងវិស័យទទួលបន្ទុករបស់គណៈកម្មការ។ ជាងនេះទៅទៀត គណៈកម្មការនេះក៏បានជួបពិភាក្សាការងារជាមួយក្រុមអង្គការសង្គមស៊ីវិលរួមមាន វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum)។ លើសពីនេះ គណៈកម្មការក៏បានចុះជួបថ្នាក់ដឹងនាំខេត្តបន្ទាយមានជ័យដើម្បីពិនិត្យ និងសិក្សាបញ្ហាកើតមាននៅក្នុងខេត្តពិសេសគឺគ្រោះរាំងស្ងួត ដែលខេត្តទទួលរងផលប៉ះពាល់លើទំហំដីផ្ទៃដីជិត២៣ពាន់ហិកតា និងចុះពិនិត្យសង្វាក់ការងារ នៅក្នុងរោងចក្រកាត់ដេរធីខេហ្កាមិន ដែលមានទីតាំងស្ថិតនៅក្នុងក្រុងសេរីសោភ័ណ្ឌផងដែរ។

គណៈកម្មការជំនាញទី៧នៃរដ្ឋសភាដឹកនាំដោយឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ បានអញ្ជើញរដ្ឋមន្ត្រីចំនួន ៤រូប មកបំភ្លឺផ្ទាល់មាត់ក្នុងគណៈកម្មការ ដែលរួមមានឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍, ឯកឧត្តម ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា, ឯកឧត្តម មិន ឃិន រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងលោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីបំភ្លឺពាក់ព័ន្ធមរណីយដ្ឋានភ្នំបូកគោ។ គណៈកម្មការក៏បានកោះអញ្ជើញឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ដឹកនាំសហការីមកបំភ្លឺ អំពីតំបន់ឆ្នេរសាធារណៈ និងសហគមន៍ទេសចរណ៍ផងដែរ។ ជាងនេះទៅទៀត ក្រៅពីសកម្មភាពអញ្ជើញរដ្ឋមន្ត្រី គណៈកម្មការនេះក៏បានចុះទៅតាមសកលវិទ្យាល័យ និងជួបមន្ត្រីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានដើម្បីស្វែងយល់អំពីការបំពេញភារកិច្ចការក្នុងវិស័យទទួលបន្ទុក។

គណៈកម្មការទី០៨ដឹកនាំដោយលោកជំទាវ កែ សុវណ្ណរតន៍ បានជួបពិភាក្សាជាមួយ ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលអំពីការងារក្នុងវិស័យពាក់ព័ន្ធ។ លើសពីនេះ គណៈកម្មការក៏បានចុះបំពេញបេសកកម្មនៅខេត្តតាកែវ ដើម្បីពិនិត្យ សិក្សាស្វែងយល់ការងារក្នុងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ និងជួបពិភាក្សាជាមួយថ្នាក់ដឹកនាំខេត្ត មន្ទីរពាក់ព័ន្ធក្នុងខេត្ត និងស្នើដល់អាជ្ញាធរ និងមន្ទីរជំនាញពាក់ព័ន្ធវិស័យសុខាភិបាលក្នុងខេត្តនេះ ត្រួតពិនិត្យគ្លីនិក ឬកន្លែងព្យាបាលជំងឺឯកជន ដែលពុំទាន់មានច្បាប់អនុញ្ញាតត្រឹមត្រូវឲ្យទៅសុំច្បាប់ប្រកបអាជីវកម្ម ដើម្បីធានាដល់ការព្យាបាលជំងឺប្រជាពលរដ្ឋមានប្រសិទ្ធភាព និងមានការទទួលខុសត្រូវ។

ដោយឡែក គណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាមានសកម្មភាពដូចជាៈ គណៈកម្មការជំនាញទី២ នៃរដ្ឋសភាដឹកនាំដោយ ឯកឧត្តម ជាម យៀប បានជួបពិភាក្សាការងារជាមួយអង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងវិស័យជំនាញរបស់ខ្លួន។ ជាក់ស្តែងបានជួបពិញភាក្សាការងារជាមួយ លោក មុំ គង់ នាយកប្រតិបត្តិអង្គការសម្ព័ន្ធដើម្បីសុខភាពកម្ពុជា ក្នុងគោលបំណងស្វែងយល់ពីសេចក្តីព្រាងច្បាប់ស្តីពីផលិតផលថ្នាំជក់ នៅវិមានរដ្ឋសភា។

គណៈកម្មការជំនាញទី៤ នៃរដ្ឋសភាដឹកនាំដោយឯកឧត្តម ហ៊ុន ណេង បានជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនៅទីស្តីការក្រសួង ដើម្បីស្វែងយល់ពីលទ្ធផលការងារ និងផលលំបាករបស់ក្រសួងថ្មី។ ជាងនេះទៅទៀត គណៈកម្មការនេះ បានចុះបំពេញបេសកកម្មការងារនៅតាមបណ្តាខេត្តមួយចំនួនរួមមានៈ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តកោះកុង ដើម្បីសិក្សាស្វែងយល់ពីការងារពាក់ព័ន្ធ និងភារកិច្ចទទួលបន្ទុករបស់គណៈកម្មការ។

គណៈកម្មការទី៥ ដឹកនាំដោយឯកឧត្តម ឈាង វុន បានជួបពិភាក្សាការងារជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីស្វែងយល់ពីកិច្ចការងារ និងលទ្ធផលការងារដែលស្ថិតក្នុងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ។ ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីស្វែងយល់ពីទុក្ខលំបាក និងចែករំលែកព័ត៌មានអំពីស្ថានការណ៍នយោបាយ ។ ជាក់ស្តែង គណៈកម្មការនេះ បានចុះជួបជាមួយអភិបាលខេត្តបាត់ដំបង និងមន្ត្រីពាក់ព័ន្ធ ដើម្បីពិភាក្សាការងារ និងស្តាប់បទបង្ហាញពីការដោះ

ស្រាយទំនាស់ដីធ្លីនៅភូមិបឹងប្រាំ និងនៅស្រុកគាស់ក្រឡ។ ជាងនេះទៅទៀត គណៈកម្មការបានចុះជួបសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះឆ្លងជំងឺអេដស៍នៅភូមរកា ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង និងបានចុះសួរសុខទុក្ខកងទ័ពនៅតាមបណ្តាព្រំដែនខេត្តព្រះវិហារ និងឧត្តរមានជ័យដែលកំពុងបំពេញភារកិច្ចការពារតាមបណ្តាព្រំដែនកម្ពុជា ថៃ។ គណៈកម្មការនេះ ក៏បានធ្វើវេទិកាប្រចាំខែនៃអ្នកនាំពាក្យរដ្ឋសភានៅវិមានរដ្ឋសភា ដើម្បីបង្ហាញពីការងាររបស់រដ្ឋសភាដែលបានធ្វើ។ គណៈកម្មការក៏បានចូលរួមរួមផ្សព្វផ្សាយសភាពការណ៍នយោបាយជូនថ្នាក់មូលដ្ឋាននៅសាលាស្រុកថ្មគោល ខេត្តបាត់ដំបង និងចូលរួមជាវាគ្មិនក្នុងការធ្វើបទបង្ហាញ ស្តីពីភូមិសាស្ត្រនយោបាយដើម្បីការសម្រេចត្រឹមត្រូវ និងវិស័យការទូតសភាជូនសិស្ស និស្សិតនៅសកលវិទ្យាល័យបាត់ដំបងផងដែរ។

គណៈកម្មការជំនាញទី៦នៃរដ្ឋសភាដឹកនាំដោយឯកឧត្តម ប៉ែន បញ្ញា បានបំពេញបេសកកម្មនៅតាមបណ្តាខេត្តមួយចំនួនដើម្បីសិក្សាស្វែងយល់ពីការអនុវត្តន៍ច្បាប់នៅតាមបណ្តាខេត្តទាំងនោះ។ ជាក់ស្តែងគណៈកម្មការ បានចុះបេសកម្មទៅខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ដើម្បីសិក្សាស្វែងយល់ពីការអនុវត្តន៍ច្បាប់ និងការប្រព្រឹត្តិទៅនៃប្រពន្ធ័តុលាការក្នុងខេត្តទាំងពីរនេះ និងបន្តចុះទៅខេត្តព្រះសីហនុ និងខេត្តកោះកុង ដើម្បីស្វែងយល់ពីការអនុវត្តច្បាប់ និងវិស័យយុត្តិធម៌។

គណៈកម្មការជំនាញទី៩នៃរដ្ឋសភាដឹកនាំដោយ លោកជំទាវ និន សាផុន បានចុះជួបអាជ្ញាធរខេត្ត ដើម្បីពិភាក្សាការងារ និងស្វែងយល់ពីការងារក្នុងខេត្ត ដែលវិស័យពាក់ព័ន្ធនឹងការទទួលខុសត្រូវគណៈកម្មការ និងចុះពិនិត្យសមិទ្ធផលនានាក្នុងមូលដ្ឋាន។ ជាក់ស្តែង គណៈកម្មការ បានចុះបេសកម្មចុះពិនិត្យសមិទ្ធផលនានាក្នុងមូលដ្ឋានខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ដោយចុះពិនិត្យមើលការសាងសង់ស្ពានបានផ្លូវ និងទីតាំងក្រុមហ៊ុនចិនដែលកំពុងធ្វើអាជីវកម្មរុករករ៉ែមាសស្ថិតនៅក្នុងស្រុកភ្នំព្រឹក។ ជាងនេះទៀត គណៈកម្មការបានចុះបេសកម្មទៅខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ដើម្បីជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត មន្ទីរនានាក្នុងខេត្តដែលទាក់ទងនឹងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ។

ការសង្កេតជារួមឃើញថា គណៈកម្មការជំនាញនៃរដ្ឋសភា ដែលដឹកនាំដោយគណបក្សសង្គ្រោះជាតិភាគច្រើន មានសកម្មភាពកោះហៅរដ្ឋមន្ត្រីមកបំភ្លឺ ខណៈដែលគណៈកម្មការជំនាញដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា សកម្មភាពភាគច្រើន គឺការជួបជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីស្វែងយល់ពីការងារទាក់ទងក្នុងវិស័យទទួលខុសត្រូវរបស់គណៈកម្មការ។

## III. សកម្មភាពចុះមូលដ្ឋាន និងបុគ្គការិយាល័យតំណាងរាស្ត្រ

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ។[4] រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានថេរៈវេលាយ៉ាងតិចបីខែ។[5] ដូច្នេះក្នុងចន្លោះសម័យប្រជុំដែលជារយៈពេលរដ្ឋសភាវិស្សមកាល អ្នកតំណាងរាស្ត្របានយកពេលនោះចុះមូលដ្ឋានដើម្បីជួបសំណេះសំណាល និងដោះស្រាយបញ្ហានានារបស់ម្ចាស់ឆ្នោត។

របាយការណ៍សម្រាប់ឆ្នាំទី២ គិតចាប់ពី ខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ខែតុលា ឆ្នាំ២០១៥ តាមទិន្នន័យខុមហ្វ្រែលទទួលបានពីបណ្តាញរបស់ខ្លួនតាមរយៈការចុះសង្កេតដោយផ្ទាល់អំពីសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ពីប្រព័ន្ធផ្សព្វផ្សាយ ពីការិយាល័យតំណាងរាស្ត្រតាមបណ្តាខេត្ត និងពីស្នាក់ការគណបក្សនយោបាយនៅតាមបណ្តាខេត្តឃើញថា មានតំណាងរាស្ត្រចំនួន៩១រូប ក្នុងចំណោមតំណាងរាស្ត្រសរុបចំនួន១២៣រូប បានចុះមូលដ្ឋានចំនួន១០០៤លើក។ បើប្រៀប

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧៧

[5] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៨៣

ធៀបក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំទី១ នៃនីតិកាលទី៥នេះ ការសង្កេតឃើញថា ចំនួនសកម្មភាពមានការថយចុះ ហើយចំនួនតំណាងរាស្ត្រចុះធ្វើសកម្មភាពក៏មានការថយចុះតិចតួចដែរ ដែលក្នុងរយៈពេលនោះមានតំណាងរាស្ត្រចំនួន៩៦រូប ចុះធ្វើសកម្មភាពបានចំនួន១២៧៤លើក។ ការថយចុះនៃចំនួនសកម្មភាពរបស់តំណាងរាស្ត្រ ជាពិសេសតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាក្នុងរយៈពេលនេះ ការសង្កេតឃើញថា មានមូលហេតុមួយចំនួនដូចជា ទី១.តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាមិនសហការក្នុងការផ្តល់ព័ត៌មានអំពីសកម្មភាពចុះមូលដ្ឋានរបស់ខ្លួន ធ្វើបានសកម្មភាពច្រើននៅរដ្ឋសភា និងមិនសូវចុះធ្វើសកម្មភាពនៅមូលដ្ឋាន ព្រោះយល់ឃើញថាក្រុមការងារចុះពង្រឹងមូលដ្ឋានរបស់គណបក្សនេះបានធ្វើសកម្មភាពច្រើនហើយ និងទី២.ការិយាល័យតំណាងរាស្ត្របំពេញការងាររបស់ខ្លួនមិនបានពេញលេញ។ ដោយឡែក សកម្មភាពតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិមានការកើនឡើងក៏ព្រោះតែមិនសូវមានការងារចំពោះកិច្ចនៅរដ្ឋសភា និងបានធ្វើពហិការមិនចូលកិច្ចប្រជុំមួយចំនួន ដែលធ្វើឲ្យតំណាងរាស្ត្រទាំងនោះមានពេលវេលាចុះទៅមូលដ្ឋានបានច្រើន។

តាមការសង្កេតឃើញថា ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ច្រើនជាងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា។ តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិបានចុះមូលដ្ឋានចំនួន៧៧៤លើក ហើយតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចុះបានចំនួន២៣០លើក។

សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្របានធ្វើឡើងក្នុងគោលបំណងសំខាន់ៗចំនួន៥ ដែលរួមមានៈ ១.ការចុះសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធផលនានា, ២.ការចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្ស, ៣.ចូលរួមវេទិកាសាធារណៈ, ៤.អមដំណើរថ្នាក់ដឹកនាំ, និង៥.គោលបំណងចុះជួយអន្តរាគមន៍ដោះស្រាយបញ្ហានានាជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

គណបក្សប្រជាជនកម្ពុជា ដែលមានអាសនៈ៦៨ក្នុងរដ្ឋសភា ខុមហ្វ្រែលទទួលព័ត៌មានថា មានតំណាងរាស្ត្រចំនួន៤៩រូប បានចុះមូលដ្ឋានបានចំនួន២៣០លើក។ សកម្មភាពចុះមូលដ្ឋានទាំងនោះគឺបានផ្តោតទៅលើគោលបំណងមួយចំនួនដូចជាៈ ការចុះសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋ និងរួមទាំងសម្ពោធសមិទ្ធផលនានាចំនួន១៥១លើក អមដំណើរថ្នាក់ដឹកនាំចំនួន៤៥លើក ចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សចំនួន១៨លើក ការចូលរួមវេទិកាសាធារណៈចំនួន៧លើក និងអន្តរាគមន៍ដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋចំនួន១៤លើក។

ដោយឡែកគណបក្សសង្គ្រោះជាតិ ដែលមាន៥៥អាសនៈក្នុងរដ្ឋសភា មានតំណាងរាស្ត្រចំនួន៤២រូប បានចុះធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន៧៧៤លើក។ សកម្មភាពទាំងនោះ បានផ្តោលលើគោលបំណងមួយចំនួនដូចជាៈ ការចុះសំណេះសំណាល សួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋចំនួន៤៩៣លើក ចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សចំនួន១១០លើក អមដំណើរថ្នាក់ដឹកនាំរបស់ខ្លួនចំនួន៩៨លើក ចូលរួមវេទិកាសាធារណៈចំនួន៤២លើក និងអន្តរាគមន៍ដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋចំនួន២៦លើក។

### ៣.១ ចំនួនដង និងចំនួនអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន

របាយការណ៍សម្រាប់ឆ្នាំទី២ នៃរដ្ឋសភា នីតិកាលទី៥នេះ តាមទិន្នន័យដែលខុមហ្វ្រែលទទួលបានបង្ហាញឲ្យឃើញថា មានអ្នកតំណាងរាស្ត្រចំនួន៩១រូប ធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន១០០៤លើក ដែលចំនួនមានការធ្លាក់ចុះបើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំទី១ ដែលមានចំនួន១២៧៤លើក។

ក្នុងរយៈពេលនេះ អ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន៤៩រូប បានចុះមូលដ្ឋានសរុប២៣០លើក រីឯអ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំនួន៤២រូប បានចុះមូលដ្ឋានសរុប៧៧៤លើក។

*ក្រាហ្វិកទី៤៖ ចំនួនតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងចំនួនតំណាងរាស្ត្រចុះមូលដ្ឋានសរុប*




ក្រាហ្វិកនេះ បង្ហាញពីចំនួនតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋានធៀបនឹងចំនួនតំណាងរាស្ត្រចុះមូលដ្ឋានសរុប។ ក្នុងរយៈពេលនេះចំនួនតំណាងរាស្ត្រសរុបចំនួន៩១រូប បានចុះមូលដ្ឋាន ដែលក្នុងនេះចំនួនតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ចុះមូលដ្ឋានច្រើនជាងចំនួនតំណាងរាស្ត្រតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា មានចំនួន៤៩រូបស្មើនឹង៥៤%នៃចំនួនតំណាងរាស្ត្រដែលបានចុះមូលដ្ឋានសរុប។ គណបក្សសង្គ្រោះជាតិចំនួន៤២រូប ស្មើនឹង៤៦%នៃចំនួនតំណាងរាស្ត្រដែលបានចុះមូលដ្ឋានសរុប។

*ក្រាហ្វិកទី៥៖ ភាគរយនៃអាសនៈរដ្ឋសភា និងភាគរយនៃអ្នកតំណាងរាស្ត្រតាមគណបក្សចុះមូលដ្ឋាន ធៀបនឹងតំណាងរាស្ត្រចុះមូលដ្ឋានសរុប*




គណបក្សប្រជាជនកម្ពុជាមានចំនួន៦៨អាសនៈ ស្មើនឹង៥៥%នៃចំនួនអាសនៈសរុបក្នុងរដ្ឋសភា មានតំណាងរាស្ត្រចំនួន៤៩រូប ស្មើនឹង៥៤% បានចុះមូលដ្ឋាន។ គណបក្សសង្គ្រោះជាតិមាន៥៥អាសនៈ ស្មើនឹង៤៥%នៃចំនួនអាសនៈសរុបក្នុងរដ្ឋសភា មានតំណាងរាស្ត្រ៤២រូប ស្មើនឹង៤៦% បានចុះមូលដ្ឋាន។

*ក្រាហ្វិកទី៦៖ ភាគរយនៃការចុះមូលដ្ឋានធៀបនឹងចំនួនតំណាងរាស្ត្រសរុបតាមគណបក្ស*




សកម្មភាពចុះមូលដ្ឋាន បើគិតជាភាគរយតំណាងរាស្ត្រដែលបានចុះ ធៀបទៅនឹងចំនួនតំណាងរាស្ត្រសរុបនៃគណបក្សនីមួយៗឃើញថា គណបក្សប្រជាជនកម្ពុជាមានតំណាងរាស្ត្រចំនួន៧២% នៃតំណាងរាស្ត្រសរុប៦៨រូប បានចុះធ្វើសកម្មភាពតាមមូលដ្ឋាន ហើយតំណាងរាស្ត្រចំនួន២៨%ទៀត ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីសកម្មភាពចុះមូលដ្ឋាននោះទេ។ ចំណែកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំនួន៧៦% នៃតំណាងរាស្ត្រសរុប៥៥រូប បានធ្វើសកម្មភាពនៅមូលដ្ឋាន ហើយចំនួន២៤%ទៀត ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីការចុះមូលដ្ឋាននោះទេ។

*ក្រាហ្វិកទី៧៖ ចំនួនតំណាងរាស្ត្រ និងចំនួនសកម្មភាពចុះមូលដ្ឋានតាមគណបក្ស*




បើមើលពីចំនួនតំណាងរាស្ត្រចុះមូលដ្ឋាន សរុបតាមគណបក្សនីមួយៗឃើញថា ចំនួនអ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា បានចុះធ្វើសកម្មភាពក្នុងមូលដ្ឋានច្រើនជាងចំនួនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។ តែបើមើលចំនួននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រវិញបង្ហាញថា ចំនួនការចុះមូលដ្ឋានរបស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ មានចំនួនច្រើនជាងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា ដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើសកម្មភាពចំនួន៧៧៤លើក រីឯតំណាងរាស្ត្រមកពីគណបក្សប្រជាជនធ្វើសកម្មភាពចំនួន២៣០លើក។

*តារាងទី៤៖ សកម្មភាពរបស់អ្នកតំណាងរាស្ត្រចុះមូលដ្ឋានច្រើនជាងគេ១០រូប*

| **លរ.** | **ឈ្មោះអ្នកតំណាងរាស្ត្រ** | **គណបក្ស** | **ចំនួនដង** | **សកម្មភាព** | |
|---|---|---|---|---|---|
| | | | | **ក្នុងមណ្ឌល** | **ក្រៅមណ្ឌល** |
| ១ | លោកជំទាវ កែ សុវណ្ណរតន៍ | | ៨៨ | ៦៧ | ២១ |
| ២ | ឯកឧត្តម ឡុង ប៊ុន្នី | | ៥៥ | ៥៣ | ០២ |
| ៣ | ឯកឧត្តម ចាន់ ចេង | | ៣៩ | ៣៦ | ០៣ |
| ៤ | ឯកឧត្តម ពិន រតនា | | ៣៧ | ៣០ | ០៧ |
| ៥ | លោកជំទាវ ពត ពៅ | | ៣៤ | ២៦ | ០៨ |
| ៦ | ឯកឧត្តម ប៉ុល ហាំ | | ៣៣ | ២៦ | ០៧ |
| ៧ | លោកជំទាវ មូរ សុខហួរ | | ៣១ | ២៧ | ០៤ |
| ៨ | ឯកឧត្តម កង គឹមហាក់ | | ៣០ | ២១ | ០៩ |
| ៩ | ឯកឧត្តម ហួរ វ៉ាន់ | | ២៩ | ២៣ | ០៦ |
| ១០ | ឯកឧត្តម គង់ ប៊ូរ៉ា | | ២៤ | ២២ | ០២ |

តារាងខាងលើនេះបញ្ជាក់ពីអ្នកតំណាងរាស្ត្រដែលចុះមូលដ្ឋានច្រើនជាងគេក្នុងរយៈពេលនៃរបាយការណ៍នេះ។ ការសង្កេតឃើញថា តំណាងរាស្ត្រចំនួន១០រូប ពីគណបក្សសង្គ្រោះជាតិ បានចុះមូលដ្ឋានច្រើនជាងគេ ក្នុងចំណោមអ្នកតំណាងរាស្ត្រចុះមូលដ្ឋានសរុប៩១រូប។

### ៣.២ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

ការសង្កេតអំពីសកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនេះ ខុមហ្វ្រែលបានបែងចែកគោលបំណងនៃសកម្មភាពចំនួន៥គោលបំណងធំៗគឺ ទី១.ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ (អន្តរាគមន៍) ទី២.ការជួប

សំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា (សួរសុខទុក្ខ) ទី៣.គោលបំណងចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស (ពង្រឹងគណបក្ស) ទី៤.គោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈ (វេទិកាសាធារណៈ) និងទី៥.គោលបំណងផ្តោតលើការចុះអមដំណើរថ្នាក់ដឹងនាំគណបក្សរបស់ខ្លួន (អមដំណើរ)។

របាយការណ៍ក្នុងឆ្នាំទី២នេះបង្ហាញថា គោលបំណងដែលអ្នកតំណាងរាស្ត្រផ្តោតសំខាន់នោះគឺមិនខុសពីរបាយការណ៍ក្នុងឆ្នាំមុននោះទេគឺ ការចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសមិទ្ធិផលនានា។ សកម្មភាពអន្តោគមន៍បញ្ហានានារបស់ម្ចាស់ឆ្នោតមានការកើនឡើងជាងឆ្នាំទី១។

*<u>ក្រាហ្វិកទី៨៖ភាគរយនៃគោលបំណងនីមួយៗរបស់អ្នកតំណាងរាស្ត្រតាមគណបក្សធៀបនឹងគោលបំណងសរុបតាមគណបក្ស</u>*




ដ្យាក្រាមនេះបង្ហាញពីភាគរយនៃគោលបំណងនីមួយៗ របស់តំណាងរាស្ត្រទៅតាមគណបក្ស ធៀបទៅនឹងគោលបំណងសរុបតាមគណបក្ស។ តួលេខបង្ហាញថា តំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបានផ្តោតខ្លាំងទៅលើគោលបំណងចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធផលនានា ដែលមានចំនួន៦៥% នៃចំនួនចុះមូលដ្ឋានសរុបនៃតំណាងរាស្ត្ររបស់ខ្លួន។ ការចុះអមដំណើរថ្នាក់ដឹកនាំចំនួន១៩% ការពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សចំនួន៧% ចូលរួមវេទិកាចំនួន៣% និងការចុះអន្តរាគមន៍ចំនួន៦%។ ចំណែកឯតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិវិញ បានផ្តោតខ្លាំងលើគោលបំណងដូចនឹងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាផងដែរ គឺការចុះសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋចំនួន៦៤% នៃចំនួនចុះមូលដ្ឋានសរុបនៃតំណាងរាស្ត្ររបស់ខ្លួន។ ការចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្សចំនួន១៤% អមដំណើរថ្នាក់ដឹកនាំចំនួន១៣% អន្តរាគមន៍ដោះស្រាយបញ្ហានានាចំនួន៣% និងចូលរួមវេទិកាសាធារណៈចំនួន៦%។

### ៣.៣ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សនីមួយៗ

ការសង្កេតឃើញថា គោលបំណងដែលអ្នកតំណាងរាស្ត្រផ្តោតសំខាន់ជាងគេក្នុងការចុះមូលដ្ឋាននោះ គឺការចុះសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធផលនានា ដែលក្នុងនោះតំណាងរាស្ត្រពីសង្គ្រោះជាតិធ្វើសកម្មភាពចំនួន៤៩៣លើក ហើយតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាធ្វើសកម្មភាពចំនួន១៥១លើក។ ចំពោះគោលបំណងចុះពង្រឹងបណ្តាញផ្ទៃក្នុងគណបក្ស តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើសកម្មភាពបានចំនួន១១០លើក ច្រើនជាងតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ដែលធ្វើសកម្មភាពចំនួន១៨លើក។ ការធ្វើសកម្មភាពក្នុងគោលបំណងចុះអមដំណើរថ្នាក់ដឹកនាំ តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាធ្វើសកម្មភាពចំនួន៤៥លើក ហើយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិចំនួន៩៨លើក។ ចំណែកឯការចុះអន្តរាគមន៍ដោះស្រាយបញ្ហានានាវិញ តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានចំនួន១៤លើក ហើយតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមានចំនួន២៦លើក។ គោលបំណងចុងក្រោយ គឺការចូលរួមវេទិកាសាធារណៈ តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិធ្វើសកម្មភាពចំនួន៤២លើក និងតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាចំនួន៧លើក។

*<u>តារាងទី៥៖ ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៃគណបក្សនយោបាយនីមួយៗតាមគោលបំណង</u>*

| **គោលបំណងនៃការចុះមូលដ្ឋានទាំង១០០៤ លើករបស់អ្នកតំណាងរាស្ត្រទាំង ៩១រូប** | **គណបក្សនយោបាយ** | | **សរុប** |
|---|---|---|---|
| | ៤៩រូប | ៤២រូប | |
| ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និង សម្ពោធសមិទ្ធិផលនានា | ១៥១ | ៤៩៣ | ៦៤៤(៦៤%) |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ១៨ | ១១០ | ១២៨(១៣%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ៤៥ | ៩៨ | ១៤៣(១៤%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ១៤ | ២៦ | ៤០(៤%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៧ | ៤២ | ៤៩(៥%) |
| សរុបគោលបំណងតាមគណបក្ស | ២៣០(២៣%) | ៧៧៤(៧៧%) | ១០០៤(១០០%) |

តារាងខាងលើនេះ បានបង្ហាញពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ តំណាងរាស្ត្រភាគច្រើនផ្តោតទៅលើគោលបំណងជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលចុះបាន ៦៤៤លើក (ស្មើនឹង ៦៤%នៃការចុះមូលដ្ឋានសរុប)។ ការចុះមូលដ្ឋានក្នុងគោលបំណងទី២ អ្នកតំណាងរាស្ត្រផ្តោតទៅលើគោលបំណងចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សចុះបាន១២៨លើក (ស្មើនឹង១៣%នៃការចុះមូលដ្ឋានសរុប)។ ការចុះក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំគណបក្សរបស់ខ្លួនចុះបាន១៤៣លើក (ស្មើនឹង១៤%នៃចំនួនចុះមូលដ្ឋានសរុប)។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈចុះបាន៤៩លើក(ស្មើនឹង៥%នៃការចុះមូលដ្ឋានសរុប) និងក្នុងគោលបំណងអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋចុះបាន៤០លើក (ស្មើនឹង៤%នៃការចុះមូលដ្ឋានសរុប)។

ទាក់ទិននឹងការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ទាំង ៤០លើក (ស្មើនឹង៤%នៃការចុះមូលដ្ឋានសរុប) របស់អ្នកតំណាងរាស្ត្រ ខុមហ្វ្រែល សង្កេតឃើញថា កិច្ចអន្តរាគមន៍ភាគច្រើនគឺផ្តោតទៅលើបញ្ហាវិវាទដីធ្លី និងបញ្ហាព្រំដែនរវាងកម្ពុជា-វៀតណាម។ កិច្ចអន្តរាគន៍របស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិគឺផ្តោតលើបញ្ហាព្រំដែន និងបញ្ហាវិវាទដីធ្លី ចំណែកឯកិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាគឺផ្តោតលើបញ្ហាវិវាទដីធ្លី។

ក្នុងចំណោមកិច្ចអន្តរាគមន៍ទាំងនោះ ខុមហ្វ្រែល ទទួលពត៌មានថា មានកិច្ចអន្តរាគមន៍ចំនួន ១៥ករណី ទទួលបានលទ្ធផល តាមរយៈការឆ្លើយតប និងចំណាត់ការពីសំណាក់រាជរដ្ឋាភិបាល។ ជាក់ស្តែងករណីវិវាទដីធ្លីនៅក្នុងខេត្តព្រះសីហនុ បន្ទាប់ពីមានកិច្ចអន្តរាគមន៍ពីក្រុមតំណាងរាស្ត្រ អាជ្ញាធរខេត្តបានដោះស្រាយជូនប្រជាពលរដ្ឋដែលមានទំនាស់នៅស្ពានឆេះ អូរត្រេះ តាមរយៈការចាប់ឆ្នោតដីសម្បទានសង្គមកិច្ចជូនដល់ពួកគេ។ ករណីវិវាទដីធ្លីផ្សេងទៀតដែលតំណាងរាស្ត្រចុះអន្តរាគមន៍ មានការឆ្លើយតបពីអាជ្ញាធរថា ខ្លួនកំពុងស្វែងរកដំណោះស្រាយ ដែលលទ្ធផលយ៉ាងណានោះកំពុងស្ថិតក្នុងការតាមដានរបស់អ្នកតំណាងរាស្ត្រ និងព្រមទាំងអ្នកសង្កេតការណ៍របស់ខុមហ្វ្រែល។

ចំពោះកិច្ចអន្តរាគមន៍លើបញ្ហាព្រំដែនវិញ ការសង្កេតឃើញថា មានការយកទិត្តទុកដាក់ស្វែងរកដំណោះស្រាយពីសំណាក់រាជរដ្ឋាភិបាល តាមរយៈយន្តការផ្សេងៗដូចជា ការផ្ទៀងផ្ទាត់ផែនទី ការបង្កើតគណៈកម្មការពិសេស ការចុះពិនិត្យផ្ទៀងផ្ទាត់ និងការធ្វើកំណត់ទូតជាដើម។

**៣.៤ មណ្ឌលរាជធានី ខេត្តដែលអ្នកតំណាងរាស្ត្របានចុះ**

ទោះបីជារដ្ឋធម្មនុញ្ញបានចែងថា តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល តែការសង្កេតឃើញថា ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រភាគច្រើន គឺផ្តោតទៅលើមណ្ឌលរបស់ខ្លួន។

តាមរយៈទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបាន អំពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រទូទាំង២៥ រាជធានី ខេត្ត ឃើញថា មណ្ឌលដែលមានអ្នកតំណាងរាស្ត្រចុះច្រើនជាគេ គឺមណ្ឌលខេត្តព្រៃវែង។ មណ្ឌលដែលមានតំណាងរាស្ត្រចុះច្រើនបន្ទាប់រួមមានមណ្ឌលខេត្តបាត់ដំបង មណ្ឌលខេត្តកណ្តាល មណ្ឌលខេត្តកំពង់ចាម និងមណ្ឌលខេត្តសៀមរាប។

ចំណែកមណ្ឌលដែលអ្នកតំណាងរាស្ត្រចុះទៅបានតិច រួមមាន មណ្ឌលខេត្តប៉ៃលិន មណ្ឌលខេត្តរតនៈគីរី និងមណ្ឌលខេត្តព្រះសីហនុ។

**៣.៥ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលរាជធានី ខេត្ត**

ការិយាល័យតំណាងរាស្ត្រ ជាទីកន្លែងធ្វើការងាររបស់អ្នកតំណាងរាស្ត្រ នៅពេលដែលតំណាងរាស្ត្រចុះមូលដ្ឋាននោះ និងជាកន្លែងផ្សារភ្ជាប់ទំនាក់ទំនង រវាងតំណាងរាស្ត្រ និងម្ចាស់ឆ្នោត និងព្រមទាំងជាកន្លែងទទួលយកបណ្តឹង ឬសំណើនានារបស់ម្ចាស់ឆ្នោត ដើម្បីបញ្ជូនបន្តទៅរដ្ឋសភាធ្វើការដោះស្រាយ។

មិនខុសពីរបាយការណ៍សង្កេតរដ្ឋសភា និងតំណាងរាស្ត្រឆ្នាំទី១ ការសង្កេតក្នុងឆ្នាំទី២នេះឃើញថា ដំណើរការនៃការិយាល័យតំណាងរាស្ត្រនៅតាមបណ្តាខេត្តមួយចំនួនហាក់មានដំណើរការមិនប្រក្រតី ព្រោះថាមិនបានបំពេញតួនាទីការងាររបស់ខ្លួន ដោយបិទទ្វារមិនដំណើរការ ឬដំណើរការមិនពេញលេញ។

ខុមហ្វ្រែលបានពិនិត្យឃើញដែរថា ក្នុងចំណោមរាជធានី ខេត្ត ដែលមានការិយាល័យតំណាងរាស្ត្រ មានការិយាល័យចំនួន១៨បានបើកដំណើរការ និងបំពេញតួនាទីការងាររបស់ខ្លួន។ ទន្ទឹមនឹងនេះក៏មានសេចក្តីរាយការណ៍ថា នៅមិនទាន់អនុវត្តតួនាទីរបស់ខ្លួនពេញលេញនៅឡើយ។

ការិយាល័យមួយចំនួនដែលបើកដំណើរការនោះបុគ្គលិកមន្ត្រីការិយាល័យ មិនទទួលបានព័ត៌មានពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រនោះទេ ដោយលើកឡើងថា តំណាងរាស្ត្រខ្លះចុះមូលដ្ឋានមិនបានផ្តល់ដំណឹងពីការចុះដល់ពួកគាត់នោះទេ។ មន្ត្រីការិយាល័យតំណាងរាស្ត្រខ្លះទៀត ដើម្បីទទួលបានព័ត៌មានពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រ ត្រូវទៅសុំព័ត៌មានពីខាងគណបក្សនយោបាយវិញ។

មួយវិញទៀត ការិយាល័យតំណាងរាស្ត្រខេត្តខ្លះ ទទួលបានព័ត៌មានថា ខ្វះបុគ្គលិកបម្រើការ ជាក់ស្តែងការិយាល័យតំណាងរាស្ត្រមណ្ឌលខេត្តកែប យកបុគ្គលិកពីខេត្តកំពតមកប្រចាំការ ព្រោះការិយាល័យតំណាងរាស្ត្រខេត្តនេះទើបតែសាងសង់រួចមានបុគ្គលិកប្រចាំការផ្ទាល់នោះទេ។ រីឯខេត្តបន្ទាយមានជ័យវិញ ខ្វះខាតបុគ្គលិកប្រចាំការនៅការិយាល័យតំណាងរាស្ត្រ ពេលដែលមន្ត្រីចុះអមដំណើរសកម្មភាពចុះមូលដ្ឋានរបស់តំណាងរាស្ត្រ។

ខេត្តចំនួន២ដែលខុមហ្វ្រែលរកឃើញថា នៅមិនទាន់មានការិយាល័យតំណាងរាស្ត្រដូចជា ខេត្តត្បូងឃ្មុំ និងខេត្តឧត្តរមានជ័យ។ ដោយឡែក ការិយាល័យតំណាងរាស្ត្រក្នុងខេត្តចំនួនបី មិនសូវបានបើកដំណើរការ និងបំពេញតួនាទីការងាររបស់ខ្លួនទេ ក្នុងនោះរួមមាន ការិយាល័យក្នុងខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តពោធិ៍សាត់។

**ប្រសិទ្ធភាពការងារនៃការិយាល័យតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង**

ខេត្តព្រៃវែងគឺជាមណ្ឌលបោះឆ្នោតដែលមានអាសនៈច្រើន (១១អាសនៈ) ក្នុងចំណោមមណ្ឌលបោះឆ្នោតដែលមានអាសនៈច្រើនទាំងបួនក្នុងព្រះរាជាណាចក្រកម្ពុជា។ លទ្ធផលបោះឆ្នោតឆ្នាំ២០១៣ គណបក្សប្រជាជនកម្ពុជាទទួលបាន៥អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន៦អាសនៈ។

មិនខុសគ្នាពីការិយាល័យតំណាងរាស្ត្រនៅតាមបណ្តាខេត្តមួយចំនួន ការិយាល័យតំណាងរាស្ត្រក្នុងខេត្តព្រៃវែង មានសេចក្តីរាយការណ៍ថា នៅមិនទាន់អនុវត្តតួនាទីរបស់ខ្លួនពេញលេញនៅឡើយ និងបញ្ហាអសកម្មមួយចំនួន។ មួយវិញបញ្ហារបស់ម្ចាស់ឆ្នោតនៅមូលដ្ឋាននោះភាគច្រើន ដែលស្នើសុំអន្តរាគមន៍ទៅអ្នកតំណាងរាស្ត្រនៅពេលចុះមូលដ្ឋានតាមភូមិ ឃុំ មិនត្រូវបានដោះស្រាយ។

ដោយពិនិត្យឃើញមានបញ្ហាទាំងនេះ អ្នកតំណាងរាស្ត្រទាំង ៦រូប ពីគណបក្សសង្គ្រោះជាតិ បានឯកភាពគ្នាកំណត់ឲ្យមានអ្នកតំណាងរាស្ត្រប្រចាំការនៅរៀងរាល់ថ្ងៃសុក្រ ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១១:៣០នាទីព្រឹក។ សកម្មភាពនេះចាប់ពីខែតុលា ឆ្នាំ២០១៥ ក្នុងគោលបំណងទទួលជួបផ្ទាល់ជាមួយម្ចាស់ឆ្នោត និងទទួលពាក្យបណ្តឹង ដើម្បីឈានទៅរកដោះស្រាយបញ្ហាជូនម្ចាស់ឆ្នោតតាមយន្តការការិយាល័យតំណាងរាស្ត្រ និងរដ្ឋសភា។ គួរបញ្ជាក់ថា ការិយាល័យតំណាងតែងតែធ្វើរបាយការណ៍ជាប្រចាំអំពីបណ្តឹង ឬសំណើអន្តរាគមន៍នានារបស់ម្ចាស់ឆ្នោត បញ្ជូនទៅរដ្ឋសភាដើម្បីរកដំណោះស្រាយ។

ជាការកត់សម្គាល់ ការរៀបចំនេះបានទទួលការចាប់អារម្មណ៍ពីម្ចាស់ឆ្នោត ហើយបញ្ហាមួយចំនួនត្រូវបានបញ្ជូនទៅរដ្ឋសភា ហើយរដ្ឋសភាបានស្នើវិធានការបន្តពីអាជ្ញាធរមានសមត្ថកិច្ច។ តែទោះជាយ៉ាងណាមានស្នើឡើងថា គួរតែមានការចូលរួមពីតំណាងរាស្ត្រគ្រប់គណបក្ស ហើយរដ្ឋសភាគួរផ្តល់មធ្យោបាយសម្រាប់ម្ចាស់ឆ្នោតដែលខ្វះខាត ហើយមានបំណងមកទទួលសេវាពីការិយាល័យតំណាងរាស្ត្រ និងព្រមទាំងស្នើឲ្យមានផ្សព្វផ្សាយព័ត៌មានបន្ថែមទៀតអំពីការរៀបចំនេះឲ្យម្ចាស់ឆ្នោតបានដឹង។

បើទោះជាសកម្មភាពនេះមិនទាន់បានបង្ហាញអំពីលទ្ធផលជាដុំកំភួន និងឆ្លើយតបទៅនឹងបញ្ហាម្ចាស់ឆ្នោតក្នុងខេត្តព្រៃវែង ប៉ុន្តែវាគឺជាគំរូដ៏ល្អមួយសម្រាប់អ្នកតំណាងរាស្ត្រនៅតាមមណ្ឌលរាជធានី ខេត្តផ្សេងទៀតអនុវត្តតាម ដើម្បីប្រសិទ្ធភាពការងាររបស់ការិយាល័យតំណាងរាស្ត្រផង និងដើម្បីផលប្រយោជន៍ម្ចាស់ឆ្នោតផង។

## IV. កិច្ចអន្តរាគមន៍របស់តំណាងរាស្ត្រ និងរដ្ឋសភា

### ៤.១ កិច្ចអន្តរាគមន៍របស់រដ្ឋសភា

នៅក្នុងអំឡុងពេលនេះ ខុមហ្វ្រែលអង្កេតឃើញថា សកម្មភាពទទួលបណ្តឹង និងកិច្ចអន្តរាគមន៍លើបណ្តឹងរបស់ប្រជាពលរដ្ឋរបស់រដ្ឋសភាសកម្មជាងរយៈពេលកន្លងមក។ មានបណ្តឹងរបស់ប្រជាពលរដ្ឋមួយចំនួនបានប្តឹងមករដ្ឋសភាតាមយន្តការនានា ដើម្បីឲ្យស្ថាប័នជាតិមួយនេះ ស្វែងរកដំណោះស្រាយលើបញ្ហាវិវាទដែលខ្លួនជួបប្រទះ។

ក្នុងរយៈពេលនេះខុមហ្វ្រែលទទួលព័ត៌មានថាមានបណ្តឹងសុំអន្តរាគមន៍ពីប្រជាពលរដ្ឋមករដ្ឋសភាដោយផ្ទាល់ ដើម្បីមានវិធានការដោះស្រាយបញ្ហានានាចំនួន២៥បណ្តឹង។ បណ្តឹងទាំងនោះ គឺភាគច្រើនប្តឹងសុំកិច្ចអន្តោគមន៍ពីរដ្ឋសភាដើម្បីឲ្យមានវិធានការដោះស្រាយបញ្ហាវិវាទនានាពិសេសគឺវិវាទដីធ្លី និងវិវាទការងារ។ ជាមួយគ្នានេះ មានបណ្តឹងប្តឹងដោយផ្ទាល់ពីតំណាងរាស្ត្រមករដ្ឋសភាចំនួន១ករណី និងបណ្តឹងទាមទារទម្លាក់ដំណែងអនុប្រធានទី១ នៃរដ្ឋសភា ចំនួន១ករណី។

ជាការឆ្លើយតបទៅនឹងបណ្តឹងរបស់ប្រជាពលរដ្ឋទាំងនោះ ខុមហ្វ្រែលទទួលបានព័ត៌មាន និងសង្កេតឃើញថា ២ បណ្តឹងទាក់ទងនឹងវិវាទការងារនៅពុំទាន់ត្រូវបានឆ្លើយតបនោះទេ។ ចំពោះបណ្តឹងទាក់ទងនឹងវិវាទដីធ្លី ការសង្កេតឃើញថា មានចំណាត់ពីរដ្ឋសភាតាមរយៈគណៈកម្មការជំនាញទី១ដូចជា ការកោះអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺក្នុងគណៈកម្មការជំនាញនៃរដ្ឋសភា និងការចុះដោយផ្ទាល់ទៅដល់កន្លែងទំនាស់ ដើម្បីសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីមូលហេតុនៃវិវាទជាដើម។ ជាក់ស្តែង រដ្ឋមន្ត្រី២រូប គឺរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានកោះអញ្ជើញមកបំភ្លឺលើករណីវិវាទដីធ្លីនៅស្រុកបទុមសាគរ និងគីរីសាគរ ខេត្តកោះកុង និងបំភ្លឺចំពោះបញ្ហាវិវាទផ្សេងទៀតដែលពាក់ព័ន្ធនឹងការងារទទួលខុសត្រូវរបស់ក្រសួងទាំងពីរ។ លើសពីនេះទៅទៀត មានការចុះទៅដល់កន្លែងវិវាទដីធ្លីដោយផ្ទាល់របស់គណៈកម្មការទី១ក្នុងខេត្តព្រះសីហនុ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តកោះកុង ខេត្តត្បូងឃ្មុំ ខេត្តបាត់ដំបង ហើយបានស្នើអាជ្ញាធរមានសមត្ថកិច្ចបន្តពិនិត្យ និងស្វែងរកដំណោះស្រាយលើករណីទំនាស់ទាំងនោះ។[6]

គួរបញ្ជាក់ថា បន្ទាប់ពីមានកិច្ចអន្តោគមន៍របស់រដ្ឋសភាទៅលើបណ្តឹងរបស់ប្រជាពលរដ្ឋ ខុមហ្វ្រែលទទួលព័ត៌មានថា បញ្ហាទំនាស់ដីធ្លីចំនួន១៧ករណី ត្រូវបានឆ្លើយតប និងកំពុងមានវិធានការណ៍ដោះស្រាយលើករណីទាំងនោះ។

### ៤.២ លទ្ធផល និងលិខិតអន្តរាគមន៍របស់តំណាងរាស្ត្រ

រាជរដ្ឋាភិបាលសម្រេចលុបចោលកិច្ចព្រមព្រៀងទទួលសិទ្ធិលក់សំបុត្រចូលទស្សនាតំបន់អង្គរ ក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ ២០១៥ និងបានសម្រេចស្តីពីការលុបចោលនូវកិច្ចព្រមព្រៀងសម្បទាន រវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុន AZ លើការយកកម្រៃសេវាថែទាំ និងជួសជុលផ្លូវជាតិលេខ៤ ក្នុងខែមករា ឆ្នាំ២០១៦។ ការសម្រេចលុបកិច្ចព្រមព្រៀងទាំងពីរនេះ មានការមើលឃើញថា ជាការខិតខំរបស់អ្នកតំណាងរាស្ត្រ។

ពាក់ព័ន្ធការលក់សំបុត្រចូលទស្សនាតំបន់អង្គរវត្ត អនុប្រធានគណៈកម្មការហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា និងជាអ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ឯកឧត្តម សុន ឆ័យ បានរកឃើញថា មានការបាត់បង់លុយរាប់លានដុល្លារលើការចូលទស្សនាប្រាសាទអង្គរវត្ត និងការជួលដីទៅឲ្យក្រុមហ៊ុនលោកឧកញ៉ា សុខ គង់។ ឯកឧត្តម បានអះអាងថា អាជ្ញាធរជាតិអប្សរាជួលដីឲ្យក្រុមហ៊ុនសុខាអូតែលរបស់លោកឧកញ៉ា សុខ គង់ ដោយមានភាពអាថ៌កំបាំង និងមិនមានតម្លាភាព ហើយចំណូលពីប្រាសាទអង្គរវត្តរាប់រយលានដុល្លារក៏ត្រូវបានបាត់បង់ផងដែរ។

ជុំវិញការចោទប្រកាន់នេះ អាជ្ញាធរអប្សរាបានបដិសេធ តាមរយៈលិខិតបំភ្លឺមួយដែលមានខ្លឹមសារថា *«អាជ្ញាធរអប្សរាសូមបដិសេធនូវការលើកឡើងរបស់តំណាងរាស្ត្រគណបក្សប្រឆាំងថា ជាព័ត៌មានភូតកុហកពីការពិត ជាចេតនាកេងចំណេញនយោបាយ និងថាតំណាងរាស្ត្ររូបនោះធ្វើការសងសឹកជាមួយអាជ្ញាធរជាតិអប្សរា»*។ អាជ្ញាធរអប្សរាបានចេញលិខិតបំភ្លឺ និងធ្វើការបកស្រាយការចោទប្រកាន់ជាបន្តបន្ទាប់ ដោយបានអះអាងផងដែរថា ការលើកឡើងរបស់ឯកឧត្តម សុន ឆ័យ ម្តងហើយម្តងទៀតនេះ ថាជាការចិញ្ចឹមចិត្តមួលបង្កាច់ការពិត និងបំផ្លើសគ្មានមូលដ្ឋានច្បាស់លាស់ ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិត្យានុភាព និងភាពត្រឹមត្រូវក្នុងការបំពេញបេសកកម្មរបស់អាជ្ញាធរជាតិអប្សរា។

បើទោះជាមានការបដិសេធពីអាជ្ញាធរជាតិអប្សរា អ្នកតំណាងរាស្ត្រគណបក្សប្រឆាំង នៅតែបន្តស្នើ និងដាក់ការសង្ស័យជាបន្តបន្ទាប់អំពីតួលេខដែលបានចេញផ្សាយអាជ្ញាធរជាតិអប្សរា។ ជាមួយគ្នានេះគណៈកម្មការទី១០នៃរដ្ឋសភាទទួល

[6] ករណីលំអិតមានសរសេរទំព័រ 10 -13 ក្នុងសកម្មភាពរបស់គណៈកម្មការជំនាញនៃរដ្ឋសភា

បន្ទុកអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយក៏បានចុះទៅត្រួតពិនិត្យរបាយការណ៍ ស្តីពីចំណូលចំណាយរបស់អាជ្ញាធរអប្សរា និងព្រមទាំងស្នើឲ្យអាជ្ញាធរអប្សរាពន្យល់អំពីបញ្ហាមួយចំនួនទៀតដែលសង្ស័យថា មានជាប់ពាក់ព័ន្ធនឹងអំពើពុករលួយផងដែរ។

ឆ្លើយតបនឹងបញ្ហានេះ នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ រដ្ឋាភិបាលសម្រេចលុបចោលកិច្ចព្រមព្រៀងទទួលសិទ្ធិលក់សំបុត្រចូលទស្សនាតំបន់អង្គរជាមួយក្រុមហ៊ុន សុខា អូតែល (Sokha Hotel) របស់ឧកញ៉ា សុខ គង់ ដែលនឹងចូលជាធរមានចាប់ពីដើមឆ្នាំ២០១៦។ រដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការមួយ ដើម្បីគ្រប់គ្រងការប្រមូលថវិកានេះ ដែលមានក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអន្តរក្រសួងរៀបចំគណៈកម្មាធិការនេះ។

តំណាងរាស្ត្រពីគណបក្សប្រឆាំង បានសាទរនឹងចំណាត់ការនេះ និងបានអះអាងថាចំណូលបានមកពីការលក់សំបុត្រចូលទស្សនាប្រាសាទអង្គរវត្ត អាចនឹងកើនឡើងបានពី ៥០ ទៅ១០០លានដុល្លារ ក្នុងមួយឆ្នាំបន្ថែមទៀត នៅពេលរដ្ឋាភិបាលគ្រប់គ្រងការប្រមូលចំណូលនេះ។ តំណាងរាស្ត្រក៏មានជំនឿដែរថា ក្រសួងពាក់ព័ន្ធអាចមានសមត្ថភាពគ្រប់គ្រងការងារនេះបានល្អ ប្រសិនបើមានកិច្ចសហការគ្នាល្អ មានការទទួលខុសត្រូវ និងបំពេញការងារដោយតម្លាភាព។ មួយវិញទៀតការគ្រប់គ្រងដោយស្ថាប័នរបស់រដ្ឋាភិបាលនេះ គឺនឹងបើលទ្ធភាពឲ្យរដ្ឋសភាអាចកោះហៅមន្ត្រីដែលពាក់ព័ន្ធមកសាកសួរបាន បើសិនការគ្រប់គ្រងនោះមានភាពចូររលុង ឬគ្មានតម្លាភាព។

ចំពោះការយកកម្រៃសេវាថែទាំ និងជួសជុលផ្លូវជាតិលេខ៤ អ្នកតំណាងរាស្ត្រ សុន ឆ័យ ជាបន្តបន្ទាប់បានធ្វើការទាមទារឲ្យមានការលុបចោលកិច្ចព្រមព្រៀងនេះតាំងពីនីតិកាលកន្លងៗមកនៃរដ្ឋសភា។ ឯកឧត្តមបានលើកឡើងថា ការផ្តល់សិទ្ធិទៅក្រុមហ៊ុន AZ គឺមិនមានតម្លាភាព និងមិនមានការដេញថ្លៃ ហើយវាជាអំពើពុករលួយមួយ ព្រោះថា ផ្លូវជាតិលេខ៤នេះស្ថិតក្រោមកិច្ចព្រមព្រៀង ស្ថាបនា ប្រតិបត្តិការ និងចែករំលែក (BOT) ប៉ុន្តែនៅពេលនេះ វាបានផ្ទុយពីកិច្ចព្រមព្រៀងនេះ។ ឯកឧត្តមបន្ថែមថា ចំណូលពីការប្រមូលថវិកា មិនសមាមាត្រនឹងទំហំដែលក្រុមហ៊ុននេះ ធ្វើការថែទាំ និងជួសជុលផ្លូវជាតិមួយនេះ។ មួយវិញទៀត ការបញ្ឈប់ការយកកម្រៃនេះក៏ដើម្បីបន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋផងដែរ។

ទាក់ទងបញ្ហានេះ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ រដ្ឋាភិបាល បានចេញសេចក្តីសម្រេចស្តីពីការលុបចោលនូវកិច្ចព្រមព្រៀងសម្បទានរវាងរដ្ឋាភិបាល និងក្រុមហ៊ុន AZ លើការយកកម្រៃសេវាថែទាំ និងជួសជុលផ្លូវជាតិលេខ៤។ ប្រមុខដឹកនាំរដ្ឋាភិបាលបានបញ្ជាក់ថា ការលុបកិច្ចព្រមព្រាងនេះគឺ ដើម្បីប្រយោជន៍ប្រជាជនកម្ពុជា។

គួរបញ្ជាក់ថា ក្រុមហ៊ុន AZ បានចុះកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល ដើម្បីយកលុយពីរថយន្តគ្រប់ប្រភេទ ឆ្លងកាត់ផ្លូវជាតិលេខ៤ ដើម្បីទូទាត់កម្រៃថែរក្សា និងជួសជុលផ្លូវមួយនេះ ចាប់តាំងពីថ្ងៃទី២៨ ខែមិនា ឆ្នាំ២០០១ ក្នុងកុងត្រា រយៈពេល ៣៥ ឆ្នាំ។ ផ្លូវជាតិលេខ៤ ដែលត្រូវបានសាងសង់ឡើង ក្រោមមូលនិធិសប្បុរសធម៌របស់ប្រជាជនអាមេរិក។

នៅក្នុងរយៈពេលនេះ ខុមហ្វ្រែលទទួលទិន្នន័យអំពីការចេញលិខិតរបស់អ្នកតំណាងរាស្ត្រចំនួន៣៦ច្បាប់ ថ្វាយ/ជូនព្រះមហាក្សត្រ រាជរដ្ឋាភិបាល រដ្ឋសភា និងស្ថាប័នសារព័ត៌មាន ក្នុងគោលបំណងភាគច្រើនស្នើ ឬអំពាវនាវវិធានការពីស្ថាប័ននីតិប្រតិបត្តិ ដើម្បីអន្តរាគមន៍រកដំណោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។

លិខិតទាំងនោះស្ទើរទាំងអស់ធ្វើឡើងដោយតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ដែលក្នុងនោះលិខិតក្នុងគោលបំណងអំពាវនាវ/ស្នើចាត់វិធានការចំនួន២៦ច្បាប់ ដែលក្នុងនោះ ២ច្បាប់គឺការស្នើឲ្យកែតម្រូវអត្ថបទព័ត៌មាន លិខិតក្នុងគោលបំណងកោះហៅរដ្ឋមន្ត្រីរដ្ឋាភិបាលមកបំភ្លឺនៅគណៈកម្មការជំនាញនៃរដ្ឋសភាចំនួន៥ច្បាប់ លិខិតក្នុងគោលបំណងដាក់សំណួរចំនួន២ច្បាប់ និងបញ្ចេញមតិចំនួន៣ច្បាប់។ ខុមហ្វ្រែលបានទទួលព័ត៌មានថា មានលិខិតចំនួន៩ច្បាប់ មានការឆ្លើយតបពីរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។ ក្នុងចំណោមលិខិតទាំងនោះ មានលិខិតចំនួន១៤ច្បាប់ ធ្វើឡើងដោយក្រុមអ្នក

តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ។ ជាមួយគ្នានេះលិខិតចំនួន ៤ច្បាប់ ត្រូវបានបដិសេធមិនធ្វើការបញ្ជូនដោយប្រធានរដ្ឋសភា។

ជាក់ស្តែងកាលពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៥ សម្តេច ហេង សំរិន ប្រធានរដ្ឋសភាបានបដិសេធមិនបញ្ជូនលិខិតរបស់អ្នកតំណាងរាស្ត្រ អ៊ុំ សំអាន មណ្ឌលសៀមរាប ពីគណបក្សសង្គ្រោះជាតិ ដែលស្នើសុំឲ្យរដ្ឋាភិបាលបញ្ឈប់កិច្ចសន្យាសម្បទានឲ្យក្រុមហ៊ុន សុខា អូតែល របស់ឧកញ៉ា សុខ គង់ ក្នុងការប្រមូលចំណូលពីការលក់ប័ណ្ណឲ្យភ្ញៀវទេសចរបរទេសចូលទស្សនាអង្គរ។ សម្តេច ហេង សំរិន បដិសេធមិនបញ្ជូលលិខិតនោះ ដោយបានចារថា «ខ្ញុំគិតថា កិច្ចការនេះទុកឲ្យគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសវនកម្ម នៃរដ្ឋសភាជាអ្នកធ្វើវិញ»។

មាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញចែងថា «តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា»។ យោងតាមមាត្រាគ្មានលក្ខខណ្ឌណាមួយដែលប្រធានរដ្ឋសភាមានសិទ្ធិបដិសេធក្នុងការបញ្ជូនលិខិតរបស់តំណាងរាស្ត្រទៅរដ្ឋាភិបាលនោះទេ។ ករណីនេះ គឺជាការប្រើសិទ្ធិអំណាចជាប្រធានសភាហួសព្រំដែន។

ខ្លឹមសារក្នុងលិខិតបានបញ្ជាក់ថា ផ្អែកលើការគណនារបស់ឯកឧត្តម ចំណូលពីការលក់ប័ណ្ណឲ្យភ្ញៀវទេសចរបរទេសចូលទស្សនាអង្គរវត្តសម្រាប់ឆ្នាំ២០១៤ គួរតែទទួលបាន១៤៤លានដុល្លារ មិនមែន៥៩លានដុល្លារ ដូចរបាយការណ៍របស់អាជ្ញាធរជាតិអប្សរានោះទេ ដែលចំនួននេះខុសគ្នាដល់ទៅ៨៥លានដុល្លារ។

លិខិតដ៏កម្រមួយទៀត គឺលិខិតរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលបានកាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ ឯកឧត្តម ប៊ូ ឡាំ តំណាងរាស្ត្រមណ្ឌលខេត្តរតនគិរី បានស្នើទៅប្រធានគណៈកម្មការទី៤នៃរដ្ឋសភាឲ្យផ្លាស់ប្តូរតំណែងលោក អ៊ុក សំអុល អភិបាលក្រុងបានលុង បន្ទាប់ពីទទួលបណ្តឹងពីប្រជាពលរដ្ឋផ្ទាល់ រឿងការប្រើអំណាចបំពានលើប្រជាពលរដ្ឋ។ ជុំវិញលិខិតអន្តរាគមន៍នេះ ត្រូវបាន ឯកឧត្តម ហ៊ុន ណេង ប្រធានគណៈកម្មការទី៤នៃរដ្ឋសភា លើកឡើងថា ឯកឧត្តមមិនមានភារកិច្ចចាត់ចែងការសំណុំរឿងនេះទេ ដោយលើកហេតុផលថា កិច្ចការដកហូតដំណែងនេះ គឺជាភារៈរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ។ គួរបញ្ជាក់ថា នេះលើកទី១ហើយ ដែលតំណាងរាស្ត្រមកពីគណបក្សប្រជាជនស្នើឲ្យដកតំណែងជាមន្ត្រីមកគណបក្សកាន់អំណាចដូចគ្នា។

*<u>តារាងទី៦៖ ឈ្មោះអ្នកតំណាងរាស្ត្រ ដែលបានចេញលិខិត និងគោលបំណងនៃលិខិត</u>*

| លរ | គោត្តនាមនិងនាម | គណបក្ស | ចំនួន | គោលបំណងនៃលិខិត | | | | | ការឆ្លើយតប |
|---|---|---|---|---|---|---|---|---|---|
| | | | | អន្តរាគ | អំពាវន | បញ្ជោ | ដាក់ស | បំ សភ | |
| ១ | កែ សុវណ្ណរតន៍ | | ១ | | | | | ១ | ១ |
| ២ | ឯកឧត្តម គឹម សុខា | | ២ | | ២ | | | | ១ |
| ៣ | ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ | | ៥ | | ១ | | | ៤ | ៤ |
| ៤ | ក្រុមតំណាងរាស្ត្រ | | ១៤ | | ១៣ | | ១ | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៥ | ឯកឧត្តម អ៊ុំ សំអាន | | ១០ | | ៨ | ១ | ១ | | ២ |
| ៦ | ឯកឧត្តម ប៊ូ ឡាំ | | ១ | | ១ | | | | ១ |
| ៧ | ឯកឧត្តម រៀល ខេមរិន្ទ្រ | | ២ | | | ២ | | | |
| ៨ | ឯកឧត្តម សម រង្ស៊ី | | ១ | | ១ | | | | |
| **សរុប** | | | ៣៦ | ០ | ២៦ | ៣ | ២ | ៥ | ៩ |

## V. សំឡេង ឬការផ្តល់ពិន្ទុរបស់ម្ចាស់ឆ្នោតចំពោះអ្នកតំណាងរាស្ត្រ

នៅចុងឆ្នាំ២០១៥ ខុមហ្វ្រែលបានរៀបចំនូវកម្មវិធីមួយទៀតដែលហៅថា «សំឡេងម្ចាស់ឆ្នោត ឬហៅថា Tracking MPs» ជាកម្មវិធីមួយនៃគម្រោងអង្កេតរដ្ឋសភា និងតំណាងរាស្ត្រ។ កម្មវិធីនេះមានបំណងឲ្យប្រជាពលរដ្ឋផ្តល់ឲ្យពួកគាត់ សម្តែងនូវការយល់ឃើញចំពោះតំណាងរាស្ត្រតាមរយៈការផ្តល់ពិន្ទុ។ កម្មវិធីនេះបានដាក់ឲ្យដំណើរចាប់ពីខែតុលា ឆ្នាំ២០១៥ មកដោយអនុញ្ញាតឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោតចូលរួមតាមរយៈគេហទំព័រ និងធ្វើការទាញយកមកប្រើប្រាស់កម្មវិធីជាមួយទូរស័ព្ទដៃ ដោយមិនចាំបាច់ភ្ជាប់សេវាអ៊ីនធឺណេតផងដែរ។

កម្មវិធីសំឡេងម្ចាស់ឆ្នោត បានផ្តល់ជូនដល់ប្រជាពលរដ្ឋម្ចាស់ឆ្នោតអាចមានលទ្ធភាពទទួលបានព័ត៌មានពីសកម្មភាពរបស់អ្នកតំណាងរាស្ត្រ ការផ្តល់ពិន្ទុដល់តំណាងរាស្ត្រដែលខ្លួនពេញចិត្ត អាចដាក់ជាសំណួរដល់តំណាងរាស្ត្ររូបណាមួយដែលខ្លួនមានចម្ងល់អំពីសកម្មភាពក្នុងសង្គម ឬចង់ឲ្យជួយដោះស្រាយដល់មូលដ្ឋានរបស់ខ្លួននោះ។ ជាងនេះកម្មវិធីក៏បានអនុញ្ញាតឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោតមានលទ្ធភាពមើល និងស្វែងរកនូវប្រវត្តិរូបសង្ខេបរបស់តំណាងរាស្ត្រទាំង១២៣រូប គ្រប់អាណត្តិផងដែរ។

ក្នុងរយៈពេល ៣ខែចុងឆ្នាំ ប្រជាពលរដ្ឋម្ចាស់ឆ្នោតបានចូលរួមប្រើប្រាស់ព័ត៌មាននៅក្នុងកម្មវិធីនេះមានចំនួន ៣៨៥អ្នកប្រើប្រាស់ និងបានចូលរួមមើលទំព័រព័ត៌មានចំនួន ៨៩៣ទំព័រ។ ក្នុងនោះផងដែរ កម្មវិធីសំឡេងម្ចាស់ឆ្នោត ក៏បានឲ្យប្រជាពលរដ្ឋមានលទ្ធភាពដឹង និងចូលរួមប្រើប្រាស់នៅក្នុងទំព័រព័ត៌មានសង្គម (ហ្វេសប៊ុក-Facebook) ផងដែរ។ គិតមកត្រឹមចុងខែធ្នូ ឆ្នាំ២០១៥ មានអ្នកចូលរួម Like Page ចំនួន ៣១៨៩ គណនេយ្យ។

ទោះបីកម្មវិធីសំឡេងម្ចាស់ឆ្នោត (Tracking MPs) បានបង្កើតឲ្យមានប្រព័ន្ធដំណើរការក្នុងការចូលរួមវាយតម្លៃ និងផ្តល់ព័ត៌មាន តាមរយៈការផ្សព្វផ្សាយចំណេះដឹងដល់យុវជន ឬម្ចាស់ឆ្នោតទូទៅ នៅលើគេហទំព័រ ឬប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏ដោយ ក៏ខុមហ្វ្រែសង្កេតឃើញនៅតែមានការចូលរួមរបស់ម្ចាស់ឆ្នោតមិនទាន់មានផុលផុសនៅឡើយ។

ក្នុងរយៈពេល ៣ខែចុងឆ្នាំ២០១៥ ជាលទ្ធផលបានបង្ហាញថា កម្មវិធីនេះមានអ្នកចូលរួមផ្តល់ពិន្ទុចំនួន៨៨នាក់ដល់អ្នកតំណាងរាស្ត្រចំនួន៥៣រូប។ ក្នុងនោះតំណាងរាស្ត្រ១០រូប ត្រូវបានផ្តល់ពិន្ទុខ្ពស់ជាងគេជាមួយការវាយតម្លៃពីម្ចាស់ឆ្នោតមានលេខរៀង ១.ឯកឧត្តម សមរង្ស៊ី, ២.សម្តេច ស ខេង, ៣.ឯកឧត្តម កឹម សុខា, ៤.ឯកឧត្តម សុន ឆ័យ, ៥.ឯកឧត្តម ឈាង វុន, ៦.ឯកឧត្តម គង់ បូរ៉ា, ៧.ឯកឧត្តម ងួន ញិល, ៨.ឯកឧត្តម កែប ជុតិមា, ៩.ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ និង១០.សម្តេច ហ៊ុន សែន។ ពិន្ទុគឺនិយាយទៅដល់ចំនួនផ្កាយ ដែលទទួលបាន។ ក្នុងចំណោម ១០រូបនោះ គឺបានផ្កាយចំនួនពីរ រហូតដល់ចំនួន ៥ផ្កាយ។

| ចំនួនផ្កាយ ★★★★★ | អធិប្បាយអត្ថន័យ |
|---|---|
| ១ | មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច (0%-20%) |
| ២ | ពេញចិត្តខ្លះ (21%-40%) |
| ៣ | ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្ដាល (41%-60%) |
| ៤ | ពេញចិត្តច្រើន )61%-80%) |
| ៥ | ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង (81%-100%) |

## VI. សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទងសភា និងតំណាងរាស្ត្រ

### ៦.១ រដ្ឋសភាកែសម្រួលអ្នកនាំពាក្យ

រដ្ឋសភាបានសម្រេចតែងតាំងអ្នកនាំពាក្យរបស់តំណាងរាស្ត្រ នៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិនៅរដ្ឋសភា។ ការតែងតាំងនេះធ្វើឡើងក្នុងសេចក្ដីសម្រេចរបស់ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ដែលឯកឧត្តម ឈាង វុន ជាអ្នកនាំពាក្យរបស់តំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា ហើយឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ ជាអ្នកនាំពាក្យរបស់តំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិ។ ទន្ទឹមគ្នានេះដែររដ្ឋសភាបានសម្រេចតែងតាំងឯកឧត្តម ឡេង ប៉េងឡុង ជាអ្នកនាំពាក្យរបស់រដ្ឋសភា។ អ្នកនាំពាក្យរបស់រដ្ឋសភា មានតួនាទី និងភារកិច្ចជម្រាបសាធារណជនអំពីព័ត៌មាននានាពាក់ព័ន្ធរដ្ឋសភា ខណៈអ្នកនាំពាក្យរបស់តំណាងរាស្ត្រនៃគណបក្សនីមួយៗមានសិទ្ធិធ្វើការបំភ្លឺ អំពីគោលនយោបាយ និងគោលជំហររបស់គណបក្សខ្លួន។

គួររំលឹកថា កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ កន្លងទៅ រដ្ឋសភាបានសម្រេចបង្កើតឱ្យមានអ្នកនាំពាក្យជាផ្លូវការរបស់ខ្លួន ដែលមានឯកឧត្តម ឈាង វុន តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មការទី៥នៃរដ្ឋសភាជាអ្នកនាំពាក្យ និងលោកជំទាវ ជូឡុង សូមូរ៉ា ជាអ្នកនាំពាក្យបម្រុង។ ក្នុងសេចក្ដីសម្រេចពេលនោះ បានបញ្ជាក់អំពីតួនាទី និងភារកិច្ចរបស់អ្នកនាំពាក្យ ក្នុងការរៀបចំឯកសារផ្សព្វផ្សាយព័ត៌មាន និងធ្វើការបំភ្លឺជូនសាធារណជនចំពោះព្រឹត្តិការណ៍ និងសភាពការណ៍នយោបាយជាតិ និងអន្តរជាតិសំខាន់ៗមកលើរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

ពាក់ព័ន្ធនឹងការបង្កើតអ្នកនាំពាក្យនាពេលនោះ ការសង្កេតឃើញថា ហាក់មិនបានឈរលើគោលការណ៍វិជ្ជាជីវៈត្រឹមត្រូវ ក្នុងការតែងតាំងអ្នកនាំពាក្យនោះទេ។ រដ្ឋសភានីតិកាលទី៥នេះ មានគណបក្សនយោបាយចំនួនពីរទទួលបានអាសនៈ ដូច្នេះអ្នកនាំពាក្យនៃរដ្ឋសភា គួរតែជាមនុស្សដែលវិជ្ជាជីវៈសារព័ត៌មាន ដែលមិនមែនអ្នកតំណាងរាស្ត្រនៃគណបក្សណាមួយដែលមានអាសនៈក្នុងរដ្ឋសភានោះទេ។ ជារឿយៗ ឯកឧត្តម ឈាង វុន តែងតែធ្វើសន្និសីទសារព័ត៌មាន ដើម្បីឆ្លើយតបទៅនឹងមតិរិះគន់ និងការចោទប្រកាន់នានាមកលើថ្នាក់ដឹកនាំរដ្ឋសភាមកពីគណបក្សប្រជាជនកម្ពុជា ពិសេសការចោទប្រកាន់ធ្វើឡើងដោយអ្នកតំណាងរាស្ត្រនៃគណបក្សប្រឆាំង។ ត្រង់ចំណុចសរបញ្ជាក់ឲ្យឃើញថា ការបំពេញភារកិច្ចការងារក្នុងនាមជាអ្នកនាំពាក្យ គឺធ្វើដើម្បីការពារតែផលប្រយោជន៍គណបក្សខ្លួន មិនមែនដើម្បីប្រយោជន៍រួមនោះទេ។

ដោយពិនិត្យឃើញថា អ្នកនាំពាក្យរបស់រដ្ឋសភាមិនមែនតំណាងឲ្យរដ្ឋសភា ព្រោះថា បានបង្ហាញជំហរនយោបាយរបស់គណបក្សខ្លួនទៅកាន់ប្រព័ន្ធផ្សព្វផ្សាយច្រើនជាងជំហររបស់រដ្ឋសភា អ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិនៅខែកញ្ញា ឆ្នាំ២០១៥ បានស្នើឲ្យមានអ្នកនាំពាក្យនៅក្នុងរដ្ឋសភាមកពីតំណាងគណបក្សនយោបាយនីមួយៗ ដែលមានអាសនៈក្នុងរដ្ឋសភា។

រហូតមកដល់អំឡុងខែវិច្ឆិកា ឆ្នាំ២០១៥ រដ្ឋសភាបានសម្រេចកែសម្រួលអ្នកនាំពាក្យរបស់តំណាងរាស្ត្រនៃគណបក្សនីមួយៗក្នុងរដ្ឋសភា និងអ្នកនាំពាក្យរបស់រដ្ឋសភា។ បើទោះជាមានការកែសម្រួលថ្មីនេះក៏ដោយ មានការព្រួយបារម្ភអំពីប្រសិទ្ធភាពការងារ ព្រោះថា តួនាទី និងភារកិច្ចរបស់អ្នកនាំពាក្យទាំងនោះហាក់នៅមិនទាន់ច្បាស់លាស់ ដែលអាចធ្វើឲ្យអ្នកនាំពាក្យទាំងនោះធ្វើការដោយមិនឈរលើគោលការណ៍វិជ្ជាជីវៈត្រឹមត្រូវ និងបម្រើឲ្យសេចក្តីត្រូវការព័ត៌មានរបស់សាធារណជន។

### ៦.២ ករណីលាលែងពីតំណាងរាស្ត្ររបស់ឯកឧត្តម វ៉ាន សំអឿន

ឯកឧត្តម វ៉ាន សំអឿន ជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពត ពីគណបក្សសង្គ្រោះជាតិ បានផ្ញើលិខិតមួយច្បាប់ជូនប្រធានរដ្ឋសភា ស្នើសុំលាលែងពីអ្នកតំណាងរាស្ត្រ។ ឯកឧត្តមបានលើកមូលហេតុថា ឯកឧត្តមគ្មានឱកាសនឹងបម្រើប្រទេសជាតិតាមឆន្ទៈ និងបទពិសោធន៍របស់ខ្លួន។

បើទោះជាមានដាក់ការសង្ស័យថា ចាកចេញរបស់តំណាងរាស្ត្ររូបនេះ ដើម្បីជាថ្នូរនឹងផលប្រយោជន៍អ្វីមួយពីគណបក្សកាន់អំណាច ប៉ុន្តែនេះជាគំរូដែលបញ្ជាក់ពីតម្លាភាពក្នុងការលាឈប់ពីតំណាងរាស្ត្រ។ ការផ្លាស់តំណាងរាស្ត្រក្នុងរយៈពេលកន្លងមកត្រូវបានមើលឃើញថា ធ្វើឡើងតាមឆន្ទៈរបស់ប្រធានគណបក្ស ហើយការផ្លាស់ប្តូរទៀតសោត គឺមិនបញ្ជាក់អំពីមូលហេតុច្បាស់លាស់ពីសាម៉ីខ្លួនដែលលាឈប់នោះទេ។

### ៦.៣ ការគំរាមអ្នកតំណាងរាស្ត្រដែលបានធ្វើការចោទសួរទាក់ទងថវិការដ្ឋសភា

ឯកឧត្តម សុន ឆ័យ អនុប្រធានគណៈកម្មការទី២នៃរដ្ឋសភា ត្រូវបានថ្នាក់ដឹកនាំរដ្ឋសភាពីគណបក្សប្រជាជនកម្ពុជាចោទប្រកាន់ថា កំពុងធ្វើឲ្យមានភាពល្អក់កករដល់ទំនាក់ទំនងគណបក្សទាំងពីរ។ ឯកឧត្តម ឈាង វុន អ្នកនាំពាក្យរបស់រដ្ឋសភាបានរៀបចំសន្និសីទសារព័ត៌មាន ដើម្បីច្រានចោលរាល់ការចោទប្រកាន់របស់ឯកឧត្តម សុន ឆ័យ ទាក់ទងបញ្ហាមិនប្រក្រតីក្នុងការចាយវាយថវិការបស់រដ្ឋសភា ដោយលើកឡើងថា ការចោទប្រកាន់ទាំងនោះ គឺគ្មានមូលដ្ឋានត្រឹមត្រូវ។ ជាមួយគ្នានេះឯកឧត្តម សុន ឆ័យ ទទួលការគំរាមថា រដ្ឋសភាអាចនឹងដកចេញពីតួនាទីអនុប្រធានគណៈកម្មការទី២ ប្រសិនឯកឧត្តមនៅបន្តធ្វើការចោទប្រកាន់រដ្ឋសភា។ ជាមួយគ្នានេះ ឯកឧត្តម ជាម យៀប ប្រធានគណៈកម្មការទី២ ក៏បានធ្វើសន្និសីទសារព័ត៌មាន ដើម្បីការពារអគ្គលេខាធិការដ្ឋាននៃរដ្ឋសភាថា ការប្រើប្រាស់ថវិកាកន្លងមករបស់រដ្ឋសភា គឺត្រឹមត្រូវ ហើយឯកឧត្តមបានស្នើប្រធានរដ្ឋសភាធ្វើការណែនាំឯកឧត្តម សុន ឆ័យ ដោយឯកឧត្តមចោទប្រកាន់ថា បានធ្វើខុសបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

ជុំវិញការចោទប្រកាន់នេះ ឯកឧត្តម សុន ឆ័យ បានអះអាងថា ឯកឧត្តមមិនបានធ្វើខុសនីតិវិធី ហើយអ្វីដែលឯកឧត្តមចោទប្រកាន់ គឺមានការសិក្សាច្បាស់លាស់ ហើយឯកឧត្តមតែងតែទាមទារសុំឲ្យអគ្គលេខាធិការរដ្ឋសភាផ្តល់ឯកសារចំណាយទាំងនោះ ដើម្បីធ្វើការផ្ទៀងផ្ទាត់ ប៉ុន្តែមិនមានការឆ្លើយតបទេ បើទោះបីជាឯកឧត្តមបានស្នើសុំអន្តរាគមន៍ពីប្រធានរដ្ឋសភា។ ឯកឧត្តមក៏ធ្លាប់បានស្នើឲ្យគណៈកម្មការទី២នៃរដ្ឋសភា និងអង្គភាពប្រឆាំងអំពើពុករលួយធ្វើការស៊ើបអង្កេតការប្រើប្រាស់ថវិកានេះដែរកន្លងមក ប៉ុន្តែមិនទាន់មានការស៊ើបអង្កេតនៅឡើយ ហើយថ្នាក់ដឹកនាំរដ្ឋសភាតែងតែចេញមុខការពារថា ការចាយវាយរបស់រដ្ឋសភាកន្លងមក គឺត្រឹមត្រូវ និងគ្មានអំពើពុករលួយនោះទេ។

### ៦.៤ ក្រុមការងារ ឬគណៈកម្មការចម្រុះគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ

ក្រៅពីការបង្កើតវប្បធម៌សន្ទនារវាងប្រមុខដឹកនាំគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ នៅកម្រិតតំណាងរាស្ត្រ គណបក្សទាំងពីរបានបង្កើតក្រុមការងារ ឬគណៈកម្មការចម្រុះ ដើម្បីតាក់តែងសេចក្តីស្នើច្បាប់ ឬនិងពិនិត្យកែលំអរច្បាប់មួយចំនួន។

ក្នុងឆ្នាំ២០១៥នេះ ក្រុមការងារ ឬគណៈកម្មការចម្រុះនៃគណបក្សទាំងពីរ បានរៀបចំសេចក្ដីស្នើច្បាប់ និងសេចក្ដីស្នើវិសោធនកម្មច្បាប់ចំនួន ៤ ហើយត្រូវបានអនុម័តដោយរដ្ឋសភា។ សេចក្ដីស្នើច្បាប់ និងសេចក្ដីស្នើវិសោធនកម្មច្បាប់ទាំងនោះរួមមានដូចជាៈ ១.ច្បាប់ស្ដីពី វិសោធនកម្មមាត្រា ២៣ នៃច្បាប់ស្ដីពីលក្ខន្តិកៈតំណាងរាស្ត្រ, ២.ច្បាប់ស្ដីពីភតិសន្យាពិសេស, ៣.ច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ និង៤.វិសោធនកម្មប្រការ៣ថ្មី, ៧ថ្មី, ៨, ១០ថ្មី(ពីរ), ១៤ថ្មី, ១៨, ២០, ២១, ២២ថ្មី, ៣១ថ្មី(ពីរ), ៣៣ថ្មី, ៣៤, ៣៦ថ្មី,៣៨ថ្មី,៤០ថ្មី និងប្រការ៤៧ថ្មី(បី)នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។ ជាមួយគ្នានេះដែល ក្រុមការងារ ឬគណៈកម្មការចម្រុះនៃគណបក្សទាំងពីរ កំពុងតែពិនិត្យ និងពិភាក្សាអំពីសេចក្ដីព្រាងច្បាប់ស្ដីពីសហជីព។

## ៦.៥ តំណាងរាស្ត្រ និងបញ្ហាព្រំដែន

បញ្ហាព្រំដែនជាមួយប្រទេសជិតខាង ពិសេសប្រទេសវៀតណាមជាបញ្ហាក្ដៅដែលក្រុមអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានធ្វើសកម្មភាពខ្លាំងក្នុងរយៈពេលចុងក្រោយនេះ។ សកម្មភាពទាំងនោះរួមមាន ការចុះពិនិត្យដល់ទីកន្លែងដែលមានការរំលោភចូលដោយភាគីវៀតណាម និងការស្នើឲ្យមានការបំភ្លឺ និងធ្វើការដោះស្រាយពីរាជរដ្ឋាភិបាលតាមយន្តការរដ្ឋសភាជាដើម។ បញ្ហាព្រំដែននេះ ត្រូវបានគណបក្សប្រឆាំងរកឃើញថា ប្រទេសវៀតណាមបានរំលោភចូលទឹកដីកម្ពុជា ដូចជាករណីនៅច្រកដាក់ដាំ ខេត្តមណ្ឌលគិរី នៅខ្សែបន្ទាប់រវាងកម្ពុជា-វៀតណាមក្នុងខេត្តស្វាយរៀង នៅឃុំកក់ ស្រុកពញាក្រែក និងភូមិជើង ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងព្រមទាំងនៅច្រកទាន់ហាន់ ឃុំព្រែកគ្រីស ស្រុកកំពង់ត្រាច ខេត្តកំពតជាដើម។

ជាក់ស្ដែង ក្រុមអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិបានដឹកនាំក្រុមការងារចុះពិនិត្យនៅតាមព្រំដែន និងធ្វើសកម្មភាពមួយចំនួនដូចជាៈ

- ថ្ងៃទី២៦ ខែមេសា ចុះទៅពិនិត្យតំបន់ព្រំដែនកម្ពុជា-វៀតណាម នៅត្រង់បង្គោលឡាក់លេខ១២៥ និង១៣០ ស្ថិតក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។
- នៅថ្ងៃទី០៣ និងថ្ងៃទី២៧ ខែឧសភា ចុះពិនិត្យករណីវៀតណាមធ្វើផ្លូវរំលោភចូលដីកម្ពុជាក្នុងឃុំដូង ស្រុកចន្ទ្រា និងនៅឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។
- ថ្ងៃទី១៤ ខែឧសភា ចុះពិនិត្យការជីកព្រែកចូលដីកម្ពុជាពីភាគីវៀតណាមនៅឃុំព្រែកគ្រីស ស្រុកកំពង់ត្រាច ខេត្តកំពត។ ករណីនេះ អ្នកតំណាងរាស្ត្រក៏បានធ្វើលិខិតទៅរដ្ឋាភិបាលឲ្យធ្វើការឆ្លើយបំភ្លឺ តែត្រូវបានតំណាងរដ្ឋាភិបាលបដិសេធ ដោយលើកឡើងថា ការចោទប្រកាន់អំពីការរំលោភនោះគ្មានមូលដ្ឋានច្បាស់លាស់។
- ថ្ងៃទី២៨ ខែឧសភា បានផ្ញើលិខិតទៅសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន ឲ្យផ្ដល់ព័ត៌មានពីឈ្មោះភូមិចំនួនពីរដែលត្រូវដោះដូរទៅឲ្យវៀតណាម ជំនួសភូមិពីរដែលជាភូមិកំណើតរបស់ប្រធានរដ្ឋសភា សម្ដេច ហេង សំរិន។ ចំពោះសំណើនេះសម្ដេច ហ៊ុន សែន បានឆ្លើយតបតាមរយៈលិខិតចុះថ្ងៃទី១៤ ខែមិថុនាថា សម្ដេចធ្លាប់បានបញ្ជាក់រួចហើយកាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ ២០១២ កន្លងមក នៅក្នុងការឆ្លើយបំភ្លឺរបស់ខ្លួនជាង៥ម៉ោងនៅរដ្ឋសភា។
- ថ្ងៃទី៣១ ខែឧសភា ចុះពិនិត្យករណីអាជ្ញាធរ និងពលរដ្ឋវៀតណាមបាញ់ថ្នាំបំផ្លាញផលដំណាំកសិករខ្មែរនៅភូមិជើង ឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ករណីនេះ រដ្ឋមន្ត្រីក្រសួងការបរទេសឯកឧត្ដម ហោ ណាំហុង បានធ្វើលិខិតបំភ្លឺទៅប្រធានរដ្ឋសភាថា កសិករខ្មែរបានដាំដំណាំលើទឹកដីវៀតណាម។
- ថ្ងៃទី០២ ខែមិថុនា បានដាក់លិខិតទៅសម្ដេចនាយករដ្ឋមន្ត្រីហ៊ុន សែន ស្នើសុំឲ្យពិនិត្យមើលព្រំដែននៅភ្នំដិនក្នុងស្រុកគិរីវង់ ខេត្តតាកែវ ដោយអះអាងថា វៀតណាមបានរំកិលព្រំដែនចូលមកទឹកដីកម្ពុជា។
- ថ្ងៃទី០៣ ខែមិថុនា បានផ្ញើលិខិតស្នើសុំឲ្យរដ្ឋាភិបាលផ្ដល់ផែនទី ដែលត្រូវបានប្រើប្រាស់សម្រាប់បោះបង្គោលព្រំដែន កម្ពុជា វៀតណាម និងស្នើពន្យល់លម្អិតអំពីនីតិវិធីនៃដំណើរការបោះបង្គោលព្រំដែន។ ជុំវិញសំណើនេះនៅ

ថ្ងៃទី១០ គណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែនបានបដិសេធ ក្នុងការផ្តល់ផែនទីផ្លូវការទៅតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ និងបានបញ្ជាក់ថា រាជរដ្ឋាភិបាលធ្លាប់បានឆ្លើយបំភ្លឺច្រើនលើកច្រើនសាហើយ អំពីការបោះបង្គោលព្រំដែនទៅរដ្ឋសភា។ ទាក់ទងនឹងផែនទីនេះដែរ ប្រមុខដឹកនាំរាជរដ្ឋាភិបាល បានសរសេរលិខិតមួយច្បាប់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន ដោយស្នើសុំផែនទីកម្ពុជាដែលតម្កល់នៅអង្គការប្រជាជាតិ ដើម្បីយកមកធ្វើការផ្ទៀងផ្ទាត់ និងបានដាក់លិខិតទៅថ្នាក់ដឹកនាំប្រទេសមហាអំណាចចំនួន៣ គឺ បារាំង អង់គ្លេស និងសហរដ្ឋអាមេរិក ដោយស្នើសុំខ្ចីផែនទី និងសុំជំនួយជាអ្នកជំនាញខាងផែនទី ដើម្បីជួយកម្ពុជាក្នុងការផ្ទៀងផ្ទាត់ផែនទីដែលរដ្ឋាភិបាលកំពុងតែប្រើប្រាស់ផងដែរ។

- ថ្ងៃទី០៨ ខែមិថុនា ចុះពិនិត្យទីតាំងដែលវៀតណាមជីករណ្តៅស្រះទឹក ក្នុងដីដែលត្រួតស៊ីគ្នា រវាងព្រំដែនកម្ពុជា-វៀតណាម នៅចំណុចភូមិឡំ ឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។ ករណីនេះ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា ឯកឧត្តម ហោ ណាំហុង នៅទី១៦ បានធ្វើលិខិតមួយទៅប្រធានរដ្ឋសភា សម្តេច ហេង សំរិន បញ្ជាក់ប្រាប់ថា រាជរដ្ឋាភិបាលបានដាក់កំណត់ទូតទៅរដ្ឋាភិបាលវៀតណាម អំពីការឈ្លានពានរបស់វៀតណាមមកលើដីកម្ពុជានៅតំបន់នោះរួចហើយ។
- ថ្ងៃទី១៣ ខែមិថុនា ចុះពិនិត្យមើលការបោះតម្រុយព្រំដែន នៅចន្លោះបង្គោល ព្រំដែនកម្ពុជា-វៀតណាម លេខ ១៤៧-១៤៨ នៅភូមិធ្នង់ ឃុំថ្នាធ្នង់ ស្រុករំដួល ខេត្តស្វាយរៀង។
- ថ្ងៃទី១៥ ខែមិថុនា បានធ្វើលិខិតទៅសម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន តាមរយៈប្រធានសភាឲ្យពិនិត្យ និងស៊ើរើការបោះតម្រុយព្រំដែននៅចន្លោះបង្គោលព្រំដែនលេខ១៤៧-១៤៨ ដែលថាវៀតណាមបោះចូលទឹកដីកម្ពុជា ធ្វើឲ្យប៉ះពាល់ដីចម្ការប្រជាពលរដ្ឋចំនួន៣០ហិកតា ស្ថិតនៅស្រុករំដួល ខេត្តស្វាយរៀង ដោយមានផ្នូរដូនតាបានបន្សល់ទុកតាំងពីឆ្នាំ១៩៥៩។ នៅថ្ងៃទី៣០ គណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែនបានធ្វើលិខិតមួយទៅប្រធានរដ្ឋសភាដែលមានខ្លឹមសារថា សំណើរបស់ក្រុមតំណាងរាស្ត្រនោះ មិនមានភស្តុតាងពិតប្រាកដទេ។ លិខិតបានអះអាងថា បើយោងតាមផែនទី Bonne ខ្នាត១/១០០០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ការបោះបង្គោលខណ្ឌសីមាព្រំដែននៅតំបន់ខាងលើនេះពុំ ធ្វើឲ្យកម្ពុជាបាត់បង់ដីស្រែចម្ការប្រជាពលរដ្ឋខ្មែរ៣០ហិកតាទៅឲ្យវៀតណាមទេ។
- ថ្ងៃទី២០ ខែមិថុនា ចុះពិនិត្យមើលព្រំដែនកម្ពុជា-វៀតណាម ដែលត្រូវចោទថា ភាគីវៀតណាមជីកដីធ្វើគ្រឹះសម្រាប់ការសាងសង់ប៉ុស្តិ៍យោធារបស់ខ្លួនចូលទឹកដីកម្ពុជា នៅជាប់ភូមិព្រៃកស្បូវ ស្រុកកោះធំ ខេត្តកណ្តាល។
- ថ្ងៃទី២៥ ខែមិថុនា បានចេញសេចក្តីប្រកាសព័ត៌មានមួយទាមទារឲ្យរដ្ឋាភិបាលកម្ពុជា បង្កើតគណៈកម្មាធិការចម្រុះមួយ ដែលមានការចូលរួមពីគណបក្សមានអាសនៈក្នុងសភា និងអ្នកជំនាញពាក់ព័ន្ធដើម្បីអាចចូលរួមដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម និងទាមទារឲ្យរដ្ឋាភិបាលយកករណីនេះទៅតុលាការយុត្តិធម៌អន្តរជាតិ។
- ថ្ងៃទី២៨ ខែមិថុនា ចុះពិនិត្យបង្គោលព្រំដែនលេខ ២០៣ ស្ថិតនៅភូមិធ្លក ឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ ក្នុងអំឡុងពេលចុះពិនិត្យនោះ អំពើហឹង្សាមួយបានកើតឡើងពីសំណាក់ប្រជាពលរដ្ឋវៀតណាម បានបណ្តាលឲ្យអ្នកតំណាងរាស្ត្រ និងប្រជាពលរដ្ឋមួយចំនួនរងរបួស។ ជុំវិញការប្រើអំពើហិង្សានេះ ក្រុមតំណាងរាស្ត្រ គណបក្សប្រឆាំងបានស្នើចំណាត់ការពីរដ្ឋាភិបាល ប៉ុន្តែមិនទាន់ឃើញមានចំណាត់ការណាមួយនៅឡើយ។ ដោយឡែក អាជ្ញាធរខេត្តស្វាយរៀងបានចេញលិខិតមួយ ប្រកាសមិនទទួលខុសត្រូវតាមផ្លូវច្បាប់លើការប៉ះទង្គិចនៅតាមព្រំដែនរវាងប្រជាពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋវៀតណាម ដោយអះអាងថា ក្រុមប្រជាពលរដ្ឋចុះពិនិត្យព្រំដែនមិនបានជូនដំណឹងអាជ្ញាធរខេត្តជាមុន។

- ថ្ងៃទី៦ ខែកក្កដា ផ្ញើលិខិតមួយច្បាប់ទៅឯកឧត្តម វ៉ា គឹមហុង ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែន ស្នើទៅពិនិត្យមើលបង្គោលព្រំដែនកម្ពុជា-វៀតណាមជាមួយគ្នា នៅបង្គោលព្រំដែនកម្ពុជាលេខ ២០២និង២០៣ នៅភូមិធ្លក ឃុំត្នោត ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដែលជាចំណុចមានហិង្សាកើតឡើង កាលពីថ្ងៃទី២៨ ខែមិថុនាកន្លងមក។ សំណើនេះត្រូវបានប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែនធ្វើការបដិសេធ។
- ថ្ងៃទី៦ ខែកក្កដា ដាក់លិខិតទៅថ្នាក់ដឹកនាំរាជរដ្ឋាភិបាល តាមរយៈប្រធានរដ្ឋសភាស្នើសុំឲ្យផ្អាកការបោះបង្គោលព្រំដែនជាមួយប្រទេសវៀតណាមបណ្ដោះអាសន្នសិន ដោយរង់ចាំដល់ឆ្នាំ២០១៨។ ប៉ុន្តែលិខិតនោះ ពុំត្រូវបានប្រធានរដ្ឋសភាបញ្ជូនចេញនោះទេ។
- ថ្ងៃទី១៥ ខែកក្កដា ចុះជួបពលរដ្ឋ និងអាជ្ញាធរនៅខេត្តស្វាយរៀង ដើម្បីផ្សព្វផ្សាយលិខិតរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែនស្រាយបំភ្លឺមករដ្ឋសភា អំពីការបង្គោលលេខ១៤៧-១៤៨ ដែលមានការលើកឡើងថាវៀតណាមបោះចូលទឹកដីកម្ពុជា។
- ថ្ងៃទី១៩ ខែកក្កដា ចុះពិនិត្យមើលបង្គោលព្រំដែន ស្ថិតនៅក្នុងភូមិធ្លក ឃុំត្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។
- ថ្ងៃទី១៤ ខែសីហា ចូលរួមសន្និសីទដែលរៀបចំដោយរាជបណ្ឌិត្យសភាកម្ពុជា ស្ដីពីការពិនិត្យផ្ទៀងផ្ទាត់ផែនទីដែលទទួលបានពីប្រភពចំនួន៤ គឺអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន គណបក្សសង្គ្រោះជាតិ បណ្ណាល័យនៃព្រឹទ្ធសភាអាមេរិក និងបណ្ណាល័យនៃវិទ្យាស្ថានភូមិសាស្ត្រជាតិបារាំង។
- ថ្ងៃទី២០ ខែសីហា ចូលរួមក្នុងពិធីប្រគល់ ទទួល និងផ្ទៀងផ្ទាត់ផែនទីពីអង្គការសហប្រជាជាតិ នៅវិមានសន្តិភាព។
- ថ្ងៃទី០៤ ខែកញ្ញា ដាក់លិខិតទៅឯកឧត្តម វ៉ា គឹមហុង ប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែន ស្នើសុំបកស្រាយជាថ្មីម្ដងទៀត ពាក់ព័ន្ធដីស្រែចំការរបស់ប្រជាពលរដ្ឋចំនួនជាង៣០ហិកតា នៅភូមិធ្នង់ ឃុំថ្នាធ្នង់ ស្រុករំដួល ខេត្តស្វាយរៀង និងសុំឲ្យគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនចុះទៅពិនិត្យជាក់ស្ដែងនៅតំបន់នោះឲ្យបានច្បាស់លាស់។
- ថ្ងៃទី១០ ខែកញ្ញា តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា បានចេញញត្តិគាំទ្រសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពីបញ្ហាប្រើប្រាស់ផែនទី និងកំណត់ព្រំដែនរវាងកម្ពុជា-វៀតណាម។

ជាការកត់សម្គាល់ សកម្មភាពរបស់តំណាងរាស្ត្រ ពិសេសពីគណបក្សសង្គ្រោះជាតិ ទាក់ទងបញ្ហាព្រំដែន បានកាត់បន្ថយស្ទើរតែទាំងស្រុងក្នុងរយៈពេលចុងក្រោយនេះ។ មានការមើលឃើញថា ការកាត់បន្ថយសកម្មភាពខ្លួនក៏ព្រោះតែមានចំណាត់ការផ្ទួនៗពីតុលាការ និងពីរដ្ឋសភាទៅលើសកម្មភាពជន អ្នកតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភានៃគណបក្សប្រឆាំងដែលសកម្មក្នុងការតវ៉ាបញ្ហាព្រំដែនកម្ពុជា-វៀតណាម។

មានការមើលឃើញថា កិច្ចការព្រំដែនកន្លងមក ក្លាយជារឿងសំងាត់របស់រដ្ឋាភិបាល ដោយមិនឲ្យភាគីពាក់ព័ន្ធនានាចូលរួម។ ដោយមិនមានការបើកចំហ និងបង្ហាញនីតិវិធីត្រឹមត្រូវដល់ភាគីពាក់ព័ន្ធពីការងាររបស់រដ្ឋាភិបាលក្នុងបញ្ហានេះ វាបានធ្វើឲ្យមានការមិនជឿទុកចិត្ត និងបានដាក់ការសង្ស័យថា កម្ពុជាបានខាតបង់ទឹកដីឲ្យប្រទេសវៀតណាម នៅស្របពេលដែលប្រជាពលរដ្ឋរស់នៅតាមបន្ទាត់ព្រំដែនបានលើកឡើងពីការរំលោភចូលទឹកដីកម្ពុជាពីភាគីវៀតណាមផងនោះ។ បញ្ហាមួយទៀត គឺមន្ត្រីជំនាញព្រំដែនរដ្ឋាភិបាលធ្លាប់ បានលើកឡើងថា រឿងព្រំដែនជាការងាររបស់រដ្ឋាភិបាល មិនមែនជាការងាររបស់ស្ថាប័ននីតិប្បញ្ញត្តិទេ។ ការលើកឡើងបែបនេះ ជាការទាត់ចោលតួនាទីរបស់ស្ថាប័នកំពូលរបស់ជាតិ ដែលជាស្ថាប័នតំណាងឲ្យប្រជាពលរដ្ឋ និងជាអ្នកត្រួតពិនិត្យការងាររបស់រដ្ឋាភិបាល។

ដើម្បីដោះស្រាយបញ្ហា និងអាចទទួលយកបានពីភាគីពាក់ព័ន្ធនោះ រដ្ឋាភិបាលត្រូវតែដោះស្រាយបញ្ហាព្រំដែនដោយបើកចំហ និងមានតម្លាភាព ដែលមានការចូលរួមពីគណបក្សប្រឆាំង អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ហើយមិនត្រូវឆ្លើយ

ទាំងប្រញាប់ប្រញាល់ ថាព្រំដែនដែលមានជម្លោះនោះ ជារបស់ប្រទេសណាមួយនោះទេ ផ្ទុយទៅវិញត្រូវតែបង្កើតគណៈកម្មការចម្រុះត្រួតពិនិត្យតំបន់ជម្លោះនោះ។

**៦.៦ ការខ្វែងគំនិតគ្នាក្នុងការកោះហៅមន្ត្រីអាជ្ញាធរស្ថាប័នរដ្ឋឲ្យចូលបំភ្លឺក្នុងរដ្ឋសភា**

ការដោះស្រាយជម្លោះដីធ្លីមានភាពយឺតយ៉ាវ និងថែមទាំងមានអំពើហិង្សាទៀតនោះ បានជំរុញឲ្យរដ្ឋសភាមានគម្រោងកោះហៅអភិបាលខេត្តក្រចេះទៅឆ្លើយបំភ្លឺនៅរដ្ឋសភា។ គម្រោងនេះត្រូវបានសង្គមស៊ីវិលធ្វើការលើបញ្ហាដីធ្លី និងពលរដ្ឋមានជម្លោះ បានបង្ហាញការគាំទ្ររបស់ខ្លួនចំពោះយន្តការនេះ ដោយពួកគេយល់ថា វាអាចជំរុញអាជ្ញាធរខេត្តដោះស្រាយជម្លោះដោយមានប្រសិទ្ធភាព និងគោរពសិទ្ធិមនុស្ស។

គណៈកម្មការទី ១ នៃរដ្ឋសភា បានដាក់លិខិតទៅកាន់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមរយៈប្រធានរដ្ឋសភា កាលពីថ្ងៃទី ១៩ ឧសភា ស្នើសុំកោះហៅអភិបាលខេត្តក្រចេះ ឯកឧត្តម សរ ចំរុង មកឆ្លើយបំភ្លឺនៅរដ្ឋសភាអំពីបញ្ហាទំនាស់ដីធ្លី ដែលកំពុងកើតមានជាច្រើនករណីក្នុងខេត្តនេះ។ ចំណែកឯគណៈកម្មការទី១០ ក៏បានដាក់លិខិតទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ៧ ឧសភាផងដែរ ដើម្បីកោះហៅអភិបាលស្រុកល្វាឯម ខេត្តកណ្តាល ទៅឆ្លើយបំភ្លឺពីបញ្ហាពុករលួយ ក្រោយពីទទួលគណៈកម្មការបានទទួលបណ្តឹងពីប្រជាពលរដ្ឋ។

ប៉ុន្តែសំណើទាំងនេះ ត្រូវបានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សម្តេច ស ខេង បានបដិសេធសំណើទាំងនេះ តាមរយៈលិខិតទៅកាន់រដ្ឋសភា កាលពីថ្ងៃទី២៦ ខែឧសភា ដោយបញ្ជាក់ថា អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមានកាតព្វកិច្ចទទួលខុសត្រូវចំពោះមុខរដ្ឋសភាទេ។ ខ្លឹមសារក្នុងលិខិតនោះលើកឡើងថា យោងតាមមាត្រា ១២១ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល ទទួលខុសត្រូវរួមចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល។ សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួនចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភាអំពីការដែលខ្លួនបានប្រព្រឹត្ត។

ជុំវិញការបដិសេធនេះ គណៈកម្មការពាក់ព័ន្ធរបស់រដ្ឋសភាបានឆ្លើយតបថា បញ្ហាទំនាស់ដីធ្លី និងការដោះស្រាយ ព្រមទាំងការចោទប្រកាន់ពីបញ្ហាពុករលួយបានកើតឡើងនៅអាជ្ញាធរថ្នាក់ខេត្ត និងស្រុក ដូច្នេះគួរតែអ្នកទាំងនោះមកបំភ្លឺដោយផ្ទាល់នៅរដ្ឋសភា។

ទាក់ទងនឹងការហៅមន្ត្រីរដ្ឋាភិបាលឲ្យចូលបំភ្លឺក្នុងរដ្ឋសភានេះដែរ ទីស្តីការគណៈរដ្ឋមន្ត្រី បានចេញសេចក្តីជូនដំណឹងមួយចុះថ្ងៃទី៥ ខែមិថុនា ដែលមានខ្លឹមសារថា គ្រប់ក្រសួង ស្ថាប័ន អង្គភាព សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈនានា មុននឹងទទួលជួប ឬទៅបំភ្លឺនៅគណៈកម្មការនានារបស់ស្ថាប័ននីតិបញ្ញត្តិ ឬក្រុមតំណាងរាស្ត្រ ដើម្បីសិក្សា ឬស្វែងយល់ និងផ្តល់ព័ត៌មាននានា ត្រូវមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នដែលជាសមាជិករាជរដ្ឋាភិបាល។ លិខិតបញ្ជាក់បន្ថែមថា ចំពោះការសុំបំភ្លឺ សុំឯកសារ សុំរបាយការណ៍ សុំព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ ឬពាក់ព័ន្ធនឹងពាក្យប្តឹងចោទប្រកាន់អំពើពុករលួយ ត្រូវគោរពតាមច្បាប់ប្រឆាំងអំពើពុករលួយ និងលិខិតបទដ្ឋានគតិយុត្តិនានា។

ជុំវិញសេចក្តីជូនដំណឹងនេះ ត្រូវបានអ្នកតំណាងរាស្ត្រ និងជាថ្នាក់ដឹកនាំគណៈកម្មការជំនាញរដ្ឋសភាពីគណបក្សសង្គ្រោះជាតិបានឆ្លើយតបថា វាប៉ះពាល់ដល់តួនាទីរបស់រដ្ឋសភា ហើយធ្វើឲ្យរដ្ឋសភាកាន់តែចង់ដឹងថា តើមានអ្វីដែលស្ថាប័ននីតិប្រតិបត្តិលាក់បាំង បានជារឹតត្បិតមន្ត្រីរបស់ខ្លួនក្នុងការធ្វើសេចក្តីរាយការណ៍បែបនេះ និងជាចេតនារឹតត្បិតសិទ្ធិរបស់តំណាងរាស្ត្រ ក្នុងការស្នើនូវព័ត៌មាននានា និងពាក់ព័ន្ធអំពើពុករលួយ។

រដ្ឋាភិបាលមិនគួរហាមមន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទៅបំភ្លឺ ឬផ្ដល់ព័ត៌មានជូនរដ្ឋសភាទេ ព្រោះការផ្ដល់សក្ខីកម្ម និងព័ត៌មានលម្អិតរវាងមន្ត្រីអាជ្ញាធរ និងស្ថាប័នរដ្ឋ គឺដើម្បីឲ្យតំណាងរាស្ត្រ និងគណៈកម្មការជំនាញនៃរដ្ឋសភា សិក្សាស្វែងយល់ឲ្យបានស៊ីជំរៅអំពីបញ្ហាអ្វីមួយដែលកើតមានឡើង។ កិច្ចសហការរបស់មន្ត្រីរដ្ឋាភិបាលនឹងជួយឲ្យស្ថាប័ននីតិបញ្ញត្តិទទួលបានព័ត៌មានច្បាស់លាស់គ្រប់ ជ្រុងជ្រោងពីមន្ត្រីអនុវត្តការងារផ្ទាល់ ប៉ុន្តែវាមិនមានន័យថា មន្ត្រីទាំងនោះត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរដ្ឋសភានោះទេ។

### ៦.៧ វប្បធម៌សន្ទនា គឺជាការបិទមាត់ភាគីសន្ទនា?

វប្បធម៌សន្ទនា ត្រូវបានបង្កើតឡើងដោយថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា សម្ដេច ហ៊ុន សែន និងថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ ឯកឧត្ដម សម រង្ស៊ី នៅបន្ទាប់ពីគណបក្សទាំងពីរបានឈានទៅដល់ការបង្កើតកិច្ចព្រមព្រៀងដំណោះស្រាយកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ និងចូលរដ្ឋសភារបស់គណបក្សសង្គ្រោះជាតិ។

សហគមន៍ជាតិ និងអន្តរជាតិបានសាទរចំពោះការបង្កើតវប្បធម៌សន្ទនានេះ ព្រោះស្ថានភាពនយោបាយមានភាពតានតឹងនៅក្រោយការបោះឆ្នោតឆ្នាំ២០១៣ ដោយសារការធ្វើពហិការមិនចូលរដ្ឋសភារបស់គណបក្សប្រឆាំង ការធ្វើបាតុកម្មតវ៉ាជាបន្តបន្ទាប់ទៅលើលទ្ធផលបោះឆ្នោត និងការឈានទៅដល់មានការបង្ក្រាបការតវ៉ា និងប្រើអំពើហិង្សា ព្រមទាំងការចាប់ខ្លួនបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រជាដើម នឹងត្រូវបានដោះស្រាយ។ មួយវិញទៀត ក្របខ័ណ្ឌច្បាប់ (បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា) និងក្រមសីលធម៌សម្រាប់គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ ត្រូវបានបង្កើត ដើម្បីជំរុញការសន្ទនានេះ ដែលកាន់តែបង្ហាញអំពីជំនឿរបស់ភាគីពាក់ព័ន្ធអំពីបញ្ហានេះ។

មិនយូរប៉ុន្មានវប្បធម៌សន្ទនានេះជួបភាពរង្គោះរង្គើ ដោយសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាស្ថាបនិកវប្បធម៌សន្ទនា តែងតែធ្វើការព្រមានលុបចោលវប្បធម៌នេះ និងធ្វើការចោទប្រកាន់ថា វាមិនមានប្រសិទ្ធភាពនោះទេ ដោយសារសម្ដេចមិនអាចទ្រាំបាននឹងការរិះគន់ និងការវាយប្រហារជាបន្តបន្ទាប់របស់ឯកឧត្ដម កឹម សុខា មកលើរូបសម្ដេច និងគណបក្សប្រជាជនកម្ពុជានៅតាមចិញ្ចើមថ្នល់។ សម្ដេចក៏បានពន្យុះឲ្យគណបក្សប្រឆាំងដើរចេញពីរដ្ឋសភា និងព្រមានថា សម្ដេចលែងខ្វល់នឹងទុកចោលចំណុចខ្វែងគំនិតគ្នានៃក្រុមការងាររបស់គណបក្សទាំងពីរ ដែលកំពុងពិភាក្សាលើបញ្ហាកំណែទម្រង់ការបោះឆ្នោត បើទោះបីធ្វើមិនទាន់ពេលបោះឆ្នោតអាណត្តិក្រោយក៏ដោយ។

លើសពីនេះសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវឲ្យតុលាការកាត់ទោសតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ទាំង៧រូប ឲ្យបានឆាប់ ហើយកុំយកបញ្ហានេះមកចោទថា គណបក្សប្រជាជនកម្ពុជាប្រើឥទ្ធិពលលើតុលាការ។ សម្ដេចក៏បានអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ កត់ត្រាទុកនូវពាក្យសម្ដីរបស់ថ្នាក់ដឹកនាំគណបក្សទាំងពីរ ដែលបានប្ដេជ្ញាបង្រួបបង្រួមជាតិ ក្នុងស្មារតីស្មោះត្រង់នឹងគ្នា និងបានស្នើឲ្យថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ បញ្ឈប់នូវគោលនយោបាយលាបពណ៌មកកាន់គណបក្សប្រជាជនកម្ពុជា ថាជាអាយ៉ងយួនដូចពេលកន្លងទៅ។ សម្ដេចនាយករដ្ឋមន្ត្រីក៏បានព្រមានលុបវប្បធម៌សន្ទនាជាបន្តបន្ទាប់ដូចជា បន្ទាប់ពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ព្រមានប្ដឹងសម្ដេច ហេង សំរិន ប្រធានរដ្ឋសភាករណីមិនបញ្ជូនលិខិតតំណាងរាស្ត្រទៅរដ្ឋាភិបាលស្នើសុំឲ្យផ្អាកការបោះបង្គោលព្រំដែនជាមួយវៀតណាមជាបណ្ដោះអាសន្ន។ ករណីនេះសម្ដេចបានដាក់ការសង្ស័យពីភាពស្មោះត្រង់របស់ឯកឧត្ដម សម រង្ស៊ី ចំពោះការអនុវត្តវប្បធម៌សន្ទនា និងបានលើកឡើងថា ការអនុវត្តវប្បធម៌សន្ទនានេះប្រហែលជាឯកឧត្ដម សម រង្ស៊ី កំពុងដើរតួស្លូត និងទុកឲ្យមន្ត្រីរបស់ខ្លួនឲ្យដើរតួកាច។

គួររំឭកថា ឯកឧត្ដម កឹម សុខា បានលើកឡើងថា ឯកឧត្ដមមិនអាចអង្គុយធ្វើការជាមួយអ្នកដែលចាប់កូនចៅខ្លួនដាក់គុកបានទេ ដោយបានចាត់ទុកថា ការចាប់ខ្លួនសកម្មជនបក្សសង្គ្រោះជាតិ គឺជារឿងនយោបាយ និងជាការគំរាមកំហែងបំបាក់ស្មារតី។ ឯកឧត្ដមអំពាវនាវឲ្យគណបក្សកាន់អំណាច បញ្ឈប់ការប្រើប្រាស់តុលាការជាឧបករណ៍គំរាមកំហែងតទៅទៀតដោយ

ចាត់ទុកថា វាជាការបង្កការឈឺចាប់បង្កើនភាពក្ដៅក្រហាយ ដែលគណបក្សសង្គ្រោះជាតិកំពុងតែខិតខំពន្លត់កម្ដៅ ដើម្បីជៀសវាងអំពើហិង្សាចលាចលក្នុងសង្គម។ មន្ត្រីជាន់ខ្ពស់គណបក្សនេះតែងតែបញ្ជាក់ថា វប្បធម៌សន្ទនាមិនជាប់ពាក់ព័ន្ធនឹងការងារតំណាងរាស្ត្រឡើយ ហើយការភ្ជាប់នេះ ធ្វើឲ្យប៉ះពាល់សកម្មភាពរបស់អ្នកតំណាងរាស្ត្រ។

ដោយឡែក ឯកឧត្ដម សម រង្ស៊ី តែងតែអំពាវនាវឲ្យថែរក្សាវប្បធម៌សន្ទនា និងគោរពនូវកិច្ចព្រមព្រៀងនយោបាយ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ ឯកឧត្ដមក៏បានស្នើឲ្យមានការបញ្ចប់ និងលុបបំបាត់វប្បធម៌សង្គ្រាមយកខ្មែរជាសត្រូវ វប្បធម៌ហិង្សា និងជាពិសេសត្រូវបញ្ចប់វប្បធម៌ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រីផងដែរ។ លើសពីនេះ ឯកឧត្ដមក៏បានប្រកាសទទួលខុសត្រូវជាមួយសម្ដេចនាយករដ្ឋមន្ត្រី បើសិនជាវប្បធម៌សន្ទនា បរាជ័យ ហើយកើតមានអំពើហិង្សានយោបាយកើតឡើងជាថ្មី។ ឯកឧត្ដមក៏មានសុទិដ្ឋិនិយមថា វប្បធម៌សន្ទនានឹងធានាឲ្យមានសន្តិភាព សន្តិសុខ ជាមួយការផ្លាស់ប្ដូរមួយតាមបែបប្រជាធិបតេយ្យ និងដោយសន្តិវិធី។

ជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំគណបក្សទាំងពីរតែងតែអះអាងថា គណបក្សខ្លួនបានគោរពកិច្ចព្រមព្រៀងដំណោះស្រាយនយោបាយ ដែលមូលដ្ឋាននៃវប្បធម៌សន្ទនា ហើយអំពាវនាវឲ្យភាគីម្ខាងគោរពវប្បធម៌សន្ទនាដោយស្មារតីស្មោះត្រង់ និងបានដាក់ការជឿទុកចិត្តថា ចំណងទាក់ទង និងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃវប្បធម៌សន្ទនា រវាងគណបក្សទាំងពីរនឹងចាក់ឫស ចាក់គល់កាន់តែជ្រៅ ហើយនឹងបន្តពង្រឹងពង្រីកកាន់តែទូលំទូលាយថែមទៀត។

បើទោះជាមានការលើកឡើងអំពីការគោរព និងការពង្រឹងវប្បធម៌សន្ទនារបស់ថ្នាក់ដឹកនាំគណបក្សទាំងពីរ ប៉ុន្តែសកម្មជនគណបក្សសង្គ្រោះជាតិ ១១នាក់ ត្រូវបានតុលាការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារចាប់ពី ៧ឆ្នាំ ទៅដល់ ២០ឆ្នាំ ពីបទដឹកនាំ និងចូលរួមកុប្បកម្មនៅក្បែរទីលានប្រជាធិបតេយ្យ។ សមាជិកព្រឹទ្ធសភាឯកឧត្ដម ហុង សុខហួរ ពីគណបក្សសម រង្ស៊ី ក៏ត្រូវបានតុលាការសម្រេចបញ្ជូនទៅពន្ធនាគារ ដោយធ្វើការចោទប្រកាន់ពាក់ព័ន្ធនឹងការក្លែងឯកសារទាក់ទងនឹងសន្ធិសញ្ញាព្រំដែនជាមួយប្រទេសវៀតណាម។ ការផ្ដន្ទាទោសទាំងនេះ គឺនៅបន្ទាប់ពីតំណាងរាស្ត្រ និងមន្ត្រីគណបក្សប្រឆាំងដឹកនាំចលនាពិនិត្យ និងធ្វើការរិះគន់បញ្ហាព្រំដែនកម្ពុជា-វៀតណាម។ វាត្រូវបានមើលឃើញថា ជាការបញ្ជូនសារពីសម្ដេច ហ៊ុន សែន ទៅឯកឧត្ដម សម រង្ស៊ី ថា ការយកបញ្ហាព្រំដែនធ្វើជារឿងនយោបាយបានធ្វើឱ្យសម្ដេចផ្ទុះកំហឹង។ នៅស្របពេលដែលឯកឧត្ដម សម រង្ស៊ី មិនអាចជួយអ្វីបានចំពោះការចាប់ខ្លួនពាក់ព័ន្ធនឹងរឿងនយោបាយដែលបង្ហាញឲ្យឃើញថា វប្បធម៌សន្ទនារបស់ឯកឧត្ដមជាមួយសម្ដេចនាយករដ្ឋមន្ត្រីហាក់មិនមានប្រយោជន៍សម្រាប់ភាគីគណបក្សប្រឆាំង។ លើសពីនេះទៀត ឯកឧត្ដម កឹម សុខា ក៏ត្រូវបានតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា សម្រេចដកចេញពីអនុប្រធានទី១នៃរដ្ឋសភា ហើយរូបឯកឧត្ដម សម រង្ស៊ី ផ្ទាល់ ក៏ត្រូវបានរដ្ឋសភាចេញសេចក្ដីប្រកាសថា ឯកឧត្ដមត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភា ដែលកាន់តែបង្ហាញថា វប្បធម៌សន្ទនាកាន់តែមានភាពរង្គោះរង្គើ។

ករណីទាំងនេះបង្ហាញថា ភាគីសន្ទនានៃគណបក្សប្រជាជនកម្ពុជាយល់ឃើញថា ភាគីសន្ទនារបស់ខ្លួនមិនអាចធ្វើការទិតៀនខ្លួនបានទេ។ រីឯភាគីនៃគណបក្សសង្គ្រោះជាតិយល់ឃើញថា ខ្លួនត្រូវធ្វើការងារពីរទន្ទឹមគ្នា គឺកិច្ចការសន្ទនាជាមួយភាគីគណបក្សកាន់អំណាចលើការទម្រង់បញ្ហាជាតិមួយចំនួន និងនៅធ្វើការទិតៀនរដ្ឋាភិបាល និងគណបក្សកាន់អំណាចក្នុងនាមខ្លួនជាគណបក្សប្រឆាំង។

### ៦.៨ អ្នកតំណាងរាស្ត្រមានអំណាចរដ្ឋបាលលើអ្នកតំណាងរាស្ត្រ?

កាលពីថ្ងៃទី០១ ខែកក្កដា អ្នកតំណាងរាស្ត្រ ឈាង វុន និងជាប្រធានគណៈកម្មការទី៥នៃរដ្ឋសភា បានបណ្ដេញអ្នកតំណាងរាស្ត្រ អ៊ុំ សំអាន ពីគណបក្សសង្គ្រោះជាតិមិនឲ្យផ្ដល់បទសម្ភាសន៍ដល់អ្នកកាសែតក្នុងបរិវេណវិមានរដ្ឋសភា។ ការ

បណ្តេញនេះ បានធ្វើឡើងក្រោយពីកិច្ចប្រជុំគណៈកម្មការចំនួន៣ នៅវិមានរដ្ឋសភាពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការក្រៅរដ្ឋាភិបាល។

ទាក់ទងករណីនេះ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) បានហៅទង្វើនោះថា ជាការរំលោភបំពានធ្ងន់ធ្ងរដល់សេរីភាពសម្តែងមតិ សេរីភាពក្នុងការមានមតិ និងសិទ្ធិក្នុងការប្រឆាំងតវ៉ា។ គណៈកម្មាធិការនេះបានអំពាវនាវដល់តំណាងរាស្ត្រទាំងអស់បញ្ឈប់នូវការជ្រៀតជ្រែក និងរំលោភបំពានលើសិទ្ធិ និងឯកសិទ្ធិរបស់តំណាងរាស្ត្រដទៃទៀត ក្នុងការផ្តល់បទសម្ភាសន៍ឲ្យអ្នកសារព័ត៌មាន និងបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលពួកគេធ្វើជាអ្នកតំណាង។

ដោយឡែក ក្លឹបអ្នកកាសែតកម្ពុជាបានចាត់ទុកថា ការបណ្តេញអ្នកកាសែតដែលកំពុងបំពេញតួនាទីតាមវិជ្ជាជីវៈ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិសេរីភាពរបស់អ្នកកាសែត ដែលមានចែងក្នុងច្បាប់ ស្តីពីរបបសារព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា។ រដ្ឋមន្ត្រីក្រសួងព័ត៌មាន ឯកឧត្តម ខៀវ កាញារីទ្ធ បានក៏បានលើកឡើងផងដែរថា រដ្ឋសភាជាកន្លែងដែលអ្នកកាសែតមានសិទ្ធិចេញចូល ដើម្បីយកព័ត៌មាន ហើយការបណ្តេញអ្នកកាសែតចេញពីរដ្ឋសភា គឺធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។

បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដែលមិនមានចែងលើកតម្កើងវិស័យសារព័ត៌មាន ព្រោះមិនមានកំណត់ឲ្យមានបន្ទប់សន្និសីទកាសែតមួយ ដែលអ្នកតំណាងរាស្ត្រក៏អាចធ្វើសន្និសីទ ឬផ្តល់សម្ភាសន៍ជាមួយអ្នកកាសែតដោយមិនចាំបាច់ស្នើសុំការយល់ព្រមពីប្រធានរដ្ឋសភា។

ករណីនេះបើពិនិត្យផ្លូវច្បាប់ អ្នកតំណាងរាស្ត្រម្នាក់ៗគ្មានសមត្ថកិច្ចណាដែលចែងថា មានអំណាយរដ្ឋបាលលើអ្នកតំណាងរាស្ត្រម្នាក់ទៀតនោះទេ។ ការអនុវត្តបែបនេះ គឺជាការរំលោភលើសិទ្ធិក្នុងការបញ្ចេញមតិរបស់តំណាងរាស្ត្រ និងរំលោភមុនងារ និងតួនាទីរបស់តំណាងរាស្ត្រ ព្រមទាំងបង្កឲ្យមានជំលោះទៀតផងដែរ។ តែទោះជាយ៉ាងណា រដ្ឋសភាមិនបានបង្ហាញចំណាត់ការរបស់ខ្លួនឡើង បើទោះជាមានការស្នើដោយអ្នកតំណាងរាស្ត្រ អ៊ុំ សំអាន ឲ្យពិចារណាចាត់វិធានការ និងទាមទារឲ្យឯកឧត្តម ឈាង វុន សុំទោសជាសាធារណៈចំពោះរូបឯកឧត្តម និងអ្នកសារព័ត៌មាន ពាក់ព័ន្ធនឹងករណីប្រើពាក្យមិនសមរម្យ។

គួរបញ្ជាក់ថា នេះជាលើកទី២ហើយ ដែលអ្នកតំណាងរាស្ត្រ ឈាង វុន ដេញអ្នកតំណាងរាស្ត្រគណបក្សប្រឆាំងពីទីធ្លារដ្ឋសភា។ លើកទីមួយ ឯកឧត្តម ឈាង វុន បានដេញឯកឧត្តម សុន ឆ័យ។ រូបភាពបែបនេះ អាចធ្វើឲ្យធ្លាក់តម្លៃស្ថាប័នរដ្ឋសភា ដែលគួរតែមានការពិនិត្យ និងកែលម្អ។

### ៦.៩ ភាពចម្រូងចម្រាសក្នុងការអនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦

សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានរដ្ឋសភាលើកមកពិភាក្សា និងអនុម័តកាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ដោយមិនមានការចូលរួមពីតំណាងរាស្ត្រគណបក្សប្រឆាំង។ ក្រុមតំណាងរាស្ត្រតែពីគណបក្សប្រជាជនកម្ពុជា បានដើរតួជាតំណាងរាស្ត្រផង និងខ្លះជាអ្នកការពារច្បាប់ផង បានថ្លែងការពារ អះអាងថា ជាច្បាប់ល្អ និងរិះគន់ក្រុមអ្នកប្រឆាំង និងការមិនចូលរួមការអនុម័តសេចក្តីព្រាងច្បាប់របស់តំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ។

អ្នកតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ដែលពហិការមិនចូលរួមប្រជុំអនុម័តបានចាត់ទុកថា សេចក្តីព្រាងច្បាប់នេះមានលក្ខណៈរឹតត្បិតសិទ្ធិសេរីភាព និងផ្ទុយពីឆន្ទៈរបស់អង្គការសង្គមស៊ីវិល។ ជាមួយគ្នានេះ គណបក្សក៏បានចេញសេចក្តី

ថ្លែងការណ៍ មិនគាំទ្រឲ្យមានច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងដំណាក់កាលបច្ចុប្បន្ននេះទេ និងអំពាវនាវដល់រាជរដ្ឋាភិបាលឲ្យដកឃ្លាទៅពិចារណាឡើងវិញក្នុងការកែសម្រួលសេចក្តីព្រាងច្បាប់ និងអំពាវនាវឲ្យរដ្ឋសភាជាតិទម្លាក់ចោលការអនុម័តតែម្តង។

ជុំវិញសេចក្តីព្រាងច្បាប់នេះមន្រ្តី និងសកម្មកជនសង្គការសង្គមស៊ីវិលភាគច្រើន បានបង្ហាញការមិនពេញចិត្តតាមមធ្យោបាយផ្សេងដូចការហែក្បួន ការតវ៉ានានា ការស្នើឲ្យរដ្ឋសភា និងតំណាងរាស្រ្តទំលាក់ចោលការអនុម័ត និងការដាក់ញត្តិជំទាស់ការអនុម័តជាដើម។ មន្រ្តីអង្គការសង្គស៊ីវិលបានលើកឡើងថា មាត្រា៥ មាត្រា១០ មាត្រា១៥ មាត្រា២២ មាត្រា៣០ និងមាត្រា៣២ សុទ្ធតែជាការបារម្ភខ្លាំង ខណៈដែលមាត្រា៣២ បានចែងពីការផាកពិន័យធ្ងន់ធ្ងរដល់អង្គការ ឬសមាគមណាដែលមិនបានបំពេញលក្ខខណ្ឌតាមច្បាប់នេះ ហើយឈានទៅលុបឈ្មោះអង្គភាពនោះចោល។ លើសពីនេះទៀត នៅពេលច្បាប់នេះចេញនឹងធ្វើឲ្យសមាគមតូចៗ និងសកម្មភាពការងារស្ម័គ្រចិត្តរបស់យុវជន និងសកម្មជនតាមមូលដ្ឋាននឹងត្រូវបញ្ចប់ព្រោះតែពួកគេមិនអាចបំពេញលក្ខខណ្ឌតាមអ្វីដែលរដ្ឋាភិបាលបានកំណត់ក្នុងច្បាប់នេះ។

គួរបញ្ជាក់ថា នៅមុនការអនុម័ត គណៈកម្មាធិការកិច្ចការបរទេសសហភាពអឺរ៉ុបបានស្នើឲ្យថ្នាក់ដឹកនាំរដ្ឋសភា បើកឲ្យមានការពិភាក្សាឲ្យបានទូលំទូលាយ និងមានតម្លាភាពលើសេចក្តីព្រាងច្បាប់នេះ។ គណៈកម្មាធិការនេះ ក៏បានលើកឡើងថាអង្គការសង្គមស៊ីវិលមានតួនាទីដែលមិនអាចជំនួសបាន ក្នុងការពិនិត្យ និងតាមដានទៅលើការអនុវត្តការងាររបស់រដ្ឋាភិបាល និងរដ្ឋបាលសាធារណៈ។

នៅបន្ទាប់ពីព្រឹទ្ធសភាអនុម័ត តំណាងរាស្រ្តគណបក្សសង្រ្គោះជាតិ និងសមាជិកព្រឹទ្ធសភាគណបក្សសម រង្ស៊ី ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ត្រួតពិនិត្យមើលពីធម្មនុញ្ញភាពនៃខ្លឹមសារច្បាប់ស្តីពីអង្គការ និងសមាគមនេះ។ ជាមួយគ្នានេះ អង្គការសិទ្ធិមនុស្សមួយចំនួនក៏បានចេញលិខិតអំពាវនាវរួមគ្នា ដោយស្នើឲ្យក្រុមប្រឹក្សាធម្មនុញ្ញបដិសេធច្បាប់នេះផងដែរ។ ប៉ុន្តែទោះជាយ៉ាងណាក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចថា ច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យរួចនេះ គឺស្របនឹងរដ្ឋធម្មនុញ្ញដែលពុំមានអ្វីត្រូវកែប្រែទៀតឡើយ។

ដោយឡែកសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលរដ្ឋសភាពិភាក្សា និងអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ គឺមិនមានការចូលរួមពីតំណាងរាស្រ្តគណបក្សសង្រ្គោះជាតិទេ។ មន្រ្តីជាន់ខ្ពស់ និងជាតំណាងរាស្រ្តគណបក្សសង្រ្គោះជាតិបានលើកឡើងថា ច្បាប់នេះមិនសូវមានតម្លាភាព និងប្រសិទ្ធភាព និងព្រមទាំងរិះគន់អំពីការប្រមូលចំណូលមិនបានពេញលេញ ហើយមានចំណាយខ្លះធ្វើឡើងដោយមិនចាំបាច់។

ជាមួយគ្នានេះ ក្រុមអង្គការសង្គមស៊ីវិលក៏បានរិះគន់អំពីតម្លាភាព និងប្រសិទ្ធិភាពនៃការតាក់តែងសេចក្តីព្រាងច្បាប់នេះ និងព្រមទាំងរិះគន់អំពីការអនុម័តទាំងប្រញាប់ប្រញាល់របស់រដ្ឋសភា ដែលមានតែតំណាងរាស្រ្តពីគណបក្សប្រជាជនកម្ពុជា។ អង្គការសង្គមស៊ីវិលបន្ថែមថា ការបែងចែកថវិកានៅក្នុងវិស័យនីមួយៗ គឺជារឿងសំខាន់ ដែលទាមទារឲ្យមានការជជែកគ្នាឲ្យបានច្រើន ពិសេសវិស័យអាទិភាព។ ការអនុម័តគ្មានអត្ថន័យឡើង ប្រសិនបើអ្នកតំណាងរាស្រ្តខ្វះព័ត៌មានសម្រាប់ជជែកដេញដោលជាមួយតំណាងរដ្ឋាភិបាល ដែលអ្នករៀបចំសេចក្តីព្រាងច្បាប់។ ការសង្កេតឃើញថា រដ្ឋសភាមានការខិតខំខ្លះក្នុងការរៀបចំឲ្យមានការពិគ្រោះពីភាគីពាក់ព័ន្ធមុននឹងការអនុម័តច្បាប់ហិរញ្ញវត្ថុនេះ ដោយរៀបចំសិក្ខាសាលា ស្វែងយល់ពីការសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០១៦ នេះ។

### ៦.១០ ការដាក់ទណ្ឌកម្មខាងវិន័យលើអ្នកតំណាងរាស្ត្រ អ៊ុំ សំអាន

អ្នកតំណាងរាស្ត្រ អ៊ុំ សំអាន មណ្ឌលខេត្តសៀមរាប ពីគណបក្សសង្គ្រោះជាតិ ត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាសម្រេចធ្វើការបន្ទោស និងដាក់ទណ្ឌកម្មខាងវិន័យដូចជាៈ ទី១.កាត់ប្រាក់បំណាច់ប្រចាំខែហាសិបភាគរយក្នុងរយៈពេល ២ខែ, ទី២.ប្រកាសផ្សាយជាសាធារណៈនូវសម្រង់កំណត់ហេតុបន្ទាស ព្រមទាំងយកទៅបោះពុម្ព ហើយបិទផ្សាយនៅគ្រប់ឃុំ ក្នុងមណ្ឌលខេត្តសៀមរាប និងទី៣ហាមមិនឲ្យចូលធ្វើការក្នុងរដ្ឋសភា ក្នុងវេលា ១៥ពេលប្រជុំជាបន្តបន្ទាប់។ ការសម្រេចនេះ ដោយយោងហេតុផលថា សកម្មភាពរបស់តំណាងរាស្ត្រ អ៊ុំ សំអាន ដែលបានផ្សាយចេញតាមបណ្តាញព័ត៌មានសង្គមហ្វេសប៊ុក (Facebook) កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៥ ចាត់ទុកជាអំពើប្រព្រឹត្តិនាំឲ្យប៉ះពាល់ដល់កិត្យានុភាពរបស់រដ្ឋសភា និងជាការប្រមាថមើលងាយប្រធានរដ្ឋសភា ដែលផ្ទុយពីមាត្រា៨៧ នៃរដ្ឋធម្មនុញ្ញ ព្រមទាំងប្រការមួយចំនួនទៀតនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

អ្នកតំណាងរាស្ត្រ អ៊ុំ សំអាន ហៅការដាក់ពិន័យមកលើរូបខ្លួននេះគឺជារឿងមិនសមហេតុផល និងអនុវត្តមិនត្រឹមត្រូវតាមនីតិវិធីច្បាប់។ ជាមួយគ្នានេះមន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បានចាត់ទុកការសម្រេចលើករណីឯកឧត្តម អ៊ុំ សំអាន ជារឿងខុសច្បាប់ ហើយសុំឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ពិចារណាឡើងវិញ ដោយត្រូវពិនិត្យមើលប្រការ៧៩ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា មុននឹងសម្រេចដាក់ពិន័យតំណាងរាស្ត្រ។

ករណីនេះជាសញ្ញាមួយបង្ហាញពីការធ្លាក់ចុះនៃការគោរពអនុវត្តច្បាប់នៅក្នុងស្ថាប័នរដ្ឋសភា ព្រោះថាទាំងរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា មិនមានចែងថា ប្រធានរដ្ឋសភាត្រូវបានហាមឃាត់ដាច់ខាតមិនឲ្យរិះគន់ ឬនិយាយប៉ះពាល់មិនបាននោះទេ ហើយក៏មិនមែនរាល់ការរិះគន់ទាំងឡាយត្រូវតែបកស្រាយទៅជាការប្រមាថមើលងាយ ប៉ះពាល់ដល់កិត្តិយសនោះដែរ។ មួយវិញទៀតការសម្រេចនេះ ជាការរាំងខ្ទប់នៃសិទ្ធិបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្ររបស់គណបក្សប្រឆាំងក្រោមហេតុផលនយោបាយ និងធ្វើឲ្យមានការព្រួយបារម្ភចំពោះការទម្លាក់តម្លៃអ្នកតំណាងរាស្ត្រ ដោយសារតែចង់ដាក់សម្ពាធនយោបាយទៅលើបក្សប្រឆាំង ដែលជាដៃគូប្រកួតប្រជែងសំខាន់របស់គណបក្សកាន់អំណាច។

គួរបញ្ជាក់ថា កន្លងទៅ ឯកឧត្តម អ៊ុំ សំអាន បានសរសេរនៅលើហ្វេសប៊ុករបស់ឯកឧត្តមថាៈ "បញ្ជាក់ត្រង់នេះមួយត្រង់គាត់និយាយថា អ៊ីចឹងតើបានជាយួននិយាយថា ភូមិកំណើតរបស់សម្តេចស្ថិតក្នុងដីយួន អត់ហ៊ានក្អកជាមួយយួន កុំចង់យកភូមិខ្មែរពីរទៅឲ្យយួនដូរជាមួយភូមិកំណើតសម្តេចវិញ"។ ឯកឧត្តមបានសរសេរបែបនេះ ក្រោយពេលប្រធានរដ្ឋសភាសម្រេចមិនបញ្ជូនលិខិតរបស់តំណាងរាស្ត្រទៅសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ករណីស្នើសុំផ្អាកការបោះបង្គោលព្រំដែនជាមួយវៀតណាម។

ក្រៅពីវិធានការខាងលើឯកឧត្តមក៏ប្រឈមនឹងប្តឹងតាមផ្លូវតុលាការពីសំណាក់ប្រធានរដ្ឋសភា។ អ្នកនាំពាក្យនៃរដ្ឋសភា ឯកឧត្តម ឈាង វុន បានឲ្យដឹងថា ក្រុមអ្នកច្បាប់ក្នុងរដ្ឋសភា បានសិក្សាពិគ្រោះយោបល់លើករណីឯកឧត្តម អ៊ុំ សំអាន ដែលឯកឧត្តមអាចប្រឈមនឹងពីរករណី ទី១.វិធានការដាក់វិន័យរដ្ឋបាលក្នុងរដ្ឋសភាតាមបទបញ្ជាផ្ទៃក្នុង (ដែលរដ្ឋសភាបានសម្រេចរួចហើយ) និងទី២.ការប្រើសិទ្ធិបុគ្គលប្តឹងតាមផ្លូវតុលាការ ពីសំណាក់ប្រធានរដ្ឋសភា។ បច្ចុប្បន្ននេះឯកឧត្តម អ៊ុំ សំអាន កំពុងរស់នៅក្រៅប្រទេស បើទោះជាមិនមានបញ្ជាក់ជាផ្លូវការអំពីមូលហេតុ តែគេអាចនិយាយបានថា ឯកឧត្តមគេចខ្លួនពីចំណាត់ការតាមផ្លូវតុលាការ ដែលអាចកើតឡើងចំពោះរូបឯកឧត្តម។

លើសពីនេះ ប្រធានគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជាឯកឧត្តម វ៉ា គឹមហុង ក៏ជំរុញឲ្យរដ្ឋាភិបាលចាត់វិធានការទៅលើឯកឧត្តម អ៊ុំ សំអាន ផងដែរ ដោយចោទថា អ្នកតំណាងរាស្ត្ររូបនេះកំពុងញុះញង់ឲ្យមានអស្ថេរភាពសង្គម តាមរយៈនៃការបន្តរិះគន់រឿងបោះបង្គោលព្រំដែនជាមួយវៀតណាមពីក្រៅប្រទេស។ ជាមួយគ្នានេះ អង្គភាពប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រីក៏បានបញ្ជាក់ក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនថា រដ្ឋាភិបាលពិចារណាយ៉ាងម៉ឺងម៉ាត់នូវវិធានការផ្លូវច្បាប់លើអ្នកតំណាងរាស្ត្រ អ៊ុំ សំអាន ដោយធ្វើការចោទប្រកាន់ថា រាល់ទង្វើ និងព័ត៌មានដែលផ្សព្វផ្សាយដោយអ្នកតំណាងរាស្ត្ររូបនេះ គឺបង្កប់ដោយឧបាយកលទុច្ចរិត ក្នុងការបំផុសគំនិតជាតិនិយមជ្រុល បំបែកបំបាក់ការឯកភាពជាតិ បង្កឱ្យមានការភ័ន្តច្រឡំនៅក្នុងសាធារណមតិជាតិ និងអន្តរជាតិអំពីបញ្ហាអធិបតេយ្យជាតិ និងបូរណភាពទឹកដីកម្ពុជា។

### ៦.១១ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងរងអំពើហិង្សាយ៉ាងធ្ងន់ធ្ងរនៅមុខរដ្ឋសភា

កាលពីព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ អ្នកតវ៉ារាប់រយពាន់នាក់បានប្រមូលផ្តុំគ្នានៅមុខវិមានរដ្ឋសភា និងគេហដ្ឋានឯកឧត្តម កឹម សុខា ទាមទារឲ្យឯកឧត្តមចុះចេញពីតំណែងអនុប្រធានទីមួយរដ្ឋសភា។ លុះនៅម៉ោងប្រមាណ ១២ និង៣០ នាទីថ្ងៃត្រង់ ក្រុមអ្នកតវ៉ាបានទាញអ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ២រូប គឺឯកឧត្តម គង់ សភា និងឯកឧត្តម ញ៉យ ចំរើន ចេញពីរថយន្តនៅមុខវិមានរដ្ឋសភា នៅពេលពួកឯកឧត្តមចាកចេញពីវិមានរដ្ឋសភា ហើយក្រុមអ្នកតវ៉ា បានវាយបណ្តាលឲ្យរងរបួសយ៉ាងដំណំ។

មុនកើតអំពើហិង្សាមានការសង្កេតឃើញថា កំលាំងមានសមត្ថកិច្ចពុំបានចេញមុខការពារ រក្សាសណ្តាប់ធ្នាប់ និងបំបែកការទាមទារតវ៉ា ដូចសព្វដងទេ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការតវ៉ាជាច្រើនរាប់មិនអស់ក្នុងរាជធានីភ្នំពេញត្រូវបានរារាំង ឬត្រូវបំបែកយ៉ាងហិង្សាដោយសមត្ថកិច្ច និងកម្លាំងកងសន្តិសុខយ៉ាងច្រើនហួសហេតុ។ ជាការកត់សម្គាល់អ្នកតវ៉ាដែលត្រូវបានរៀបចំឡើងយ៉ាងល្អ ប្រមាណ ៤ពាន់នាក់ ភាគច្រើន ពួកគេបានបង់ក្រមាក្រហម និងក្រណាត់ក្រហមបិទភ្ជាប់នឹងអាវរបស់ពួកគេ។ ជាការកត់សម្គាល់ បាតុកម្មលេចជារូបរាងឡើងក្រោយពេលដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ហើបពីគម្រោងនេះនាអំឡុងនៃជំនួបរបស់សម្តេចជាមួយពលរដ្ឋ និងនិស្សិតខ្មែរនៅទីក្រុងប៉ារីស ប្រទេសបារាំង នៅស្របពេលដែលមនុស្សជាច្រើននាក់នៅទីនោះ ធ្វើបាតុកម្មប្រឆាំងនឹងដំណើរទស្សនកិច្ចរបស់សម្តេច។

គណបក្សសង្គ្រោះជាតិបានសរសេរលិខិតដាក់ថ្វាយទៅកាន់ព្រះមហាក្សត្រ ឯកឧត្តម ស ខេង និងបណ្តាអង្គទូតនានានៅកម្ពុជា ដើម្បីជួយអន្តរាគមន៍ដោះស្រាយលើករណីហិង្សាលើតំណាងរាស្ត្រនៃគណបក្សខ្លួន។ ជាមួយគ្នានេះ គណបក្សបានអំពាវឲ្យសហគមន៍អន្តរជាតិ និងអង្គការសហប្រជាជាតិ ជំរុញឲ្យរដ្ឋាភិបាលបើកការស៊ើបអង្កេតដោយឯករាជ្យ និងអព្យាក្រឹត្យក្នុងការរកមុខរកជនដៃដល់ និងអ្នកបញ្ជាពីក្រោយខ្នង ដោយដើម្បីរកយុត្តិធម៌ដល់តំណាងរាស្ត្របក្សខ្លួនទាំងពីររូប។ មន្ត្រីជាន់ខ្ពស់គណបក្សនេះបានអះអាងថា ភស្តុតាងស្តីពីសកម្មភាពវាយប្រហារលើអ្នកតំណាងរាស្ត្រទាំងពីររូប គឺមានគ្រប់គ្រាន់ហើយជាពិសេសកាម៉េរារដ្ឋសភា កាម៉េរាទូតអូស្ត្រាលី និងការថតតាមទូរសព្ទដៃ។

ជុំវិញករណីនេះ រដ្ឋសភាបានថ្កោលទោសចំពោះអំពើហិង្សាលើតំណាងរាស្ត្រទាំងពីររូប និងស្នើអាជ្ញាធរមានសមត្ថកិច្ចរាជរដ្ឋាភិបាល ចាត់វិធានការស្រាវជ្រាវចាប់ខ្លួនជនល្មើសមកផ្តន្ទាទោស។ ជាមួយគ្នានេះ រដ្ឋាភិបាលក៏បានថ្កោលទោស ចំពោះអំពើបង្ករបួសស្នាមនេះ ហើយបានចាត់វិធានការដោយបញ្ជាឲ្យក្រសួងមហាផ្ទៃបើកការស៊ើបអង្កេត និងចាប់ជនល្មើសទៅផ្តន្ទាទោសតាមច្បាប់ និងបានអំពាវនាវផងដែរឲ្យការសហការផ្តល់ភស្តុតាងពាក់ព័ន្ធនានា ដើម្បីរកយុត្តិធម៌ដល់ជនរងគ្រោះឲ្យបាន

ឆាប់តាមដែលអាចធ្វើទៅបាន។ ជាការឆ្លើយតប ក្រសួងមហាផ្ទៃបានបង្កើតគណៈកម្មការចម្រុះមួយ ដើម្បីបើកការស៊ើបអង្កេតស្វែងរកមុខជនដៃដល់។

សង្គមស៊ីវិលក៏បានចេញសេចក្តីថ្លែងការណ៍ថ្កោលទោស និងបានអំពាវនាវឲ្យមានការស៊ើបអង្កេតដោយឯករាជ្យ និងមានតម្លាភាពទៅលើការបង្កហិង្សាលើអ្នកតំណាងរាស្ត្រទាំងពីររូបនេះ។ សង្គមស៊ីវិលបានហៅអំពើហិង្សានេះ គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាធរមាន ហើយកើតចេញពីកង្វះខាតវិធានការរបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការគ្រប់គ្រងការប្រមូលផ្តុំដោយមនុស្សរាប់រយរាប់ពាន់នាក់នៅមុខវិមានរដ្ឋសភា និងមុខគេហដ្ឋានរបស់ឯកឧត្តម កឹម សុខា។

ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ក៏បានចេញសេចក្តីថ្លែងការណ៍ថ្កោលទោសសកម្មភាពវាយដំទៅលើតំណាងរាស្ត្រ និងបានលើកឡើងថា ការអនុវត្តន៍សេរីភាពក្នុងការប្រមូលផ្តុំគ្នា និងសេរីភាពក្នុងការនិយាយស្តី មិនមែនជាហេតុផលត្រឹមត្រូវសំរាប់ប្រព្រឹត្តអំពើហិង្សាទេ និងព្រមទាំងអំពាវនាវឲ្យអាជ្ញាធរធ្វើការស៊ើបអង្កេតអោយបានពេញលេញ និងប្រកបដោយតម្លាភាពទៅលើការវាយដំទាំងនេះ ដើម្បីរក្សារបៀបរៀបរយនៅរដ្ឋសភាជាតិ និងដើម្បីធានាសុវត្ថិភាពរបស់អ្នកនយោបាយពីគ្រប់គណបក្សទាំងអស់។

ទន្ទឹមគ្នានេះ សភាសិទ្ធិមនុស្សអាស៊ានក៏បានថ្កោលទោស ចំពោះអំពើហិង្សាលើអ្នកតំណាងរាស្ត្រនេះដែរ ហើយបានទទូចឲ្យមានការបើកការស៊ើបអង្កេតមួយដោយឯករាជ្យ។ សភាសិទ្ធិមនុស្សអាស៊ានបានរិះគន់ថា ការប្រើប្រាស់ហិង្សា គឺសំរាប់ផលប្រយោជន៍នយោបាយ និងបានអំពាវនាវសហគមន៍អន្តរជាតិ ដែលរាប់បញ្ចូលទាំងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង រដ្ឋជាសមាជិក ដើម្បីដាក់សម្ពាធលើរដ្ឋាភិបាលកម្ពុជាដើម្បីបញ្ចប់នូវគោលនយោបាយរឹតត្បិតលើក្រុមអ្នកប្រឆាំងខ្លួន។

ដោយឡែកគណបក្សគ្មានអាសនៈក្នុងរដ្ឋសភាមួយចំនួនបានសម្តែងនូវការហួសចិត្ត និងសោកស្តាយយ៉ាងខ្លាំងចំពោះការប្រើអំពើហិង្សានេះ និងបានស្នើឲ្យអាជ្ញាធរចាត់វិធានការជាបន្ទាន់ ដើម្បីចាប់ជនល្មើសយកមកផ្តន្ទាទោសតាមច្បាប់ និងព្រមទាំងអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យដាក់សម្ពាធលើរដ្ឋាភិបាលកម្ពុជា ដើម្បីបញ្ឈប់ការប្រើប្រាស់អំពើហិង្សគ្រប់ប្រភេទផងដែរ។

នៅបន្ទាប់ពីប្រតិកម្មពីស្ថាប័នជាតិ និងអន្តរជាតិបានរិះគន់យ៉ាងខ្លាំងលើអំពើហិង្សានេះ រួមទាំងការបញ្ជាឲ្យចាប់ខ្លួន និងការអំពាវនាវរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឲ្យជនដៃដល់ចេញមកសារភាព។ មនុស្ស៣នាក់បានចេញមុខសារភាព ចំពោះមុខគណៈកម្មការចម្រុះក្រសួងមហាផ្ទៃកាលពីថ្ងៃទី៣ វិច្ឆិកា ឆ្នាំ២០១៥ ហើយត្រូវតុលាការសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងពន្ធនាគារ ក្រោមការចោទប្រកាន់ពីបទបង្កហិង្សាដោយចេតនា និងធ្វើឲ្យខូចខាតទ្រព្យសម្បត្តិមានស្ថានទម្ងន់ទោស។ ទោះជាយ៉ាងណាមន្ត្រីគណបក្សប្រឆាំង និងតំណាងរាស្ត្រដែលរងគ្រោះ បានទាមទារឲ្យអាជ្ញាធរបន្តស្វែងរកអ្នកបញ្ជាក្រុមជនដៃដល់បន្ថែមទៀត។

អំពើហិង្សានេះបង្ហាញថា តំណាងរាស្ត្រ ដែលការពារដោយអភ័យ និងបុព្វសិទ្ធិពិសេសមួយចំនួន ដែលចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ប៉ុន្តែមានភាពងាយរងគ្រោះ មិនខុសពីប្រជាពលរដ្ឋធម្មតានោះទេ ហើយធ្វើឲ្យប៉ះពាល់ដល់ប្រសិទ្ធភាពការងារបម្រើម្ចាស់ឆ្នោតរបស់អ្នកតំណាងរាស្ត្រ។

### ៦.១២ អនុប្រធានទី១ នៃរដ្ឋសភាទទួលរងការគំរាមកំហែងជាបន្តបន្ទាប់មុនការសម្រេចដកតំណែងដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា

ឯកឧត្តម កឹម សុខា អនុប្រធានទី១នៃរដ្ឋសភាមកពីគណបក្សសង្គ្រោះជាតិ តែងត្រូវបានមន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា ពិសេសសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ព្រមានចាត់វិធានការលើរូបឯកឧត្តម ទាក់ទងទៅនឹងការដឹកនាំបាតុកម្មនៅក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ និងសារដែលឯកឧត្តមបានថ្លែងទៅកាន់អ្នកគាំទ្រនៅក្រៅប្រទេស។ សកម្មភាព និងពាក្យសម្តីរបស់ឯកឧត្តម កឹម សុខា ត្រូវបានមន្ត្រីគណបក្សប្រជាជនកម្ពុជាលើកឡើងថា ជាគម្រោងផ្តួលរំលំរដ្ឋាភិបាលនៅក្រោយការបោះឆ្នោត។ ទាក់ទងការចោទប្រកាន់នេះដែរ ឯកឧត្តម កឹម សុខា តែងតែធ្វើការបដិសេធថា ឯកឧត្តមមិនបានប្រើពាក្យ និងធ្វើសកម្មភាពដើម្បីផ្តួលរំលំរដ្ឋាភិបាលនោះទេ ប៉ុន្តែគឺក្នុងន័យផ្លាស់ប្តូរ ហើយការផ្លាស់នោះគឺធ្វើឡើងដោយសន្តិវិធី និងអហិង្សា។

ជុំវិញបញ្ហានេះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានខ្លាំងៗថា នឹងវាយខ្ទេះឯកឧត្តម កឹម សុខា បើសិនឯកឧត្តមដឹកនាំបាតុកម្មឲ្យដោះលែងសកម្មជនគណបក្សសង្គ្រោះជាតិ ដែលជាប់ពន្ធនាគារពាក់ព័ន្ធនឹង បាតុកម្មនៅក្រោយការបោះឆ្នោតឆ្នាំ២០១៣។ សម្តេចនាយករដ្ឋមន្ត្រីក៏បានរំឮកថា កន្លងមកអាជ្ញាធរមានសមត្ថកិច្ចមានគម្រោងចាប់ខ្លួនឯកឧត្តម កឹម សុខា ផងដែរ តែដោយសារពេលនោះអត់មានមូលដ្ឋានច្បាប់រឹងមាំ។

បន្ទាប់ពីការព្រមានពីសំណាក់សម្តេចនាយករដ្ឋមន្ត្រី តុលាការបានចេញដីកាកោះហៅឯកឧត្តម កឹម សុខាឲ្យចូលបំភ្លឺនៅតុលាការ។ ការកោះហៅនោះធ្វើឡើងទាំងរូបឯកឧត្តមមានអភ័យឯកសិទ្ធិតំណាងរាស្ត្រ។ ករណីត្រូវបានមើលឃើញថា ចំណាត់ការរបស់តុលាការហាក់ធ្វើឡើងក្រោមសម្ពាធនយោបាយរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល ហើយតុលាការមិនបានអនុវត្តត្រឹមត្រូវតាមនីតិវិធីច្បាប់ ព្រោះមិនបានស្នើទៅរដ្ឋសភា តាមរយៈក្រសួងយុត្តិធម៌ឲ្យលើកអភ័យឯកសិទ្ធិឯកឧត្តម កឹម សុខា មុននឹងអនុវត្តនីតិវិធីរបស់ខ្លួន។

ដោយឯកឧត្តម កឹម សុខា នៅបន្តធ្វើការរិះគន់ភាពអសកម្ម និងភាពអវិជ្ជមានរបស់រដ្ឋាភិបាល ឬស្ថាប័នរដ្ឋនោះ ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាចបានគំរាមជាបន្តបន្ទាប់ថា គណបក្សខ្លួននឹងធ្វើការបោះឆ្នោតទម្លាក់ ឯកឧត្តម កឹម សុខា ពីតំណែងជាអនុប្រធានទី១រដ្ឋសភា ព្រោះថា កៅអីអនុប្រធានទី១រដ្ឋសភាដែល ឯកឧត្តម កឹម សុខា កំពុងតែអង្គុយនេះ បានមកដោយមានការរួមចំណែកសំឡេងគាំទ្ររបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា។

ជាក់ស្តែងនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ តំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជាទាំង ៦៨រូប បានសម្រេចបោះឆ្នោតដកឯកឧត្តម កឹម សុខា ចេញពីតំណែងអនុប្រធានទី១នៃរដ្ឋសភា។ ការបោះឆ្នោតដកតំណែងនេះ ធ្វើឡើង ៣ថ្ងៃ ក្រោយពីមានបាតុកម្មរបស់អ្នកគាំទ្រគណបក្សប្រជាជនកម្ពុជានៅមុខរដ្ឋសភា និងផ្ទះឯកឧត្តម កឹម សុខា ស្នើឲ្យដកតំណែងរូបឯកឧត្តម និងឈានទៅដល់មានការប្រើអំពើហិង្សាលើតំណាងរាស្ត្រពីគណបក្សសង្គ្រោះជាតិ ២រូប ឲ្យរងរបួសជាទម្ងន់។

ជុំវិញការដកតំណែងនេះ អ្នកនាំពាក្យរដ្ឋសភាពីគណបក្សប្រជាជនកម្ពុជាឯកឧត្តម ឈាង វុន បានបញ្ជាក់ថា ការដកតំណែងឯកឧត្តម កឹម សុខា មិនមែនធ្វើតាមបាតុកម្មទេ ប៉ុន្តែយោងលើញត្តិតំណាងរាស្ត្រ កិច្ចព្រមព្រៀងនយោបាយ ថ្ងៃទី២២ កក្កដា និងវប្បធម៌សន្ទនា។ ឯកឧត្តមបន្ថែមថា ប្រសិនបើទុកឯកឧត្តម កឹម សុខា ធ្វើជាអនុប្រធានសភាបន្តទៀតនឹងធ្វើឲ្យប៉ះពាល់ខ្លាំងដល់ស្ថានការណ៍ទូទៅនៅកម្ពុជា។

គណបក្សសង្គ្រោះជាតិ បានចាត់ទុកការដកតំណែងឯកឧត្តម កឹម សុខា ចេញពីអនុប្រធានទី១ រដ្ឋសភាដោយតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា ថាជាការរំលោភរដ្ឋធម្មនុញ្ញ ដែលផ្ទុយនឹងមាត្រា ៨៧ និងរំលោភកិច្ចព្រមព្រៀងនយោបាយរវាងគណបក្សទាំងពីរ។ មន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិបានបកស្រាយថា មាត្រា៨៧ នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី៣ ចែងតែលើករណីប្រធាន និងអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម ត្រូវបោះឆ្នោតជ្រើសតាំងប្រធាន និងអនុប្រធានថ្មី ហើយ គ្មានមាត្រាណាមួយចែងអំពីការដកតួនាទីថ្នាក់ដឹកនាំរដ្ឋសភានោះទេ។ ផ្ទុយទៅវិញ រដ្ឋសភាចេញសេចក្តីថ្លែងការណ៍មួយបញ្ជាក់ថា ការដកតំណែងឯកឧត្តម កឹម សុខា នេះ ធ្វើឡើងស្របតាមប្រការ ១៩ និងប្រការ ២០ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងតាមសំណើរបស់តំណាងរាស្ត្រចំនួន ៦៣រូប។ សេចក្តីថ្លែងការណ៍បន្ថែមថា ការដកនេះ គឺស្របតាមមាត្រា ៨២ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងពីការជ្រើសតាំងតំណែងប្រធាន និងអនុប្រធានរដ្ឋសភា គឺធ្វើឡើងដោយការបោះឆ្នោតពីសមាជិករដ្ឋសភាទាំងមូលនៃសំឡេងភាគច្រើនដាច់ខាត ហើយមាត្រា ៨៧ ក៏ពុំបានហាមឃាត់រដ្ឋសភាក្នុងការផ្លាស់ប្តូរមុខតំណែងប្រធាន ឬអនុប្រធាននៃរដ្ឋសភាឡើយ។

ករណីនេះត្រូវបានមើលឃើញថា ប៉ះពាល់ខ្លាំងក្នុងការបំបិទមាត់ថ្នាក់ដឹកនាំរដ្ឋសភា និងបង្កើតភាពមិនប្រក្រតីនៃនីតិវិធីដកថ្នាក់ដឹកនាំរដ្ឋសភាដែលមានចែងក្នុងរដ្ឋធមនុញ្ញ ព្រោះថា គ្មានហេតុផល និងនីតិវិធីគ្រប់គ្រាន់ក្នុងការដកតំណែងនេះទេ។ ម្យ៉ាងវិញទៀត ការដកដោយហេតុផលបញ្ចេញមតិ បានន័យថា រចនាសម្ព័ន្ធដឹកនាំក្នុងរដ្ឋសភាមិនរឹងមាំ និងធ្វើឲ្យស្ថាប័នរដ្ឋសភាបាត់បង់តម្លៃ និងការជឿទុកចិត្ត ព្រោះអ្វីៗកំពុងប្រព្រឹត្តិទៅក្រោមឥទ្ធិពលនៃនយោបាយ។

ការដកតំណែងអនុប្រធានទី១របស់ឯកឧត្តម កឹម សុខា ត្រូវបានគេមើលឃើញថា ជាយុទ្ធសាស្ត្រដើម្បីបំបាក់ស្មារតីថ្នាក់ដឹកនាំ និងសកម្មជនគណបក្សប្រឆាំងឯទៀត ដែលនៅបន្តធ្វើការរិះគន់សម្តេច ហ៊ុន សែន និងរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៥នេះ ហើយវាជារឿងនយោបាយសុទ្ធសាធ ព្រោះថា ការរិះគន់រាជរដ្ឋាភិបាលពីសំណាក់មន្ត្រីនៃគណបក្សនៅក្រៅរដ្ឋាភិបាល និងមានអាសនៈក្នុងរដ្ឋសភា គឺជាការអនុវត្តន៍តួនាទីរបស់ខ្លួនក្នុងសង្គមប្រជាធិបតេយ្យ ដែលមិនគួរមានការរឹតត្បិត ឬទទួលរងការកំរាមកំហែងនោះទេ។

នៅក្រោយការដកតំណែងនេះ មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជាថា វាមិនប៉ះពាល់វប្បធម៌សន្ទនាទេ គណបក្សប្រជាជនកម្ពុជានៅតែថែរក្សាវប្បធម៌សន្ទនាជាមួយគណបក្សសង្គ្រោះជាតិ។ ទន្ទឹមគ្នានេះប្រធានរដ្ឋសភាសម្តេច ហេង សំរិន បានផ្ញើលិខិតទៅកាន់ឯកឧត្តម សម រង្ស៊ី ប្រាប់ពីការបោះឆ្នោតទម្លាក់ឯកឧត្តម កឹម សុខា ចេញពីតំណែង និងបានស្នើឲ្យឯកឧត្តម សម រង្ស៊ី បញ្ជូនឈ្មោះបេក្ខជនសម្រាប់តំណែងអនុប្រធានទី១ រដ្ឋសភា ដើម្បីឲ្យសភារៀបចំការបោះឆ្នោតជ្រើសតាំងបេក្ខជននោះជំនួសឯកឧត្តម កឹម សុខា។ ប៉ុន្តែគណបក្សសង្គ្រោះជាតិសម្រេចមិនបញ្ជូនបេក្ខជនថ្មីដើម្បីជំនួសកន្លែងឯកឧត្តម កឹម សុខា ឡើយ។

### ៦.១៣ សិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភារបស់ឯកឧត្តម សម រង្ស៊ី ត្រូវបាត់បង់

កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឯកឧត្តម សម រង្ស៊ី ដោយរងការចោទប្រកាន់ពីបទ បរិហាកេរ្តិ៍ជាសាធារណៈ និងញុះញង់ឲ្យមានការរើសអើង ប្រព្រឹត្តនៅសារមន្ទីរជើងឯង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨។ ឯកឧត្តមត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ឆ្នាំ និងពិន័យជាប្រាក់ ៨លានរៀល។

ក្រោយការចេញដីការបស់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ រដ្ឋសភា ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា (គណបក្សកាន់អំណាច) បានចេញសេចក្តីប្រកាសរបស់ខ្លួន ដែលមានខ្លឹមសារថា ឯកឧត្តម សម រង្ស៊ី ត្រូវបាត់បង់ទាំងស្រុកនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភា មណ្ឌលខេត្តកំពង់ចាម នីតិកាលទី៥។ ការប្រកាសរបស់រដ្ឋសភា គឺយោងលើសាលក្រមព្រហ្មទណ្ឌលេខ ៨៩ (ច) ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាស្ថាពរលេខ ១៧ ក្រ៥. ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍។

ការប្រកាសរបស់រដ្ឋសភា បានធ្វើឲ្យខូចតម្លៃ និងប្រព័ន្ធច្បាប់ក្នុងការការពាររដ្ឋសភា និងអ្នកតំណាងរាស្ត្រយ៉ាងធ្ងន់ធ្ងរ។ មាត្រា ២៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានបញ្ជាក់អំពី លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌជាច្រើនផ្សេងទៀត ដើម្បីឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជនដែលមិនត្រូវបានការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដូច្នេះមានន័យថា គ្មានសមាជិករដ្ឋសភាណាជាប់ទោសឧក្រិដ្ឋ ឬទោសមជ្ឈិម នៅពេលខ្លួនត្រូវបានប្រកាសសុពលភាពជាតំណាងរាស្ត្រនោះទេ។ លើសពីនេះ ប្រកាសនេះធ្វើឲ្យខូចន័យ និងប្រសិទ្ធិភាពនៃសមាជិកភាពរដ្ឋសភា និងអភ័យឯកសិទ្ធិសភា ដែលការពារដោយរដ្ឋធម្មនុញ្ញ ក្នុងមាត្រា ៨០។

ដោយឡែកសំណុំរឿងរបស់អ្នកតំណាងរាស្ត្រប្រាំពីរ (៧)រូប នៃគណបក្សសង្គ្រោះជាតិ ទាក់ទងបាតុកម្មនៅក្បែរទីលានប្រជាធិបតេយ្យ អាចនឹងត្រូវបានតុលាការបន្តនីតិវិធីរបស់ខ្លួនផងដែរ។

## VII. កាលប្បវត្តិព្រឹត្តិការណ៍សំខាន់ៗទាក់ទងរដ្ឋសភា និងតំណាងរាស្ត្រ

- ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០១ ៖
  - ការបោះឆ្នោតជ្រើសរើសសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន ១រូប លើកទី១។
- ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០២ ៖
  - សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៥។
  - សេចក្តីព្រាងច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក។
- ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅវិមានរដ្ឋសភាមានជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជាដឹកនាំដោយសម្តេច **ហ៊ុន សែន** និងគណបក្សសង្គ្រោះជាតិដឹកនាំដោយ ឯកឧត្តម **សម រង្ស៊ី** ពិភាក្សាលើបញ្ហាមួយចំនួនដូចខាងក្រោម៖
  - ដំណើរការស្ថានីយទូរទស្សន៍ (ស្ថានីយទូរទស្សន៍របស់គណបក្សសង្គ្រោះជាតិ)
  - ការធ្វើវិសោធនកម្មប្រការ ៤៨ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
  - បញ្ហាមិនចុះសម្រុងគ្នានៅក្នុងសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គ.ជ.ប និងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។
- ថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៤ គណៈប្រតិភូសភាកម្ពុជាចូលរួមកិច្ចប្រជុំពេញអង្គលើកទី ៧ របស់សភាតំបន់អាស៊ី (APA) បានប្រព្រឹត្តទៅក្នុងទីក្រុងឡាហ័រ ប្រទេសប៉ាគីស្ថាន។
- ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០១ ៖
  - វិសោធនកម្មប្រការ ៤៨ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

- ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល បានកោះហៅអ្នកតំណាងរាស្ត្រ **កែវ ភីរម្យ** មណ្ឌលខេត្តក្រចេះពីគណបក្សសង្គ្រោះជាតិ ចូលរួមសវនាការពីបទដឹកនាំកុប្បកម្ម ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចទីលានប្រជាធិបតេយ្យ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤។

- ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៥ រដ្ឋសភាប្រកាសទទួលស្គាល់ឯកឧត្តម **ស ខេង** ជាថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា និងឯកឧត្តម **សម រង្ស៊ី** ជាថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិ។ ជាមួយគ្នានេះ រដ្ឋសភាក៏បានប្រកាសទទួលស្គាល់ឯកឧត្តម **សម រង្ស៊ី** ជាប្រធានក្រុមមតិភាគតិចនៅរដ្ឋសភាផងដែរ។

- ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ឯកឧត្តម **សូ យុន** តំណាងរាស្ត្រមណ្ឌលខេត្តតាកែវ បានទទួលមរណភាព ក្នុងជន្មាយុ ៧១ឆ្នាំ ដោយរោគាពាធ។

- ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ថ្នាក់ដឹកនាំតំណាងរាស្ត្រ ដឹកនាំដោយ ឯកឧត្តម **ស ខេង** និងឯកឧត្តម **សម រង្ស៊ី** នៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាជួបប្រជុំលើកដំបូងពិភាក្សាជុំវិញការលើកកម្ពស់វប្បធម៌ សន្ទនារវាងគណបក្សទាំងពីរ។

- ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ រដ្ឋសភាប្រកាសទទួលស្គាល់ឯកឧត្តម **សុខ សូកាន** ជាតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជា ប្រចាំមណ្ឌលតាកែវ ជំនួសឯកឧត្តម **សូ យុន** ដែលបានទទួលមរណភាព។

- ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៥ អ្នកតំណាងរាស្ត្រ **វ៉ាន សំអឿន** មណ្ឌលខេត្តកំពត ពីគណបក្សសង្គ្រោះជាតិបានប្រកាសសុំលាលែងពីសមាជិករដ្ឋសភា ដោយលើកមូលហេតុថា ខ្លួនគ្មានឱកាស និងបម្រើជាតិតាមឆន្ទៈ និងបទពិសោធន៍។

- ខែកុម្ភៈ ឆ្នាំ២០១៥ រដ្ឋសភាប្រកាសទទួលស្គាល់ឯកឧត្តម **ដាង ចំរើន** ជាតំណាងរាស្ត្រមណ្ឌលខេត្តកំពត ជំនួសឯកឧត្តម **វ៉ាន សំអឿន** ដែលបានលាឈប់។

- ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សដែលមានអាសនៈក្នុងរដ្ឋសភាបានព្រម ព្រៀងចាត់តាំងក្រុមការងារតាក់តែងសេចក្តីស្នើច្បាប់ភតិសន្យាពិសេស (កិច្ចសន្យាជួលផ្ទះ) ក្នុងវិស័យសង្គមកិច្ចដើម្បីបញ្ចៀសការដំឡើងថ្លៃឈ្នួលផ្ទះ។

- ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៥ រដ្ឋសភារៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប។

- ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥ សាលាដំបូងខេត្តកណ្តាលបានសម្រេចផ្តន្ទាទោសចំនួន ២ឆ្នាំ លើអ្នកតំណាងរាស្ត្រ **ចាន់ ចេង** មណ្ឌលខេត្តកណ្តាល ពីគណបក្សសង្គ្រោះជាតិ ពីបទផ្តល់មធ្យោបាយលួចរត់ តាមមាត្រា ៥៦៥ នៃក្រុមព្រហ្មទណ្ឌ។ ការផ្តន្ទាទោសនេះធ្វើឡើងទាំងតំណាងរាស្ត្រនៅមានអភ័យឯកសិទ្ធិ។

- ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ រដ្ឋសភាបានសម្រេចបង្កើតឱ្យមានអ្នកនាំពាក្យជាផ្លូវការរបស់ខ្លួន ដែលមានឯកឧត្តម **ឈាង វុន** ប្រធានគណៈកម្មការទី៥នៃរដ្ឋសភា ជាអ្នកនាំពាក្យ និងលោកជំទាវ **ជូឡុង សូម៉ារ៉ា** ជាអនុប្រធានគណៈកម្មការទី៥នៃរដ្ឋសភា ជាអ្នកនាំពាក្យបម្រុង។

- ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គជាវិសាមញ្ញ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០២៖
    - សេចក្តីស្នើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
    - សេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

- ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ សាលាដំបូងរាជធានីភ្នំពេញចេញដីកាកោះហៅឯកឧត្តម **កឹម សុខា** អនុប្រធានទី១ នៃរដ្ឋសភា ទៅឆ្លើយបំភ្លឺ នៅថ្ងៃទី៨ ខែមេសា ដោយមិនបានបញ្ជាក់ប្រាប់អំពីបទចោទ។

- ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥ រដ្ឋសភាស្នើទៅគណបក្សដែលមានអាសនៈក្នុងរដ្ឋសភាជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងបញ្ជី ដែលសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។

- ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ឯកឧត្តម **កឹម សុខា** អនុប្រធានទី១នៃរដ្ឋសភា ចូលខ្លួនបំភ្លឺនៅសាលាដំបូងរាជធានីភ្នំពេញតាមដីកាកោះចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥។

- ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥
    - រដ្ឋសភាបោះឆ្នោតទុកចិត្តប្រធាន អនុប្រធាន សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
    - រដ្ឋសភាបោះឆ្នោតជ្រើសតាំង៖
        - លោកជំទាវ **ទេព សុទ្ធី** ជាសមាជិកគណៈកម្មការទី៣នៃរដ្ឋសភា។
        - ឯកឧត្តម **ម៉ែន សុថាវរិន្ទ្រ** ជាសមាជិកគណៈកម្មការទី៨នៃរដ្ឋសភា។
        - ឯកឧត្តម **សុខ សូកាន** ជាសមាជិកគណៈកម្មការទី៩នៃរដ្ឋសភា។
        - ឯកឧត្តម **ដាង ចំរើន** ជាសមាជិកគណៈកម្មការទី១០នៃរដ្ឋសភា។

- ខែឧសភា ឆ្នាំ២០១៥ តំណាងរាស្ត្រចំនួន៧រូប (លោកជំទាវ **មូរ សុខហួរ** ឯកឧត្តម **ហូរ វ៉ាន់** ឯកឧត្តម **ឡុង រី** ឯកឧត្តម **កែវ ភិរម្យ** ឯកឧត្តម **ម៉ែន សុថាវរិន្ទ** ឯកឧត្តម **រៀល ខេមរិន្ទ្រ** និងឯកឧត្តម **នុត រំដួល** ត្រូវបានសាលាដំបូងរាជធានីភ្នំពេញចេញដីកាបង្គាប់ឲ្យចូលឆ្លើយបំភ្លឺ ដើម្បីសាកសួរបន្ថែមជុំវិញសំណុំរឿងព្រហ្មទណ្ឌ នឹងហិង្សានៅក្បែរទីលានប្រជាធិបតេយ្យកាលពីខែកក្កដា ឆ្នាំ២០១៤។

- ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មណ្ឌលខេត្តបាត់ដំបង ចូលទៅបំភ្លឺនៅសាលាដំបូងរាជធានីភ្នំពេញទាក់ទងនឹងហិង្សាក្បែរទីលានប្រជាធិបតេយ្យកាលពីខែកក្កដា ឆ្នាំ២០១៤។

- ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ រដ្ឋសភារៀបចំ សិក្ខាសាលាស្វែងយល់ពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

- ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ រដ្ឋសភារៀបចំសិក្ខាសាលា ស្វែងយល់ពី "ការឈ្វេងយល់ពីច្បាប់ និងការអនុវត្តន៍ច្បាប់ ស្តីពីការប្រឆាំងអំពីពុករលួយ"។

- ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន០៣ ៖
    - ការបោះឆ្នោតជ្រើសតាំងឯកឧត្តម **អាយ ខន** ជាសមាជិកគណៈកម្មការទី១០នៃរដ្ឋសភា។

o សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ។

- ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៥ ប្រធានរដ្ឋសភាបានបដិសេធសំណើសុំធ្វើសន្និសីទកាសែតនៅវិមានរដ្ឋសភាទាក់ទងនឹងបញ្ហាព្រំដែនកម្ពុជា-វៀតណាម របស់អ្នកតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ។

- ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន០១៖

o សេចក្តីព្រាងច្បាប់ស្តីពី ការទូតទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣។

- ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៥ អ្នកតំណាងរាស្ត្រ **រៀល ខេមរិន្ទ្រ** ត្រូវបានអាជ្ញាធរ និងពលរដ្ឋវៀតណាម វាយឲ្យរងរបួសធ្ងន់ ខណៈចុះពិនិត្យព្រំដែនកម្ពុជា-វៀតណាម ត្រង់ចំណុចភូមិគោកធ្លក ឃុំឆ្នោត ស្រុកកំពង់រោ ខេត្តស្វាយរៀង។

- ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន០២ ៖

o ការបោះឆ្នោតជ្រើសតាំងឯកឧត្តម **ជា អឿង** ជាសមាជិកគណៈកម្មការទី៣នៃរដ្ឋសភា។

o សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣។

- ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ រដ្ឋសភាបន្តសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន០១ ៖

o សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣។

- ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ អ្នកតំណាងរាស្ត្រ **ឈាង វុន** ពីគណបក្សប្រជាជនកម្ពុជា បានបណ្តេញអ្នកតំណាងរាស្ត្រ **អ៊ុំ សំអាន** ពីគណបក្សសង្គ្រោះជាតិ មិនឲ្យផ្តល់បទសម្ភាសន៍ដល់អ្នកកាសែតនៅក្នុងបរិវេណមន្ទីររដ្ឋសភា។

- ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ រដ្ឋសភារៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

- ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន០២ ៖

o ការបោះឆ្នោតជ្រើសតាំងឯកឧត្តម **កែវ ពិសិដ្ឋ** ជាសមាជិកគណៈកម្មការទី៦នៃរដ្ឋសភា។

o សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

- ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ រដ្ឋសភាចេញសេចក្តីសម្រេច ស្តីពីការដាក់ទណ្ឌកម្មខាងវិន័យចំពោះឯកឧត្តម **អ៊ុំ សំអាន** តំណាងរាស្ត្រមណ្ឌលខេត្តសៀមរាប។

- ថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ សភានៃព្រះរាជាណាចក្រកម្ពុជា រៀបចំកិច្ចប្រជុំក្រុមអ្នកនយោបាយអាយប៉ា លើកទី៧ ក្រោមប្រធានបទ «ទេសចរណ៍អាស៊ានៈ ជម្រុញការអភិរក្សធម្មជាតិ និងការអភិវឌ្ឍន៍ទេសចរណ៍ ប្រកបដោយចីរភាព»។

- ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ក្រុមអ្នកនយោបាយនៃអន្តរសភាអាស៊ាន ដែលហៅកាត់ថា អាយប៉ា បានជួបប្រជុំគ្នារយៈពេលពីរថ្ងៃនៅក្នុងខេត្តសៀមរាបពិភាក្សាអំពី ការអភិរក្សធនធានធម្មជាតិ និងអភិវឌ្ឍវិស័យទេសចរណ៍អាស៊ានឲ្យមានចីរភាព។

- ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ រដ្ឋសភារៀបចំសិក្ខាសាលាស្តីពី «សុខដុមនីយកម្មក្នុងវិស័យសាសនានៅកម្ពុជា»។

- ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ អង្គភាពប្រឆាំងអំពើពុករលួយបានចេញលិខិតមួយច្បាប់ស្នើឲ្យអ្នកតំណាង រាស្ត្រ រៀល ខេមរិន្ទ្រ មណ្ឌលខេត្តស្វាយរៀង ពីគណបក្សសង្គ្រោះជាតិ ធ្វើលិខិតបកស្រាយជាលាយលក្ខណ៍អក្សរដោយភ្ជាប់ជាមួយ ឯកសារពាក់ព័ន្ធ ដើម្បីការពារខ្លួនចំពោះបណ្ដឹងចំនួន៣ ដែលគេប្ដឹងមកអង្គភាពនេះពីបទកេងប្រវ័ញ្ចប្រាក់ចំនួន៥ម៉ឺន៥ពាន់ ដុល្លារអាមេរិក ពីការរៀបចំដំណើរការទៅព្រំដែនកម្ពុជា-វៀតណាម។

- ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ថ្នាក់ដឹកនាំតំណាងរាស្ត្រ ដឹកនាំដោយ ឯកឧត្តម **ស ខេង** និងឯកឧត្តម **កឹម សុខា** នៃ គណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាជួបប្រជុំពិភាក្សា អំពីការពង្រឹង និងបន្តវប្បធម៌សន្ទនារវាងគណបក្សទាំងពី រ។ របៀបវារៈចំនួន៥ ត្រូវបានលើកមកពិភាក្សាដូចជាៈ ១.ការប្ដេជ្ញាពង្រឹងកិច្ចព្រមព្រៀងនយោបាយថ្ងៃ២២ កក្កដា, ២. ពិភាក្សាលើធ្វើវិសោធនកម្មច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល, ៣.បញ្ហាព្រំដែន, ៤.កាលបរិច្ឆេទរៀបចំការបោះ ឆ្នោតជាតិ, និង៥.បញ្ហាចាប់ខ្លួនសកម្មជនគណបក្សសង្គ្រោះជាតិ។ ទោះជាយ៉ាងណាជំនួបនោះមិនបានបង្ហាញអំពីលទ្ធផល ទៅលើបញ្ហាទាំង៥ ដែលលើកមកពិភាក្សានោះទេ។

- ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៥ រដ្ឋសភារៀបចំពិធីសម្ពោធសៀវភៅសភាស្ដីពី «សេវាកម្មសំខាន់ៗសម្រាប់តំណាងរាស្ត្រ»។

- ថ្ងៃទី១៥ ដល់ ១៦ ខែកញ្ញា ឆ្នាំ២០១៥ រដ្ឋសភារៀបចំសិក្ខាសាលាស្ដីពី «បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និង តម្លាភាពសភា» នៅសណ្ឋាគារ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ ក្នុងគោលបំណងពង្រឹងសមត្ថភាពកិច្ចការ ព័ត៌មាន និងគមនាគមន៍ សភាកម្ពុជា ក្នុងការផលិត គ្រប់គ្រង ផ្សព្វផ្សាយ និងថែរក្សាព័ត៌មានឲ្យបានកាន់តែប្រសើរឡើង និងមានទំនើបកម្មនៅក្នុង សម័យបច្ចេកវិទ្យាជឿនលឿននេះ។

- ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ ថ្នាក់ដឹកនាំតំណាងរាស្ត្រ ដឹកនាំដោយ ឯកឧត្តម **ស ខេង** និងឯកឧត្តម **សម រង្ស៊ី** នៃ គណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាជួបប្រជុំពិភាក្សាអំពីបញ្ហាបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបញ្ហាកំណែទម្រង់ ច្បាប់បោះឆ្នោតឃុំ-សង្កាត់។

- ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ ឯកឧត្តម **កង ហ៊ាង** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ស្ពឺ បានទទួលមរណភាព ក្នុងជន្មា យុ ៦៥ឆ្នាំ ដោយរោគាពាធ។

- ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៥ ថ្នាក់ដឹកនាំតំណាងរាស្ត្រ ដឹកនាំដោយ ឯកឧត្តម **ស ខេង** និងឯកឧត្តម **សម រង្ស៊ី** នៃ គណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាជួបប្រជុំពិភាក្សាអំពីគណៈកម្មការពិសេស ចំពោះកិច្ចរៀបចំតាក់តែងសេច ក្ដីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

- ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ថ្នាក់ដឹកនាំតំណាងរាស្ត្រ ដឹកនាំដោយ ឯកឧត្តម **ស ខេង** និងឯកឧត្តម **សម រង្ស៊ី** នៃ គណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភាជួបប្រជុំពិភាក្សាអំពីបញ្ហាដែលសេសសល់ ពាក់ព័ន្ធនឹងការធ្វើវិសោធន កម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

- ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន០៦ ៖

  - ព្រះរាជសារព្រះករុណាព្រះបាទសម្ដេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រ កម្ពុជា ជូនសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ។

- o របាយការណ៍ស្តីពីសកម្មភាពរបស់រដ្ឋសភា ចន្លោះសម័យប្រជុំរដ្ឋសភាលើកទី៤ និងលើកទី៥ នីតិកាលទី៥ ។
- o សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលបេឡារុស។
- o សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលបេឡារុស ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ។
- o សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលរុស្ស៊ី ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃវិនិយោគ។
- o សេចក្តីស្នើច្បាប់ ស្តីពីវិសោធនកម្មមាត្រាទី២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា។

- ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ រដ្ឋសភាបើកសម័យប្រជុំពេញអង្គ ពិភាក្សា និងអនុម័តរបៀបវារៈចំនួន០៣ ៖
  - o ការបោះឆ្នោតដកតំណែងអនុប្រធានទី១ នៃរដ្ឋសភាពីឯកឧត្តម **កឹម សុខា**។
  - o សេចក្តីស្នើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។
  - o សេចក្តីស្នើវិសោធនកម្មប្រការ ៣ថ្មី ប្រការ ៧ថ្មី ប្រការ ៨ ប្រការ ១០ថ្មី(ពីរ) ប្រការ ១៤ថ្មី ប្រការ ១៨ ប្រការ ២០ ប្រការ ២១ ប្រការ ២២ថ្មី ប្រការ ៣១ថ្មី(ពីរ) ប្រការ ៣៣ថ្មី ប្រការ ៣៤ ប្រការ ៣៦ថ្មី ប្រការ ៣៨ថ្មី ប្រការ ៤០ថ្មី និងប្រការ ៤៧ថ្មី(បី) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។

# ឧបសម្ព័ន្ធ

# ការវាយតម្លៃរបស់គណៈកម្មាធិការខុមហ្វ្រែលលើចំណុចផ្លាស់ប្តូរនៃបញ្ញត្តិនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

<table>
<tr>
<td>ល.រ</td>
<td>ចំណុចផ្លាស់ប្តូរនៃប្រការនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា<br><br>ឃ្លាដែលមានគូសបន្ទាត់ពីក្រោមជាចំណុចសំខាន់ដែលផ្លាស់ប្តូរ។</td>
<td>ការវាយតម្លៃរបស់ខុមហ្វ្រែល ដោយធ្វើការប្រៀបធៀបបញ្ញត្តិក្នុងបទបញ្ជាផ្ទៃក្នុងចាស់ និងបញ្ញត្តិក្នុងបទបញ្ជាផ្ទៃក្នុងថ្មី និងអនុសាសន៍របស់ខុមហ្វ្រែល និងអង្គការសង្គមស៊ីវិលនានាទៅលើបញ្ញត្តិដែលបានផ្លាស់ប្តូរ។<br><br>ពាក្យគន្លឹះដែលមាននៅក្នុងការវាយតម្លៃនេះ៖<br>• វិជ្ជមាន សំដៅលើការរីកចំរើនខ្លះៗ ឬប្រសើរជាងមុន អវិជ្ជមាន សំដៅលើការផ្លាស់ប្តូរដែលអាក្រក់ជាងបញ្ញតិចាស់<br>• មិនច្បាស់ សំដៅលើអត្ថន័យដែលអាចបកស្រាយជាចំណុចវិជ្ជមាន ឬអវិជ្ជមាន<br>• អក្សរពណ៌បៃតងជាចំណុចវិជ្ជមាន និងជាអនុសាសន៍របស់ខុមហ្វ្រែល<br>• អក្សរពណ៌ក្រហមសំដៅលើចំណុចអវិជ្ជមាន ឬចំណុចមិនច្បាស់លាស់</td>
</tr>
<tr>
<td colspan="3" align="center">ជំពូកទី ២ ៖ អំពីសុពលភាពនៃអ្នកតំណាងរាស្ត្រ</td>
</tr>
<tr>
<td>១</td>
<td>ប្រការ ៣ ថ្មី (ពីរ)<br>នៅពេលបើកសម័យប្រជុំខាងលើនេះ ព្រឹទ្ធសមាជិករដ្ឋសភាប្រកាសជូនអង្គសភាៈ<br>-ឈ្មោះបេក្ខជនជាប់ឆ្នោតជាស្ថាពរ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជូនមក។<br>-ឈ្មោះបេក្ខជនជាប់ឆ្នោតដែលមានគេប្តឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្តឹងទាំងនោះ។<br>ការប្រកាសសុពលភាពខាងលើនេះ មិនអាចធ្វើបានឡើយ ក្នុងករណីដែលមានគណបក្សនយោបាយណាមួយទទួលអាសនៈមួយ ឬច្រើនក្នុងរដ្ឋសភាធ្វើពហិការមិនព្រមចូលរួមសម័យប្រជុំដំបូងតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ឬធ្វើពហិការមិនព្រមចូលរួមប្រជុំរដ្ឋសភាសម្រាប់ការប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ។<br>ក្នុងករណីនេះ ព្រឹទ្ធសមាជិករដ្ឋសភាត្រូវចាត់នីតិវិធី តាមបទប្បញ្ញត្តិនៃមាត្រា១៣៨</td>
<td>បញ្ញត្តិនេះមានភាពមិនច្បាស់លាស់។ គោលបំណងនៃបញ្ញត្តិ គឺរកដំណោះស្រាយក្នុងការធានាការបង្កើតរដ្ឋសភា នៅបន្ទាប់ពី គ.ជ.ប ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការ។ បញ្ញត្តិនេះ (ត្រូវបានដកស្រង់ពីមាត្រា១៣៨នៃច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ) ក៏បង្កើតនូវភាពស្មុគស្មាញនៃនីតិវិធីក្នុងផ្តល់សុពលភាពសមាជិករដ្ឋសភា និងការដកអាសនៈពីគណបក្សនយោបាយជាប់ឆ្នោត តាមរយៈកិច្ចប្រជុំដំបូងរបស់រដ្ឋសភា ឬពេលស្បថចូលកាន់តំណែងរបស់អ្នកតំណាងរាស្ត្រ។ សំណួរសួរថា តើអ្នកណាជារដ្ឋសភាដែលសុពលភាព រដ្ឋសភាថ្មី ឬរដ្ឋសភាចាស់ក្នុងការស្នើដកអាសនៈពីគណបក្សជាប់ឆ្នោត ឬគណបក្សជាច្រើនដែលសម្រេចធ្វើពហិការ។<br>ខុមហ្វ្រែលស្នើថា បញ្ញត្តិនៃច្បាប់បោះឆ្នោតថ្មី ត្រូវផ្តល់អំណាច គ.ជ.ប ឬ/និង ព្រះមហាក្សត្រ ក្នុងការប្រកាសសុពលភាពសមាជិកភាពរដ្ឋសភា នៅបន្ទាប់ពីការលទ្ធ</td>
</tr>
</table>

| | | |
|---|---|---|
| | នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។<br>ឈ្មោះតំណាងរាស្ត្រទាំងអស់ ដែលបានប្រកាសសុពលភាពរួចហើយ ត្រូវបិទផ្សាយក្នុងរដ្ឋសភា ផ្សព្វផ្សាយជាសាធារណៈក្រោយពេលប្រជុំ និងត្រូវចុះផ្សាយក្នុងរាជកិច្ចក្រោយពីបានធ្វើសច្ចាប្រណិធានចូលកាន់តំណែង។ | ផលបោះឆ្នោតផ្លូវការ ជាមួយនឹងបេក្ខជនជាប់ឆ្នោតយ៉ាងតិច១២០រូប។ ចំពោះសមាជិករដ្ឋសភាធ្វើពហិការក្នុងការស្បថចូលកាន់តំណែង ឬចូលរួមកិច្ចប្រជុំរបស់រដ្ឋសភា ត្រូវទទួលទណ្ឌកម្មក្រោមបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។ |
| **ជំពូកទី ៣ ៖ អំពីគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានានៃរដ្ឋសភា** | | |
| ២ | **ប្រការ ៦ ថ្មី** (**ពីរ**)<br>គណៈកម្មការនានានៃរដ្ឋសភាមាន:<br>១. គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា<br>២. គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម<br>៣. គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក<br>៤. គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ<br>៥. គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន<br>៦. គណៈកម្មការនីតិកម្ម និងយុត្តិធម៌<br>៧. គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍<br>៨. គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី<br>៩. គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដីនគរូបនីយកម្ម និងសំណង់<br>១០. គណៈកម្មការសង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ។ | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះបានបន្ថែមគណៈកម្មការដែលធ្វើការលើការប្រឆាំងអំពើពុករលួយ នៅស្របពេលដែលមន្ត្រីនៃស្ថាប័នសាធារណៈរបស់រដ្ឋមួយចំនួនកំពុងប្រព្រឹត្តអំពើពុករលួយ ដែលធ្វើឲ្យបាត់បង់ថវិកាជាតិយ៉ាងច្រើនក្នុងមួយឆ្នាំៗ និងបង្កើតចំនួនគណៈកម្មការ ដើម្បីធ្វើការត្រួតពិនិត្យការងារនីតិប្រតិបត្តិ។ ចំនួនដប់(១០) គណៈកម្មការ គឺងាយក្នុងការបែងចែកស្មើគ្នាទៅគណបក្សកាន់អំណាច និងគណបក្សមិនកាន់អំណាចដែលមានអាសនៈក្នុងរដ្ឋសភា។<br><br>ទន្ទឹមគ្នានេះ ខុមហ្វ្រែលផ្តល់យោបល់ថា វិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា (ជាក្របខ័ណ្ឌច្បាប់) គួរដាក់បញ្ចូលគោលការណ៍បែងចែកការដឹកនាំគណៈកម្មការនៅក្នុងរដ្ឋសភាថា គណបក្សដឹកនាំរាជរដ្ឋាភិបាលទទួលតួនាទីដឹកនាំគណៈកម្មការមានចំនួនស្មើនឹង ចំនួនគណៈកម្មការដឹកនាំដោយគណបក្សមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល។ |
| ៣ | **ប្រការ ៧ ថ្មី** (**ពីរ**)<br>គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាមាន: | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះបានចែងលំអិតអំពីភារកិច្ចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងការបែងចែកសិទ្ធិអំណាចច្បាស់អំពីគណៈកម្មាធិការអចិន្ត្រៃ |

| | | |
|---|---|---|
| | -ប្រធានរដ្ឋសភា<br>-អនុប្រធានទាំងពីរ នៃរដ្ឋសភា<br>-ប្រធានគណៈកម្មការនានា នៃរដ្ឋសភា។<br>ប្រធានរដ្ឋសភាជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។<br>កូរ៉ុមសម្រាប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវឲ្យមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិក។<br>គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា មានអាណត្តិស្មើនឹងនីតិកាលរបស់រដ្ឋសភា។<br>គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា មានភារកិច្ចដូចតទៅៈ<br>**ក**. ដឹកនាំ ចាត់ចែង និងពិនិត្យសម្រេចរាល់ការងារ សកម្មភាពផ្សេងៗរបស់រដ្ឋសភាក្នុងលក្ខខណ្ឌកំណត់នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ព្រមទាំងទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់នូវសេចក្ដីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ។<br>**ខ**. ចាត់ចែងការងាររបស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា។<br>**គ**. រៀបចំសមាសភាពលេខាធិការបីរូប សម្រាប់សម័យប្រជុំបន្ទាប់ ដើម្បីដាក់ជូនអង្គប្រជុំនៃរដ្ឋសភាអនុម័ត។<br>**ឃ**. ធានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។<br>**ង**. ធានាគ្រប់គ្រង និងការចំណាយថវិការដ្ឋសភាឲ្យប្រព្រឹត្តទៅបានត្រឹមត្រូវ តាមការកំណត់ក្នុងច្បាប់ស្ដីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។<br>**ច**. ធានាការផ្ដល់គ្រឿងឥស្សរិយយសជូនដល់សមាជិករដ្ឋសភា។<br>**ឆ**. ធានាការអនុវត្តវិន័យក្នុងរដ្ឋសភា។<br>**ជ**. លើកជូនរដ្ឋសភា អំពីករណីនៃការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភា ដោយអនុវត្តតាមកថាខណ្ឌទី៣ និងទី៤ នៃមាត្រា៨០ នៃរដ្ឋធម្មនុញ្ញ។<br>**ឈ**. លើកជូនរដ្ឋសភាពិនិត្យ និងសម្រេចលើការផ្អាកការឃុំខ្លួន ការចោទប្រកាន់សមាជិករដ្ឋសភាណាមួយ ដោយសំឡេងបីភាគបួននៃចំនួនសមាជិករដ្ឋសភា | យ៍រដ្ឋសភា ពិសេសការគ្រប់គ្រង និងការចំណាយថវិការបស់រដ្ឋសភា និងការធានាការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។ |

| | | |
|---|---|---|
| | ទាំងមូល។<br>៣. លើកជូនរដ្ឋសភាពិនិត្យ និងសម្រេចអំពីការលើកអភ័យឯកសិទ្ធិសភា ការប្រគល់ជូនវិញនូវអភ័យឯកសិទ្ធិសភា ការបោះបង់ចោលការងារ វិសមិតភាព និងការប្រាសចាកសមាជិកភាពរដ្ឋសភា ដោយសំឡេងពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ | |
| ៤ | **ប្រការ ៨ ថ្មី**<br>ប្រធានរដ្ឋសភាមានមុខការដូចតទៅនេះ:<br>**ក**. ធានាការប្រព្រឹត្តទៅនៃរដ្ឋសភាឲ្យបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ទទួលអញ្ញត្តិច្បាប់ និងសេចក្តីសម្រេចចិត្តទាំងឡាយដែលរដ្ឋសភាបានអនុម័ត ព្រមទាំងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា<br>**ខ**. ដឹកនាំអង្គប្រជុំនៃរដ្ឋសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា<br>**គ**. បើក និងលើកពេលប្រជុំនៃរដ្ឋសភា<br>**ឃ**. ចាត់ចែងការពិភាក្សា ហើយចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងការប្រជុំនៃរដ្ឋសភា<br>**ង**. ញ៉ាំងឲ្យប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា<br>**ច**. រក្សាការពារសណ្តាប់ធ្នាប់ក្នុងរដ្ឋសភា<br>**ឆ**. តំណាងរដ្ឋសភាក្នុងការទាក់ទងជាមួយព្រះមហាក្សត្រ និងអាជ្ញាធរសាធារណៈ។ | បញ្ញត្តិនេះមានភាពមិនច្បាស់លាស់ ព្រោះថា មុខការរបស់ប្រធានរដ្ឋសភាមានលក្ខណៈច្បាស់លាស់ជាច្រើន ប៉ុន្តែក៏ត្រូវបានបកស្រាយក្នុងការផ្តល់អំណាចមុខការដល់ប្រធាន។ សេចក្តីសម្រេចចិត្តខ្លះរបស់ប្រធានរដ្ឋសភាធ្វើឡើងដោយ មិនស្របតាមគោលការណ៍ប្រជាធិបតេយ្យ តម្លាភាព ប្រសិទ្ធភាព និងរដ្ឋធម្មនុញ្ញ ព្រមទាំងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា។ នៅពេលអនុវត្តមុខការនេះ ប្រធានរដ្ឋសភាបានរំលោភដូចជាការចេញ «សារាចរណែនាំស្តីពីបែបបទការងារស្តីពី គណៈកម្មការនានានៃរដ្ឋសភា ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤» ជាដើម។ |
| ៥ | **ប្រការ ១០ ថ្មី** (**ពី**)<br>ក្នុងករណីធម្មតា រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងដាច់ដោយឡែកពីគ្នានូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា។ គណៈកម្មការនីមួយៗត្រូវជ្រើសតាំង ប្រធានមួយរូប អនុប្រធានមួយរូប និងលេខាធិការមួយរូប ដោយវិធីបោះឆ្នោត។<br>ក្នុងករណីដែលស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ការជ្រើសរើសប្រធាន និងអនុប្រធានគណៈកម្មការនានានៃរដ្ឋសភា ត្រូវអនុវត្តតាមចំណុច ខ.២ នៃប្រការ២ថ្មី(ពីរ)។ បន្ទាប់មក រដ្ឋ | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះប្រធានគណៈកម្មការអាចកោះប្រជុំ បើមានការស្នើសុំពីសំណាក់សមាជិកគណៈកម្មការចំនួន៣រូប។ |

| | | |
|---|---|---|
| | សភាអាចដំណើរការបន្ត ដើម្បីជ្រើសតាំងដាច់ដោយឡែកពីគ្នានូវសមាជិកគណៈកម្មការនានានៃរដ្ឋសភា ដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>ពេលប្រធានគណៈកម្មការអវត្តមាន អនុប្រធានគណៈកម្មការបំពេញការងារជួសប្រធាន ក្នុងឋានៈជាប្រធានស្ដីទី តាមរយៈលិខិតផ្ទេរសិទ្ធិ។<br>កូរ៉ុមសម្រាប់ប្រជុំគណៈកម្មការនានា ត្រូវឲ្យមានលើសពីពាក់កណ្ដាលនៃចំនួនសមាជិក។<br>គណៈកម្មការនីមួយៗ មានសមាជិកយ៉ាងតិចប្រាំពីររូប។<br>តំណាងរាស្ត្រមួយរូប អាចជាសមាជិកពីរគណៈកម្មការបាន។<br>សមាជិកគណៈកម្មការចំនួន៣(បី)រូបយ៉ាងតិច អាចស្នើសុំប្រជុំគណៈកម្មការ។ សំណើនេះ ត្រូវជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់ពីមូលហេតុសមស្រប។ ប្រធានគណៈកម្មការ អាចកោះប្រជុំគណៈកម្មការ តាមសំណើខាងលើនេះបាន។ | |
| | **ជំពូកទី ៤ ៖ អំពីអគ្គលេខាធិការដ្ឋាន** | |
| ៦ | **ប្រការ ១៤ ថ្មី** (ពីរ)<br>រដ្ឋសភាមានអគ្គលេខាធិការដ្ឋានមួយ ដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោមៈ<br>**ក.** រៀបចំធ្វើកំណត់ហេតុរបស់រដ្ឋសភា<br>**ខ.** ទទួលរ៉ាប់រងនូវគ្រប់កិច្ចការរដ្ឋបាល និងសេវានានាជូនរដ្ឋសភា<br>**គ.** ទំនាក់ទំនងផ្សេងៗក្រៅរដ្ឋសភា<br>**ឃ.** ទទួលរ៉ាប់រងសន្តិសុខ និងសណ្ដាប់ធ្នាប់នៅក្នុងរដ្ឋសភា<br>**ង.** ទទួលភារកិច្ចផ្សេងៗដែលប្រធានរដ្ឋសភាប្រគល់ឲ្យ<br>**ច.** អនុវត្តតួនាទី និងភារកិច្ចដែលមានកំណត់នៅក្នុងសេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ | បញ្ញត្តិនេះមានភាពមិនច្បាស់លាស់ ព្រោះថា ប្រការនេះបានកំណត់អំពីតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន ប៉ុន្តែចំណុចដែលទទួលភារកិច្ចរបស់ប្រធានរដ្ឋសភា និងការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហាក់ឲ្យអគ្គលេខាធិការដ្ឋាននៅក្រោមការត្រួតត្រារបស់គណបក្សកាន់អំណាច។ ចំណុចខ្លះនៃប្រការនេះ អាចមានការអនុវត្តន៍មិនស្មើភាពគ្នា និងរឹតត្បិតចំពោះភាគីពាក់ព័ន្ធ ពិសេសម្ចាស់ឆ្នោតក្នុងការទាក់ទងអ្នកតំណាងរាស្ត្រ និងរដ្ឋសភា ដោយយកមូលហេតុសន្តិសុខ និងសណ្ដាប់ធ្នាប់។ អគ្គលេខាធិការដ្ឋានរដ្ឋសភា គួរមានតួនាទី និងភារកិច្ចច្បាស់បន្ថែមអំពីការទទួលភារកិច្ចពី ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ ដែលមានអាសនៈក្នុងរដ្ឋសភា។ |
| ៧ | **ប្រការ ១៨ ថ្មី**<br>កំណត់ហេតុទាំងអស់ និងឯកសារដទៃទៀតរបស់រដ្ឋសភា ត្រូវរក្សាទុកនៅក្នុងអគ្គលេខាធិការដ្ឋានរដ្ឋសភា។ អគ្គលេខាធិការរដ្ឋសភា អាចផ្ដល់ជូនសាធារណជន និង | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះបានបង្ហាញថា រដ្ឋសភានឹងមានការបើកចំហក្នុងការផ្ដល់នូវឯកសារនានារបស់ខ្លួនជូនសាធារណជន និងអ្នកតំណាងរាស្ត្រ។ |

| | | |
|---|---|---|
| | តំណាងរាស្ត្រនូវកំណត់ហេតុ និងឯកសារខាងលើតាមការស្នើសុំ លើកលែងតែកំណត់ហេតុ និងឯកសារសម្ងាត់ដែលត្រូវមានការអនុញ្ញាតពីប្រធានរដ្ឋសភា។ | ទន្ទឹមគ្នានេះ ខុមហ្វ្រែលផ្តល់យោបល់ថា អគ្គលេខាធិការរដ្ឋសភា ត្រូវផ្តល់ជូនសាធារណជន និងតំណាងរាស្ត្រនូវកំណត់ហេតុ និងឯកសារខាងលើតាមការស្នើសុំ និងព្រមទាំងចែងអំពីនីតិវិធីនៃការស្នើសុំ។ |
| **ជំពូកទី ៥ ៖ អំពីរបៀបវារៈ** | | |
| ៨ | **ប្រការ ២០ ថ្មី**<br>ក្នុងរបៀបវារៈ មានសេចក្តីជាលំដាប់មុនក្រោយដូចតទៅនេះ:<br>១.បញ្ហាទាំងឡាយ ដែលរដ្ឋសភាបានសម្រេចថាទុកជាការប្រញាប់<br>២.បញ្ហាទាំងឡាយ ដែលរាជរដ្ឋាភិបាលជូនមករដ្ឋសភា<br>៣.បញ្ហាទាំងឡាយ ដែលគណៈកម្មការនានាជូនមករដ្ឋសភា<br>៤.បញ្ហាទាំងឡាយ ដែលសមាជិករដ្ឋសភាជូនមករដ្ឋសភា។<br>បើក្នុងប្រភេទនីមួយៗមានបញ្ហាជាច្រើននោះ របៀបវារៈនៃបញ្ហាទាំងនោះ ត្រូវរៀបចំតាមលំដាប់កាលបរិច្ឆេទនៃការបញ្ជូនមកដល់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងពីនេះ។ | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះបានចែងទូលាយជាងបញ្ញត្តិចាស់អំពីរបៀបវារៈសម្រាប់កិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា ដែលជាបញ្ហារបស់គណៈកម្មការនានា ឬ/និង សមាជិករដ្ឋសភានឹងត្រូវបានដាក់ចូលក្នុងរបៀបវារៈរបស់រដ្ឋសភា ហើយរៀបចំតាមលំដាប់កាលបរិច្ឆេទ។ |
| **ជំពូកទី ៦ ៖ អំពីសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់** | | |
| ៩ | **ប្រការ ២១ ថ្មី**<br>សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ សេចក្តីព្រាងច្បាប់នោះធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវចែកជូនតំណាងរាស្ត្រទាំងអស់ ព្រមទាំងសេចក្តីថ្លែងហេតុមកជាមួយផង។<br>គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បញ្ជូនសេចក្តីព្រាងនោះទៅគណៈកម្មការតាមមុខជំនាញឱ្យពិនិត្យ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនោះ ត្រូវនាំយកយោបល់គណៈកម្មការមកជម្រាបជូនរដ្ឋសភា។ | បញ្ញត្តិនេះមានភាពមិនច្បាស់លាស់ ព្រោះថា ការប្រែប្រួលមិនមានចំណុចគួរឲ្យកត់សម្គាល់។ |
| ១០ | **ប្រការ ២២ ថ្មី** (ពីរ)<br>សេចក្តីស្នើច្បាប់ដែលតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាជាអ្នកធ្វើនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចែកជាមាត្រា ហើយមានសេចក្តីថ្លែងហេតុនៅខាងដើមជាប់មក | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះបានចែងបន្ថែមអំពីនីតិវិធីនៃការបញ្ជូនសេចក្តីស្នើច្បាប់នៅក្នុងរដ្ឋសភា។ |

| | | |
|---|---|---|
| | ជាមួយផង។<br>គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បញ្ជូនសេចក្តីស្នើច្បាប់នោះទៅគណៈកម្មការតាមមុខជំនាញឱ្យពិនិត្យ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភា។ | ផ្នែកខ្លះនៃបញ្ញត្តិនេះមានភាពមិនច្បាស់លាស់ ត្រង់ចំណុច «ត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនរដ្ឋសភា» ព្រោះថា ជូនរដ្ឋសភាប្រជុំពេញអង្គ ឬយ៉ាងណា? |
| **ជំពូកទី ៨ ៖ អំពីបញ្ញត្តិពិសេសសម្រាប់ថវិកាជាតិ និងថវិកាសម្រាប់រដ្ឋសភា** | | |
| ១១ | **ប្រការ ៣១ថ្មី (ថី)**<br>រដ្ឋសភា មានថវិកាស្វយ័តសម្រាប់ដំណើរការ។ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដោយមានការចូលរួមពីតំណាងគណៈកម្មការនានារបស់រដ្ឋសភា មានភារកិច្ចពិនិត្យ និងលើកយោបល់ក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋសភា ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាពិនិត្យសម្រេច ហើយបញ្ជូនសេចក្តីស្នើថវិកានោះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់បញ្ចូលទៅក្នុងគម្រោងថវិកាជាតិ តាមការកំណត់ក្នុងច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។<br>រាល់ការចំណាយថវិការបស់រដ្ឋសភា ត្រូវមានតម្លាភាព និងធានាផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងសមធម៌ជូនដល់រដ្ឋសភា គណៈកម្មការនានារបស់រដ្ឋសភា ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ និងសមាជិករដ្ឋសភា។<br>បែបបទចំណាយថវិការបស់រដ្ឋសភា ត្រូវកំណត់ដោយសេចក្តីសម្រេចប្រចាំឆ្នាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។<br>អគ្គលេខាធិការដ្ឋានរដ្ឋសភា ទទួលខុសត្រូវធ្វើរបាយការណ៍ចំណាយថវិការដ្ឋសភានៅរាល់៦ខែម្តង និងក្នុងរាល់ដំណាច់ឆ្នាំ និងដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាពិនិត្យសម្រេច ក្រោយពីមានការវាយតម្លៃ និងសេចក្តីសន្និដ្ឋានពីគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រមទាំងមានការចូលរួមពីតំណាងគណៈកម្មការនានារបស់រដ្ឋសភាផង លើកលែងតែរបាយការណ៍ទូទាត់ថវិកាដំណាច់ឆ្នាំ ក្រោយពីគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យសម្រេច ហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរៀបចំបញ្ចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ។ | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះបានចែងលំអិតអំពីដំណើររៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋសភា និងរបាយការណ៍ចំណាយថវិកា និងព្រមទាំងបើកឲ្យមានការចូលរួមពីតំណាងគណៈកម្មការនានារបស់រដ្ឋសភា។ រាល់ការចំណាយថវិកាជាតិត្រូវធានាផ្តល់សេវាដោយសមធម៌ជូនថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ និងសមាជិករដ្ឋសភា។ |

| ជំពូកទី ៩ ៖ អំពីសំណួរ និងចម្លើយ | | |
|---|---|---|
| ១២ | **ប្រការ ៣៣ ថ្មី(ពីរ)**<br>តំណាងរាស្ត្រដែលបានតាំងសំណួរចំពោះរដ្ឋមន្ត្រីណាមួយ អាចសុំដកលិខិតតាំងសំណួររបស់ខ្លួនចេញបាន។<br>តំណាងរាស្ត្រឯទៀតអាចទទួលពាក្យសុំតាំងសំណួរដែលដកចេញហើយនោះទៅជូនប្រធានរដ្ឋសភាសាជាថ្មីទៀតបាន កាលបើយល់ឃើញថាចាំបាច់។<br>បើមានការបើកឱ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និងរដ្ឋមន្ត្រីពាក់ព័ន្ធ នាយករដ្ឋមន្ត្រីអាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ។ រដ្ឋសភាកំណត់ទុករយៈពេលមួយថ្ងៃក្នុងមួយសប្តាហ៍សម្រាប់ការតាំង និងការឆ្លើយសំណួរ។ ការប្រជុំនេះ មិនទាមទារកូរ៉ុមទេ។<br>បើសំណួរ ចំលើនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី ឬតំណាងក្នុងករណីនាយករដ្ឋមន្ត្រីមានធុរៈ ត្រូវមកឆ្លើយសំណួរ។<br>បើសំណួរ ចំលើសមាជិករាជរដ្ឋាភិបាលរូបណា សមាជិករូបនោះ ត្រូវមកឆ្លើយសំណួរនៅរដ្ឋសភា។<br>ទោះបីជាយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ។<br>បែបបទ និងនីតិវិធីនៃសំណួរ និងចម្លើយ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋសភា។ | បញ្ញត្តិនេះមានភាពមិនច្បាស់លាស់ ព្រោះថាអាចនឹងមានបទដ្ឋានខុសគ្នាទៅលើការសម្រេចរបស់ប្រធានរដ្ឋសភាលើបែបបទ និងនីតិវិធីនៃសំណួរ និងចម្លើយ។ ការសម្រេចរបស់ប្រធានដោយគ្មាននីតិវិធីអាចនាំមកនូវភាពអត្តនោម័ត និងលម្អៀងដោយគ្មានហេតុផល។ ការអនុវត្តន៍កន្លងមក ប្រធានរដ្ឋសភាបានសម្រេចមិនឲ្យតំណាងរាស្ត្រដាក់សំណួរ ចំពោះការកោះអញ្ជើញតំណាងរដ្ឋាភិបាលមកបំភ្លឺនៅរដ្ឋសភា។ |
| ១៣ | **ប្រការ ៣៤ ថ្មី**<br>គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីណាមួយ មកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន។ | បញ្ញត្តិនេះមានភាពអវិជ្ជមាន ព្រោះថាបានលុបពាក្យ «វរជនណាមួយ» ដែលគណៈកម្មការអាចអញ្ជើញមកបំភ្លឺ។ វិសោធនកម្មនេះបានបន្ថយវិសាលភាពនៃប្រការនេះនៅស្របពេលដែលការអនុវត្តន៍ក្នុងអណត្តិទី៥នេះ (នៅបន្ទាប់ពីតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចូលរដ្ឋសភា) ដោយគណៈកម្មការជំនាញដឹកនាំដោយគណបក្សប្រឆាំងក្នុងការកោះអញ្ជើញមន្ត្រីសង្គមស៊ីវិល និងមន្ត្រីពាក់ព័ន្ធផ្សេងទៀតទៅឆ្លើយបំភ្លឺនៅរដ្ឋសភាលើវិស័យពុករលួយ ដីធ្លី និងសិទ្ធិមនុស្សជាដើម។ |

| | | |
|---|---|---|
| | | ម៉្យាងទៀតអាចមានការបកស្រាយថា គណៈកម្មការនានារបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រីបានតែម្នាក់ នៅស្របពេលដែលការអនុវត្តន៍កន្លងមកគណៈកម្មការខ្លះអញ្ជើញរដ្ឋមន្ត្រីច្រើនមកបំភ្លឺជាមួយគ្នា ព្រោះបញ្ហាដែលត្រូវបំភ្លឺនេះជាបញ្ហាអន្តរវិស័យ។ |
| **ជំពូកទី ១០ ៖ អំពីការបញ្ចេញមតិ** | | |
| ១៤ | **ប្រការ ៣៦ថ្មី** (**ពីរ**)<br>ក្នុងបញ្ហាទាំងឡាយដែលរដ្ឋសភាត្រូវពិនិត្យ រដ្ឋសភាបញ្ចេញមតិដោយវិធី៣យ៉ាងគឺ ដោយលើកដៃ ឬដោយបោះឆ្នោតចំហ ឬដោយបោះឆ្នោតសម្ងាត់។<br>វិធីបញ្ចេញមតិដោយលើកដៃ ឬដោយបោះឆ្នោតចំហខាងលើនេះ អាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច។ | បញ្ញត្តិនេះមានភាពមិនច្បាស់លាស់ ព្រោះថា ការប្រែប្រួលមិនមានចំណុចគួរឲ្យកត់សម្គាល់។ |
| ១៥ | **ប្រការ ៣៨ថ្មី** (**ពីរ**)<br>កាលបើការបញ្ចេញមតិដោយលើកដៃបានធ្វើពីរដងហើយ នៅតែមិនទាន់បានលទ្ធផលច្បាស់លាស់នោះ ត្រូវប្រើវិធីបោះឆ្នោតជាចំហ។<br>វិធីបោះឆ្នោតចំហនេះត្រូវធ្វើដូចតទៅៈ<br>អាជ្ញាសភាដែលជាមន្ត្រីចាត់តាំងដោយអគ្គលេខាធិការរដ្ឋសភា កាន់ហិបឆ្នោតដើរទទួលប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា។ សមាជិករដ្ឋសភា ត្រូវសរសេរឈ្មោះខ្លួនលើសន្លឹកឆ្នោតនោះ។ សន្លឹកឆ្នោត មានបីយ៉ាងៈ ពណ៌សសម្គាល់ថាព្រម ពណ៌ខៀវសម្គាល់ថាមិនព្រម និងពណ៌សឆ្នូតខៀវសម្គាល់ថា អនុបវាទ។<br>ក្រោយពីបោះឆ្នោតរួចស្រេចហើយ លេខាធិការរាប់សន្លឹកឆ្នោត។ ដល់រាប់សន្លឹកឆ្នោតរួចហើយ ប្រធានរដ្ឋសភាត្រូវប្រកាសលទ្ធផលជូនអង្គសភាស្ដាប់។ | បញ្ញត្តិនេះមានភាពមិនច្បាស់លាស់ ព្រោះថា ការប្រែប្រួលមិនមានចំណុចគួរឲ្យកត់សម្គាល់។ |

| | | |
|---|---|---|
| ១៦ | **ប្រការ ៤០ថ្មី** (**ពីរ**)<br>វិធីបោះឆ្នោតសម្ងាត់ត្រូវតែប្រើក្នុងការជ្រើសតាំង ការសម្ដែងការទុកចិត្ត និងក្នុងការអនុម័តញត្តិបន្ទោស វៀរលែងតែមានកំណត់ក្នុងច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវ | បញ្ញត្តិនេះមានភាពមិនច្បាស់លាស់ ព្រោះថា ការប្រែប្រួលមិនមានចំណុចគួរឲ្យកត់សម្គាល់។ |

| | | |
|---|---|---|
| | ដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។<br>ការអនុម័តច្បាប់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ អាចប្រព្រឹត្តដោយវិធីបោះឆ្នោតសម្ងាត់ដែរ។<br>សម្រាប់ការបោះឆ្នោតសម្ងាត់ លេខាធិការអង្គប្រជុំត្រូវចាប់ឆ្នោតជ្រើសរើសសមាជិកប្រាំរូប ក្នុងចំណោមឈ្មោះសមាជិករដ្ឋសភាវត្តមាន ដើម្បីរៀបចំជាគណៈកម្មការបោះឆ្នោត។ | |
| **ជំពូកទី ១២ ថ្មី ៖ អំពីរបៀបប្រជុំ និងថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ** | | |
| ១៧ | **ប្រការ ៤៧ថ្មី** (**បួន**)<br>ការប្រជុំរដ្ឋសភា ត្រូវធ្វើជាសាធារណៈ។<br>ការប្រជុំរដ្ឋសភានឹងយកជាការបានលុះត្រាតែមានៈ<br>**ក**. កូរ៉ុមលើសពីពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>**ខ**. កូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។<br>សមាជិកដែលអវត្តមានត្រូវបានចុះក្នុងបញ្ជីអវត្តមាន ហើយបញ្ជីនេះត្រូវបានប្រកាសដោយប្រធាន ដោយបញ្ជាក់អំពីមូលហេតុផង។<br>ប្រធានរដ្ឋសភាត្រូវផ្អាកការប្រជុំ បើកូរ៉ុមមិនគ្រប់ក្នុងរយៈពេល១៥(ដប់ប្រាំ)នាទីបន្ទាប់ពីហួសពេលកំណត់នៃការចាប់ផ្តើមប្រជុំ។ | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះបានបញ្ញត្តិនេះបានបញ្ជាក់បន្ថែមថា ការប្រជុំរដ្ឋសភា ត្រូវធ្វើជាសាធារណៈ ខណៈដែលរដ្ឋធម្មនុញ្ញក៏បានបញ្ជាក់ដែរ។ |
| ១៨ | **ប្រការ ៤៨ ថ្មី** (**បី**)<br>តំណាងរាស្ត្រនៃគណបក្សនយោបាយ ដែលមានអាសនៈក្នុងរដ្ឋសភា ចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ត្រូវរៀបចំថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ តាមគណបក្សនយោបាយនីមួយៗ។ ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ មានសមាសភាពយ៉ាងច្រើន ៣ (បី) រូប ដោយត្រូវមានប្រធាន១(មួយ) រូប។ បញ្ជីរាយនាម | បញ្ញត្តិនេះមានភាពវិជ្ជមាន ព្រោះថា ការកំណត់អាសនៈចំនួន២៥%នៃរដ្ឋសភា នៃគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល (គណបក្សប្រឆាំង) ជាលក្ខខណ្ឌការបង្កើតប្រធានក្រុមភាគតិច និងការទទួលស្គាល់គណបក្សប្រឆាំងធំជាងគេនៅក្នុងរដ្ឋសភា។ ចំនួនអាសនៈ ២៥%នោះ ជាអាសនៈគឺសម្រាប់គណបក្សតែមួយ។ ការតម្រូវចំនួនភាគរយនៃអាសនៈច្រើន បើដូចរដ្ឋសភានៅ |

| | | |
|---|---|---|
| | របស់ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយត្រូវផ្ញើជូនប្រធានរដ្ឋសភា។ ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយមានភារកិច្ចដូចខាងក្រោម៖<br>-ធ្វើការដឹកនាំតំណាងរាស្ត្ររបស់គណបក្ស ដើម្បីធ្វើឲ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅស្របតាមកម្មវិធីនយោបាយ និងគោលការណ៍នានារបស់គណបក្ស។<br>-ធ្វើការសម្របសម្រួលជាមួយថ្នាក់ដឹកនាំតំណាងរាស្ត្រគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីធ្វើឲ្យការងារពាក់ព័ន្ធទាំងឡាយបានប្រព្រឹត្តទៅដោយរលូន និងធានាបាននូវផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។<br>រដ្ឋសភាត្រូវផ្តល់ឲ្យថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ នូវមធ្យោបាយសមស្រប ដើម្បីថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយ បំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អនៅក្នុងរដ្ឋសភា។<br>ប្រធានក្រុមតំណាងរាស្ត្រនៃគណបក្សនយោបាយក្រៅរាជរដ្ឋាភិបាល ដែលមានអាសនៈក្នុងរដ្ឋសភាចាប់ពី ២៥ (ម្ភៃប្រាំ) ភាគរយឡើងទៅ មានឈ្មោះហៅថា ប្រធានក្រុមមតិភាគតិចនៅរដ្ឋសភា។ ប្រធានក្រុមមតិភាគតិច ជាគូសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទាក់ទងនឹងបញ្ហាប្រទេសជាតិ។ ប្រធានក្រុមមតិភាគតិច មានឋានៈស្មើនាយករដ្ឋមន្ត្រី។<br>អាសនានុក្រមនៃក្រុមតំណាង ត្រូវរៀបជាក្រុមៗ តាមគណបក្សនយោបាយពីមុខទៅក្រោយ។ ក្រុមនីមួយៗ ត្រូវមានសមាជិកយ៉ាងតិចដប់រូប។ តំណាងរាស្ត្រមួយរូបអាចចូលជាសមាជិករបស់ក្រុមតែមួយប៉ុណ្ណោះ។ ក្រុមនីមួយៗ ត្រូវមានប្រធានមួយរូប អនុប្រធានមួយរូប។ គណបក្សនយោបាយមានអាសនៈតិចជាងដប់ត្រូវជ្រើសរើសក្រុមណាមួយដែលខ្លួនពេញចិត្តនៅជាមួយ។ បញ្ជីរាយនាមរបស់ក្រុមតំណាងរាស្ត្រ នៃគណបក្សនយោបាយ ត្រូវផ្ញើជូនប្រធានរដ្ឋសភា។ | អាណត្តិកន្លងមកគ្មានទេប្រធានក្រុមភាគតិច ឬប្រធានក្រុមគណបក្សប្រឆាំង។ ជាមួយគ្នានេះវិសោធនកម្មមិនបានចែងច្បាស់លាស់អំពីតួនាទី និងសិទ្ធិអំណាចរបស់ប្រធានក្រុមតំណាងរាស្ត្រនៃគណបក្សនយោបាយប្រឆាំងនេះ។ តំណាងរាស្ត្រនៃគណបក្សមួយមានអាសនៈចាប់ពី៥% បង្កើតថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនោះ។<br><br>ខុមប្រែ្វលផ្តល់អនុសាសន៍ថា ប្រធានក្រុមភាគតិចគួរត្រូវបានអនុញ្ញាតឲ្យបង្កើតអ្នកនាំពាក្យ នៃក្រុមភាគតិចនៅរដ្ឋសភាទទួលបន្ទុកវិស័យសំខាន់ៗរបស់រាជរដ្ឋាភិបាល។<br>ប្រការនេះ គួរលប់ចោលលក្ខខណ្ឌតម្រូវតំណាងរាស្ត្រ ១០នាក់ ក្នុងការបង្កើតក្រុម ឬទុកឲ្យបង្កើតក្រុមតំណាងរាស្ត្រមួយដែរ ចំពោះគណបក្សទទួលបានអាសនៈតិចជាង១០ ដែលផ្តល់លទ្ធភាពក្នុងការបញ្ចេញមតិដល់គណកប្សនោះក្នុងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា។ |

**ជាសរុប ៖** បញ្ញត្តិថ្មី (បានផ្លាស់ប្តូរ ឬបន្ថែម) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាគឺមានភាពវិជ្ជមានច្រើន។ មានបញ្ញត្តិនៃប្រការ**ចំនួន៩** មានភាព**វិជ្ជមាន** ហើយបញ្ញត្តិនៃប្រការ**ចំនួន១** មានភាព**អវិជ្ជមាន** និងខណៈដែលបញ្ញត្តិនៃប្រការ**ចំនួន៨** មានភាព**មិនច្បាស់លាស់**។

# ឧបត្ថម្ភដោយ

diakonia
PEOPLE CHANGING THE WORLD

NORWEGIAN PEOPLE'S AID

Oxfam

Activity supported by the
Canada Fund for Local Initiatives

Activité réalisée avec l'appui du
Fonds canadien d'initiatives locales

Canada

OPEN SOCIETY
FOUNDATIONS

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ ទឹកល្អក់១ ទួលគោក ភ្នំពេញ ប្រអប់សំបុត្រលេខ ១១៤៥

ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ ទូរសារ ០២៣ ៨៨៥ ៧៤៥

អ៊ីម៉ែល: comfrel@online.com.kh ; comfrel@comfrel.org

គេហទំព័រ: www.comfrel.org